ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ រឿងនិទាន «ផ្លូវភាពស្ងៀមស្ងាត់» នឹងជួយឲ្យមានការពិភាក្សា និងការចងចាំ

◆ «ភ្នំព្រៃ» នឹងជួយឲ្យមានការយល់ដឹងពីប្រវត្តិសាស្ត្រ និងសារសំខាន់នៃព្រៃឈើ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៣៣ ខែឧសភា ឆ្នាំ២០១៩

# ស្វែងរកការពិត

លេខ២៣៣ ខែឧសភា ឆ្នាំ២០១៩


## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

### សំបុត្រ


◆ ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ..............................១


### ផ្នែកឯកសារ


◆ ផាន យោន ហៅ ដួន ជនជាតិលាវ អតីតនីរសាររបស់ កុយ ធួន .. ៤


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


◆ ការសម្ដែងល្ខោននិយាយរឿង «ទម្លាយភាពស្ងៀមស្ងាត់»........... ៨

◆ អតីតគណៈស្រុករងស្រុកសំឡូត ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ. ១១

◆ ការយល់ខុសរបស់ សារុន បានធ្វើឲ្យគាត់ធ្លាក់ខ្លួនជាពេជ្ឈឃាដ...១៣

◆ រឿងរ៉ាវរបស់ មុន សារឿន ហៅ មុន មុត........................... ១៨

◆ រឿងរ៉ាវរបស់ប្រជាជនចេញពីសហគមន៍អន្លង់វែង.................. ២០

◆ រឿងខ្ញុំនៅក្នុងរបបខ្មែរក្រហម.......................................... ២៨

◆ ការចាប់ផ្ដើម និងការបញ្ចប់ជីវិតជាយោធា ..........................៣០

◆ ដោយសារសង្គ្រាមទើបខ្ញុំបានមករស់នៅស្រុកវាលវែង........... ៣៤

◆ ហួន យន ៖ អតីតគ្រូពេទ្យមើលថែជំងឺ តាម៉ុក...................... ៣៨

◆ ការងាររបស់ស្ត្រីនៅក្នុងរបបខ្មែរក្រហម ............................. ៤០

◆ «ឆ្នាំព្រៃ» នឹងជួយឲ្យមានការយល់ដឹងពីប្រវត្តិសាស្ត្រ ............. ៤២


### ផ្នែកច្បាប់


◆ សេចក្ដីសង្ខេបសាលក្រមសំណុំរឿង០០២/០២.......................៤៧


### វេទិកាពិភាក្សាសាធារណៈ


◆ ការយល់ឃើញរបស់អ្នកទស្សនាទៅលើគ្រូពេទ្យ.................... ៥១


### ទំព័រស្រាវជ្រាវរកគ្រួសារ


◆ បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម ............ ៥៦

◆ អដ្ឋិធាតុ៖ គ្មានអ្វីជាអមតៈ ..............................................៥៩




ក្រុមសិល្បៈសែនក្រុងពាលីមុនចាប់ផ្ដើមសម្ដែងល្ខោននិយាយ
ទម្លាយភាពស្ងៀមស្ងាត់


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ៣៧៥ ព.មប្រក

ចុះថ្ងៃអង្គារ ៦រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធស័ក ព.ស២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



***ស្នេរលេខនេះ៖*** *ផាត ចាន់សុនិតា, សួត វិចិត្រ, សុខ វណ្ណៈ, ឡុង ដានី, វ៉ាន់ ថាន់ពៅដារ៉ា, ព្រាំ គិតម៉ាន់, និង រី លក្ខិណា* ***អ្នកនិពន្ធ និងស្រាវជ្រាវ៖*** *ដារ៉ារដ្ឋ មេត្តា, អ៊ុន សុដាវី និង ហូ ចុំនា* ***អ្នកបកប្រែ៖*** *អ៊ុន សុដាវី* ***និពន្ធនាយកទូទៅ៖*** *សោម ប៊ុនថន* ***ជំនួយការនិពន្ធនាយក៖*** *ហូ ចុំនា* ***ក្រាហ្វិកកុំព្យូទ័រ៖*** *គីម សុវណ្ណដានី* ***គ្រប់គ្រងការចែកផ្សាយ៖*** *ឆេង វើង*



**Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org**

# ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» នឹងជួយឲ្យមានការពិភាក្សា និងការចងចាំ

ល្ខោននិយាយរឿង «ទម្លាយភាពស្ងៀមស្ងាត់» គឺជាសាច់រឿងល្ខោនដែលដកស្រង់ចេញពីរឿងរ៉ាវពិតរបស់អ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហម តាមរយៈការស្រាវជ្រាវ និងសម្ភាសន៍ជាមួយជនរងគ្រោះ និងជនដែលដល់នៅតាមភូមិឃុំនានាក្នុងប្រទេសកម្ពុជា។ ល្ខោននិយាយរឿង «ទម្លាយភាពស្ងៀមស្ងាត់» បានចូលរួមចំណែកដល់ភាពចំបាច់ក្នុងការបញ្ចប់ភាពស្ងៀមស្ងាត់របស់ប្រជាជនកម្ពុជាដែលបានអូសបន្លាយអស់រយៈពេល ៤ ទសវត្សរ៍មកហើយ ស្របពេលដែលល្ខោននេះ បានក្លាយជាមធ្យោបាយក្នុងការលើកឡើងអំពីកិច្ចពិភាក្សា និងចម្ងល់នានា ដើម្បីចាប់ផ្តើមការផ្សះផ្សា និងការចងចាំពីរបបខ្មែរក្រហម។ មិនត្រឹមតែជារឿងរ៉ាវរបស់អ្នករស់រានមានជីវិតប៉ុណ្ណោះទេ រឿងរ៉ាវរបស់សាលាក្តីខ្មែរក្រហម ក៏ត្រូវបានលើកឡើងនៅក្នុងវគ្គបញ្ចប់នៃល្ខោននេះដែរ ដើម្បីបញ្ជាក់ថា សាលាក្តីនេះមានតួនាទីយ៉ាងសំខាន់ក្នុងការស្តារជំនឿទុកចិត្តចំពោះប្រព័ន្ធច្បាប់ដែលរងភាពខ្ទេចខ្ទាំពីរបបខ្មែរក្រហម និងដំណើរយុត្តិធម៌ដែលអាចទទួលយកបាន។

ល្ខោននិយាយរឿង «ទម្លាយភាពស្ងៀមស្ងាត់» ត្រូវបានសម្តែងឡើងជាលើកដំបូងចាប់តាំងពីឆ្នាំ២០០៩ និងមានចំនួន២១ទីតាំង ស្ថិតនៅក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានាទូទាំងប្រទេសកម្ពុជា ដោយមានសាធារណជនចំនួន ១០.១១០នាក់ បានចូលរួមទស្សនា។ នៅក្នុងខែឧសភា ឆ្នាំ


គរុសិស្សកំពុងរង់ចាំទស្សនាល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់


អ្នកភូមិកំពុងរង់ចាំទស្សនាល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់


ទស្សនិកជនរង់ចាំទស្សនាល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់ ស្ថិតនៅបរិវេណវិទ្យាស្ថានគរុសិស្ស បាត់ដំបង

២០១៩នេះ ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ត្រូវបានសម្តែងនៅវិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបង ដែលមានបុគ្គលិកសិក្សា គ្រូ គរុសិស្ស និស្សិត និងប្រជាជនប្រមាណ៨០០ នាក់បានចូលរួមទស្សនា បន្ទាប់ពីបានសម្តែងនៅវិទ្យាស្ថានជាតិអប់រំ ក្នុងទីក្រុងភ្នំពេញ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាមនិងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង កន្លងមក។ ការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» មិនត្រឹមតែជាការចែករំលែកដល់អ្នកទស្សនាឲ្យស្វែងយល់ពីប្រវត្តិសាស្ត្រ និងបទពិសោធន៍របស់អ្នករស់រានមានជីវិតនៅក្នុងរបបខ្មែរក្រហមប៉ុណ្ណោះទេ គឺថែមបានជំរុញឲ្យការផ្សះផ្សា កសាងសន្តិភាព ការទប់ស្កាត់អំពើប្រល័យពូជសាសន៍ទៀតផង។ ល្ខោននិយាយរឿង «ទម្លាយភាពស្ងៀមស្ងាត់» បានលាតត្រដាងរឿងរ៉ាវជាច្រើនដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម តាមរយៈតួអង្គដែលជាគ្រូបង្ហាត់បង្រៀនសិល្បៈនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ដែលនៅរស់ជីវិតពីរបបខ្មែរក្រហម។ អ្នកទស្សនាបានឃើញឈុតឆាក ទិដ្ឋភាព និងបានស្តាប់ពួតួអង្គនិយាយរៀបរាប់រឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម លាយឡំជាមួយអារម្មណ៍ពុះកញ្ជ្រោលជាមួយបទពិសោធន៍ផ្ទាល់របស់តួអង្គ អមជាមួយបទចម្រៀង បានធ្វើឲ្យសាច់រឿងល្ខោននេះហាក់ដូចជាបានកើតឡើងនៅពេលថ្មីៗដែរ។

ល្ខោននិយាយរឿង «ទម្លាយភាពស្ងៀមស្ងាត់» បានលាតត្រដាងពីការលាក់បាំង និងការរស់នៅមិនចុះសម្រុងគ្នាក្នុងចំណោមជនដៃដល់ និងជនរងគ្រោះពីរបបខ្មែរក្រហម ដើម្បីជំរុញឲ្យមានការពិភាក្សាវែកញែក និងឈានទៅដល់ការផ្សះផ្សាជាតិ។ ល្ខោននិយាយនេះ ក៏បានបង្កើតឲ្យមានការគិតពិចារណាស៊ីជម្រៅ និងវិជ្ជមាន ជាជាងការដាក់បន្ទុកការស្អប់ គុំគួន ក្នុងចំណោមសាធារណជន គ្រូបង្រៀន និងសិស្សានុសិស្ស នៅតាមសាលារៀនដែរ។

បន្ទាប់ពីបានទស្សនាការសម្តែងរយៈពេលជាងមួយម៉ោង គរុសិស្ស លី សុខគង់ ក៏បានលើកជាសំណួរថា តើអ្នកមានអារម្មណ៍ឈឺចាប់ដូចម្តេចខ្លះក្នុងនាមជាជនរងគ្រោះ? របបខ្មែរក្រហមបានកន្លងហួសទៅហើយ តើជនរងគ្រោះ



សាធារណជនរង់ចាំទស្សនាល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់

អាចលើកលែងទោសឲ្យអ្នកដែលប្រព្រឹត្តខុសបានដែរឬទេ? សុខគង់ ក៏បានលើកពីគំនិតចង់ឲ្យមានការពិភាក្សាគ្នារវាងជនរងគ្រោះ និងជនដៃដល់ជួបគ្នាដើម្បីដោះស្រាយរឿងរ៉ាវដែលបានកើតឡើងពីអតីតកាលដែរ។

អ្នកគ្រូ ស៊ីណា គឺជាតួសម្ដែងក្នុងល្ខោននិយាយរឿង «ទម្លាយភាពស្ងៀមស្ងាត់» បានមានប្រសាសន៍ថា ៖ ខ្ញុំមានអារម្មណ៍ឈឺចាប់ នៅពេលដែលពេទ្យខ្មែរបានចាក់ថ្នាំឲ្យឪពុករបស់ខ្ញុំ ហើយមួយសន្ទុះក្រោយមកឪពុករបស់ខ្ញុំក៏ស្លាប់ទៅ។ នៅថ្ងៃមួយពេលខ្ញុំកំពុងធ្វើការនៅវាលស្រែ ប្រធានកងបានមកវាយដំខ្ញុំយ៉ាងខ្លាំង ជ្រមុជទៅក្នុងទឹកដោយចោទថាខ្ញុំមិនចេះស្ដូង។ ពេលនោះខ្ញុំនៅវ័យកុមារនៅឡើយ ខ្ញុំមានការឈឺចាប់យ៉ាងខ្លាំង។ រហូតដល់សព្វថ្ងៃ ខ្ញុំនៅតែចងចាំរឿងរ៉ាវទាំងនេះ ប៉ុន្តែខ្ញុំក៏មិនមានចិត្តស្អប់ គុំគួន និងសងសឹកជាមួយអ្នកដែលធ្លាប់ធ្វើបាបខ្ញុំ និងក្រុមគ្រួសារខ្ញុំដែរ ព្រោះអ្នកដែលស្លាប់ទៅហើយមិនអាចរស់ឡើងវិញទេ ហើយជនរងគ្រោះក៏មិនមែនតែគ្រួសារខ្ញុំដែរ គឺប្រជាជនខ្មែរទាំងអស់។ ពេលខ្លះខ្ញុំមិនចង់និយាយពីការឈឺចាប់របស់ខ្ញុំឡើយ ប៉ុន្តែដោយសារខ្ញុំជាអ្នកសិល្បៈ ខ្ញុំមានភារកិច្ចចែករំលែករឿងរ៉ាវទាំងនេះ ហើយខ្ញុំក៏មានមោទកភាពចំពោះការសម្ដែងនេះដែរ។

លោក សុខ ហ៊ីង នាយករងវិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបង បានមានប្រសាសន៍នៅក្នុងឱកាសបើកការសម្ដែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ថា គ្រូបង្រៀនគឺជាបុគ្គលដ៏សំខាន់ក្នុងការលាតត្រដាងពីប្រវត្តិសាស្ត្រខ្មែរក្រហម ការផ្សព្វផ្សាយនៅតាមថ្នាក់រៀន ភូមិ និងសហគមន៍។ ចំណែកល្ខោននេះនឹងធ្វើឲ្យមានការនិយាយ រំឭកឡើងវិញពីអតីតកាល ដែលនាំឲ្យមានអំពើប្រល័យពូជសាសន៍ និងការកាប់សម្លាប់សម្លាប់យ៉ាងរង្គាលនៅក្នុងរបបខ្មែរក្រហម។

«ទម្លាយភាពស្ងៀមស្ងាត់» បានបង្កប់ខ្លឹមសារអប់រំក្នុងសង្គមមួយដែលបែកបាក់ដើម្បីឈានឆ្ពោះទៅមុខ។ គរុសិស្សនិស្សិត ដែលនឹងក្លាយជាគ្រូបង្រៀននៅពេលខាងមុខ ក៏អាចយករឿងរ៉ាវទាំងនេះធ្វើជាមេរៀន និងលើកជាសំណួរដើម្បីពិភាក្សាក្នុងចំណោមសិស្សានុសិស្សរបស់ខ្លួននៅក្នុងថ្នាក់ដែរ។

**សោម ប៊ុនថន**



ការសម្ដែងល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់នៅខេត្តបាត់ដំបង

# ផាន យ៉ោន ហៅ ជួន ជនជាតិលាវ អតីតនីរសាររបស់ កុយ ធួន
## ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ D02696

នៅក្នុងចម្លើយសារភាពដែលមានកម្រាស់ ៦៦ទំព័រ ផាន យ៉ោន ហៅ ជួន ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៧។ ជួន ត្រូវបានបញ្ជូនទៅកាន់គុកទួលស្លែង ឬមន្ទីរ ស-២១ ហើយត្រូវបានសួរចម្លើយចំនួនពីរលើក។ លើកទីមួយនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៧៧ និងលើកទីពីរនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧។ ជួន ត្រូវបានសួរចម្លើយដោយឈ្មោះ ឡាក់ ហើយនៅលើចម្លើយសារភាពមានចំណាររបស់ ឌុច ដែលជាអតីតប្រធានមន្ទីរស-២១។ ខាងក្រោមនេះ ជាសកម្មភាពរបស់ ផាន យ៉ោន ហៅ ជួន មុនការចាប់ខ្លួន៖

ខ្ញុំឈ្មោះ ផាន យ៉ោន ហៅ ជួន មានអាយុ ៣៥ឆ្នាំ។ ខ្ញុំគឺជាជនជាតិលាវ។ ឪពុកម្តាយខ្ញុំបានមករស់នៅក្នុងប្រទេសកម្ពុជា តាំងពីពួកគាត់ទាំងពីរនាក់មិនទាន់រៀបការជាមួយគ្នា។ ម្តាយឪពុកខ្ញុំជាអ្នកធ្វើស្រែចម្ការ។ នៅពេលខ្ញុំមានអាយុ ១២ឆ្នាំ ខ្ញុំបានទៅរស់នៅវត្តពាមជីមាត។ ខ្ញុំរស់នៅ និងបម្រើព្រះសង្ឃរាជព្រះនាម ប៊ួ។ ខ្ញុំបានរស់នៅក្នុងវត្តពាមជីមាតបានរយៈពេល៣ឆ្នាំ។ នៅពេលព្រះសង្ឃរាជ ប៊ួ និមន្តទៅប្រទេសលាវវិញ ខ្ញុំក៏បានត្រឡប់ទៅរស់នៅជាមួយឪពុកម្តាយខ្ញុំវិញដែរ។

នៅអាយុ១៨ឆ្នាំ ខ្ញុំមានមុខរបរជាអ្នកផ្សាំងសត្វដំរីស្រុកឲ្យបុរសម្នាក់ឈ្មោះ តាផេង។ តាផេង គឺជាកសិករដែលមានទ្រព្យស្តុកស្តម្ភម្នាក់រស់នៅក្នុងភូមិលំផាត់។ អំឡុងពេលដែលខ្ញុំស៊ីឈ្នួលជាអ្នកផ្សាំងសត្វដំរី ខ្ញុំបានស្គាល់គិញម្នាក់ឈ្មោះ ខាំផៃ ដែលរស់នៅក្នុងភូមិស្រុកជាមួយខ្ញុំ។ ខាំផៃ ពីមុនធ្វើជាទាហានឲ្យបារាំង។ ក្រោយមកគាត់បានធ្វើជាគិញប្រចាំ



ប្រជាជននៅសហករណ៍កំពុងដឹកជញ្ជូនគ្រាប់រំសេវតាមរទេះសេះទៅផ្តល់ឲ្យយោធាខ្មែរក្រហមនៅសមរភូមិ នៅពេលវាយតទល់នឹងកងទ័ពវៀតណាម (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប៉ុស្តិ៍នៅ ខេត្តមណ្ឌលគិរី ដែលមានភារកិច្ចតាមដានសកម្មភាពរបស់ខ្មែរក្រហមក្នុងភូមិដីមាត។

នៅក្នុងឆ្នាំ១៩៦១ ខាំផៃ បានជួបខ្ញុំ និងបានបបួលខ្ញុំធ្វើជាទាហាន។ ខ្ញុំប្រាប់ ខាំផៃថា ខ្ញុំមិនចង់ធ្វើជាទាហានទេព្រោះមិនមានអ្នកណាជួយធ្វើស្រែចម្ការឪពុកម្តាយខ្ញុំ។ មួយខែក្រោយមកខ្ញុំបានជួប ខាំផៃ ម្តងទៀតនៅពេលខ្ញុំកំពុងផ្សាំងដំរី។ ខាំផៃ បានឲ្យខ្ញុំស៊ើបការណ៍ពីក្រុមខ្មែរក្រហមនៅក្នុងភូមិ ហើយខ្ញុំក៏យល់ព្រមទទួលការងារនេះព្រោះទទួលបានប្រាក់ខែ។ បន្ទាប់ពីស៊ើបការណ៍បានហើយ ខាំផៃ ឲ្យខ្ញុំរាយការណ៍ប្រាប់គិញស័ក្តិពីរនៅមណ្ឌលគិរី ឈ្មោះ អ៊ុយ អេង។ ខាំផៃ បានធ្វើការណែនាំខ្ញុំបន្ថែមទៀតឲ្យបន្លំខ្លួនប្រកបមុខរបររកស៊ីដូច ប្រជាជនដែលរស់នៅតាមភូមិ តាមស្រែ និងតាមព្រៃ។ ជាពិសេសតាមដានអ្នកដែលនិយាយនយោបាយ។ អ្នកដែលធ្វើសកម្មភាពជាមួយខ្ញុំពេលនោះមានឈ្មោះ មុង, លាប, វ៉ិន, ហា និងឈ្មោះ ផាត់។

នៅឆ្នាំ១៩៦៥ ខាំផៃ មានជំងឺ ហើយក៏បានស្លាប់ទៅ។ ខ្ញុំក៏បានបន្តសកម្មភាពតាមដានក្រុមខ្មែរក្រហមដោយធ្វើការរាយការណ៍ទៅឈ្មោះមុង ដែលធ្លាប់ធ្វើការជាមួយ ខាំផៃ និងផ្តល់ព័ត៌មានឲ្យទាហានស័ក្តិពីរឈ្មោះ សន បន្តទៀត។ នៅដើមឆ្នាំ១៩៦៧ សកម្មភាពរបស់ខ្មែរក្រហម មានភាពផុសផុលខ្លាំងណាស់។ មុង ក៏បានហៅខ្ញុំ, ហា, ផាត់, វ៉ិន និងឈ្មោះ លាប ទៅណែនាំ ហើយឲ្យបន្លំខ្លួនជាអ្នកលក់មាន់ ដើម្បីតាមដានក្រុមខ្មែរក្រហម។ ខ្ញុំបានទទួលផែនការឲ្យទៅទិញមាន់នៅស្រែលំម៉ាន់។ ខ្ញុំបានឃើញប្រជាជននៅស្រែលំម៉ាន់ ចំនួន៣នាក់យកអង្ករដើរកាត់តាមមាត់ទន្លេស្រែពក។ ខ្ញុំបានដឹងច្បាស់ថា ប្រជាជនទាំងនោះយកអង្ករទៅឲ្យខ្មែរក្រហម។ ខ្ញុំ និងឈ្មោះហា បានរាយការណ៍ប្រាប់ទៅ មុង។ មុង បានធ្វើការទាក់ទងទៅប៉ូលីសឈ្មោះ ម៉ន ចាប់ខ្លួនជនទាំងនោះយកទៅឃុំឃាំង។

នៅក្នុងឆ្នាំ១៩៦៨ បងហម (ហៅឡាំង) បានឲ្យខ្ញុំនៅជាមួយគាត់នៅមន្ទីរសម្ងាត់៦០។ ខ្ញុំនៅជាមួយបងឡាំង បានរយៈពេល២ខែ បងឡាំងក៏បានចាត់តាំងខ្ញុំឲ្យធ្វើនីរសាររបស់កម្មាភិបាល។ ប៉ុន្តែក្រោយមកខ្ញុំបានធ្វើជានីរសាររបស់បង កុយ ធុច ហៅ យួន (កុយ ធួន)។ ពេលខ្ញុំនៅជាមួយបងយួន បានចំនួនពីរថ្ងៃ បងយួន បានឲ្យមួកស្បែកពណ៌ខ្មៅមកខ្ញុំ ហើយគាត់បាននិយាយថាមិត្តពាក់មួកនេះសមណាស់។ មិត្តសមធ្វើជាហ្មដំរី។ ចាប់ពីថ្ងៃនោះមកខ្ញុំគោរពស្រឡាញ់ បងយួន ព្រមទាំងគិតថាគាត់ជាមនុស្សល្អ។ បងយួន ទុកចិត្តខ្ញុំខ្លាំងណាស់។ នៅថ្ងៃមួយខ្ញុំបានដឹក បងយួន ពីខេត្តមណ្ឌលគិរីទៅខេត្តក្រចេះ។ នៅពេលធ្វើដំណើរតាមផ្លូវបងយួនបានអប់រំខ្ញុំអំពីបញ្ហាដូចជា៖ ធ្វើបដិវត្តន៍មានភាពលំបាកខ្លាំងភាពស្មុគស្មាញ អត់បាយ គ្មានអាវុធគ្រប់គ្រាន់។ បងយួន ប្រាប់ខ្ញុំថា គាត់ធ្វើបដិវត្តន៍ពីរផ្នែកគឺ ធ្វើបដិវត្តន៍ផង និងប្រឆាំងបដិវត្តន៍ផង។

នៅឆ្នាំ១៩៦៩ បងយួន បានអប់រំខ្ញុំ, ធី (ប្រធានមន្ទីរទទួលភ្ញៀវភូមិភាគឧត្តរ) និងឈ្មោះសែម (នីរសារ) ម្តងទៀតដោយលើកឡើងអំពីបញ្ហាលំបាកដដែល និងបន្តបំផ្លាញបដិវត្តន៍។ មិត្តដែលបរដំរីត្រូវបំផ្លាញសម្ភារតាមរបៀបបរដំរី ចំណែកមិត្ត សែម និងមិត្ត ធី ត្រូវបំផ្លាញតាមអ្វីដែលអាចធ្វើទៅបាន។ ក្រោយមកយើងទាំងបីនាក់ បាននាំគ្នាធ្វើសកម្មភាពដោយបានយកក្រណាត់ចំនួន២គី ទៅទម្លាក់ចោលក្នុងព្រៃអូរប្បារ និងបានធ្វើឲ្យថ្នាំពេទ្យខូចអស់មួយចំនួន។

នៅដើមឆ្នាំ១៩៧០ ខ្ញុំបានផ្តាច់ការទាក់ទងជាមួយបងយួន ពីព្រោះគាត់ត្រូវបានផ្លាស់ប្តូរទៅភូមិភាគឧត្តរវិញ។ មុនពេល បងយួន ផ្លាស់ទៅ គាត់បាននិយាយប្រាប់ខ្ញុំថា ត្រូវទាក់ទងធ្វើសកម្មភាពជាមួយ មិត្តកង (ប្រធានបច្ចេកទេសខាងសិប្បកម្ម១០៥)។ ក្រោយពេល បងយួន ផ្លាស់ទៅ ខ្ញុំក៏ត្រូវបានផ្លាស់ទៅកន្លែងផ្សេងដែរ។ ខ្ញុំបានផ្លាស់មកកាន់សមាជិកពាណិជ្ជកម្មតំបន់ ១០៥មានទីប្រចាំការនៅតំបន់៥០៥។

នៅខែវិច្ឆិកា ឆ្នាំ១៩៧១ ទើបខ្ញុំជួបធ្វើការទាក់ទងជាមួយមិត្តកង។ នៅឆ្នាំ១៩៧២មិត្តកងបានហៅខ្ញុំទៅប្រជុំនៅខេត្តក្រចេះ។ អ្នកចូលរួមប្រជុំមានមិត្តកង(អនុលេខាតំបន់៥០៥),

ឈ្មោះខន (ប្រធានសន្តិសុខតំបន់៥០៥), ឈ្មោះសៃ (អនុប្រធានសន្តិសុខ៥០៥) និងខ្ញុំ។ ដំបូង មិត្តកង បានណែនាំឲ្យខ្ញុំស្គាល់ មិត្តខន និង សៃ ដែលជាខ្សែរយៈ សេ.អ៊ី.អា.។ បន្ទាប់មក មិត្តកង បានឲ្យធ្វើសកម្មភាពតាមផែនការដោយធ្វើការបំផ្លាញសម្ភាររបស់អង្គការ និងទាក់ទងលោកសង្ឃនៅវត្តក្រចេះ ដើម្បីឲ្យយន្តហោះមកទម្លាក់គ្រាប់បែកកម្ទេចស្ពានថ្ម នៅអូរដែកដូន និងទម្លាក់លើប្រជាជននៅជិតៗនោះ។

នៅខែមករា ឆ្នាំ១៩៧២ យើងបានអនុវត្តតាមផែនការ។ ខ្ញុំបានធ្វើឲ្យខូចឡាន មួយគ្រឿង និងបង្ហូរអំបិលចេញពីក្នុងឡានអស់៥០០គីឡូក្រាម។ ចំណែក មិត្តកង បានទៅទាក់ទងព្រះសង្ឃនៅវត្តក្រចេះ ផ្តល់សញ្ញាទៅយន្តហោះទម្លាក់គ្រាប់បែក ធ្វើឲ្យខូចស្ពានថ្មអូរដែកដូនចំនួន២ និងស្លាប់ប្រជាជនមួយចំនួន។

នៅខែតុលា ឆ្នាំ១៩៧៣ បងឃួន បានហៅខ្ញុំឲ្យទៅជួបគាត់នៅចម្ការកៅស៊ូគីឡូម៉ែត្រលេខ១០ ខេត្តកំពង់ចាម។ ជួបគ្នានៅពេលនោះបងហើយគាត់បានបញ្ចូលខ្ញុំជា សេ.អ៊ី.អា.។ នៅខែធ្នូឆ្នាំ១៩៧៣មិត្តកងបានហៅខ្ញុំទៅប្រជុំនៅក្រុងក្រចេះជាមួយ មិត្តខន និងមិត្តសៃ។ ខ្លឹមសារប្រជុំគឺបន្តសកម្មភាពពង្រឹងកម្លាំង សេ.អ៊ី.អា. បំផ្លាញសម្ភាររបស់អង្គការ បំផុសប្រជាជនឲ្យខ្លាចក្នុងការធ្វើសង្គ្រាម កាត់បន្ថយការដាំដុះ និងរៀបចំអង្គរដើម្បីលក់ឲ្យឃួន ឈ្មោះ អឹក។ អឹក គឺជាខ្សែរបស់មិត្តកង និងខ្ញុំ។ ខ្ញុំកសាងកម្លាំងបានចំនួន១០នាក់មានឈ្មោះ៖ ស៊ុន ថន (ប្រធានពាណិជ្ជកម្មតំបន់១០៥), ថា (សមាជិកពាណិជ្ជកម្មតំបន់១០៥), ឈ្មោះ ញូន (អនុភ័ស្តុភារយោធាតំបន់១០៥), នឿន (ប្រធានទទួលស្រែនៅក-១៦), ឡាន (ប្រធានចិញ្ចឹមគោ និងក្របីនៅក-១៦), ឡាំ (សមាជិកផ្នែកចិញ្ចឹមគោ និងក្របីនៅក-១៦), ប៊ុន (កងការពារ ភុន អនុលេខាតំបន់១០៥), ដែង (យុទ្ធជនការពារ ភុន អនុលេខាតំបន់១០៥), វ៉ាន (ទទួលខុសត្រូវឡាននៅមន្ទីរ១០៥) និង ស៊ី យុទ្ធជនបើកឡាននៅមន្ទីរតំបន់១០៥។

នៅខែវិច្ឆិកា ឆ្នាំ១៩៧៤ មិត្តកង បានហៅខ្ញុំទៅប្រជុំនៅក្រចេះ ពេលនោះខ្ញុំឃើញ បងខាំភូន (អនុលេខាតំបន់១០៥) ទៅប្រជុំដែរ។ មិត្តកង បានប្រាប់ទៅ បងខាំភូន ឲ្យទាក់ទងជាមួយ ខន និង សៃ ដើម្បីរួមគ្នាធ្វើសកម្មភាពកសាងកម្លាំងស្ទួលបំផ្លាញអង្គការ។

នៅខែមករា ឆ្នាំ១៩៧៥ មិត្តកង បានហៅ ខ្ញុំ, កង, សៃ និង សុខន ទៅប្រជុំនៅក្រចេះ។ នៅក្នុងការប្រជុំនោះ មិត្តកង បានប្រាប់អំពីផែនការ ដែលអង្គការជិតវាយចូលទីក្រុងភ្នំពេញ។ ប្រសិនបើវាយបែកភ្នំពេញ មិត្តទាំងអស់ត្រូវប្រមូលថ្នាំពេទ្យ, ក្រណាត់ និងសម្ភារផ្សេងៗទុកឲ្យបានច្រើន ដើម្បីត្រៀមធ្វើសង្គ្រាម ជាមួយបដិវត្តន៍នៅថ្ងៃខាងមុខ។ ក្រោយពីបានទទួលផែនការរួចហើយ ខ្ញុំបានទៅប្រាប់អ្នកទាំង១០នាក់ដែលខ្ញុំធ្លាប់បានអប់រំ។ ប៉ុន្តែជាអកុសលខ្ញុំមិនបានអនុវត្តផែនការនោះទេ ព្រោះនៅថ្ងៃរំដោះភ្នំពេញខ្ញុំត្រូវឡានបុកបាក់ស្មងជើងម្ខាង និងត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យអស់រយៈពេល១ឆ្នាំទើបជើងរបស់ខ្ញុំអាចដើរបាន។

នៅឆ្នាំ១៩៧៦ ខ្ញុំធ្វើការទាក់ទងជាមួយ បងខាំភូន នៅមន្ទីរ១០៥។ ខែកុម្ភៈ ឆ្នាំ១៩៧៦ បងខាំភូន បានហៅខ្ញុំទៅប្រជុំនៅមន្ទីរក-១៦ ស្ថិតនៅក្នុងមន្ទីរពាណិជ្ជកម្មតំបន់១០៥ ហើយអ្នកចូលរួមមាន ៖ ស៊ុន ជន (ប្រធានពាណិជ្ជកម្មតំបន់១០៥), ឡាប់ (អនុប្រធានពាណិជ្ជកម្មតំបន់១០៥), ថា និងខ្ញុំ។ ខាំភូន បានលើកផែនការឲ្យបំផ្លាញបក្ស និងបំផុសប្រជាជនឲ្យប្រឆាំងមាគ៌ាកសាងប្រទេសរបស់បក្ស។ មិត្ត ស៊ុន ជន ជាអ្នកចែកសម្ភារ ដោយធ្វើយ៉ាងណាត្រូវចែកមិនឲ្យគ្រប់គ្រាន់ដល់ប្រជាជន ដើម្បីធ្វើឲ្យស្ទះដល់ការបង្កបង្កើនផលរបស់អង្គការ។ នៅខែសីហា ឆ្នាំ១៩៧៦ បងខាំភូន បានហៅខ្ញុំ និងឈ្មោះ ញូន ទៅជួបនៅមន្ទីរក-១៦ ពេលនោះប្រពន្ធរបស់បងខាំភូន ឈ្មោះ ឡាប់ ក៏នៅជាមួយដែរ។ នៅក្នុងអង្គប្រជុំ ខាំភូន លើកឡើងដោយបានស្នើ មិត្តញូន និងប្រពន្ធរបស់គាត់ធ្វើសកម្មភាពនៅក្នុងមន្ទីរ គឺដឹកនាំកម្លាំងផ្នែកដេរ កុំឲ្យគាត់ដេរបានលឿនធ្វើឲ្យស្ទះការងារបដិវត្តន៍ ព្រោះពេលនេះអង្គការត្រូវការសម្លៀកបំពាក់ខ្លាំងណាស់។

នៅខែឧសភា ឆ្នាំ១៩៧៧ បងឡាំង បានចាត់តាំងខ្ញុំឲ្យទាក់ទងជាមួយមន្ទីរពាណិជ្ជកម្មកណ្ដាល ដោយយកសត្វដំរីទៅដូរជាមួយសត្វសេះ យកមកចិញ្ចឹមវិញ។ ខ្ញុំបានធ្វើដំណើរតាមការណូតជាមួយឈ្មោះ ដារ។ នៅពេលខ្ញុំទៅដល់មន្ទីរពាណិជ្ជកម្មភូមិភាគកណ្ដាល ខ្ញុំបានជួបជាមួយឈ្មោះ ជ័យ ជាប្រធានមន្ទីរពាណិជ្ជកម្ម។ ការជួបគ្នាលើកដំបូងរវាងខ្ញុំ និងឈ្មោះជ័យ យើងបានស្រុះស្រួលគ្នាដូរដំរី១០ក្បាល ជាមួយសេះ៣០ក្បាល។ ក្រៅពីដោះដូរ ខ្ញុំនិងជ័យបានទាក់ទងគ្នារឿងដោះដូរសម្ភារក្រៅផ្លូវការ។ នៅចុងខែមិថុនា ឆ្នាំ១៩៧៧ ខ្ញុំបានទៅទទួលសម្ភារនៅភ្នំពេញដោយធ្វើដំណើរតាមផ្លូវទឹកទន្លេមេគង្គ។ ពេលត្រឡប់មកវិញខ្ញុំបានទៅជួបមិត្តជ័យ នៅមន្ទីរពាណិជ្ជកម្មភូមិភាគកណ្ដាល ខេត្តកំពង់ចាម។ ខ្ញុំបានហូបបាយជាមួយជ័យ ហើយបាននិយាយអំពីស្ថានភាពប្រជាជនតាមតំបន់រៀងខ្លួន។ ជ័យ បាននិយាយប្រាប់ខ្ញុំអំពីប្រជាជនហូបតែក្លូចធ្វើឲ្យហើមខ្លួន ជាពិសេសប្រជាជននៅក្នុងតំបន់៤១ មានការខ្វះខាតជាងគេ។ ក្រោយពីជជែកគ្នា យើងទាំងពីរនាក់បានយល់គ្នាច្រើនក្នុងការធ្វើសកម្មភាពក្បត់អង្គការ។ បន្ទាប់មក ខ្ញុំក៏បានរាយការណ៍ប្រាប់ បងខាំភូន នៅមន្ទីរក-១៦។ នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៧៧ មិត្តជ័យ ឲ្យខ្ញុំទៅជួបគាត់ម្ដងទៀត ដើម្បីនិយាយអំពីផែនការក្នុងការកម្ទេចអង្គការ។ នៅពេលខ្ញុំទៅដល់មន្ទីរ ខ្ញុំមិនបានឃើញគាត់ទេហើយទំនាក់ទំនងរវាងខ្ញុំ និង ជ័យ បានដាច់ចាប់ពីពេលនោះមក។

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៧៧ បងខាំភូន បានសរសេរសំបុត្រទៅឈ្មោះ អន់ គយ ឲ្យខ្ញុំបានចូលរួមក្នុងការប្រជុំនៅក្នុងមន្ទីរក-១៦ដែលប្រព្រឹត្តនៅថ្ងៃទី១៨ខែកញ្ញាឆ្នាំ១៩៧៧។ នៅក្នុងអង្គប្រជុំ ខាំភូន បានលើកឡើងដោយស្នើមិត្តទាំងអស់ឲ្យរៀបចំអាវុធនៅកន្លែងរៀងខ្លួនរួចយកមកទុកនៅកន្លែងរបស់គាត់ នៅមន្ទីរក-១៦វិញ។ ក្នុងការប្រមូលអាវុធនេះ គឺយើងមានផែនការក្នុងការរត់ទៅប្រទេសយួន ព្រោះសភាពការណ៍បដិវត្តន៍បច្ចុប្បន្នកាន់តែមានការតឹងរ៉ឹង។ ផែនការនេះ ខាំភូន បានសម្រេចឲ្យឈ្មោះ មិត្តញូន, ប៊ុន, នឿន, ឡាង, ឡាំង ដឹកនាំកម្លាំងរត់ចូលទៅដីយួន។ ផ្លូវដែលត្រូវធ្វើដំណើរគឺតាមផ្លូវភូមិស្រែព្រះ ឃុំស្រែព្រះ ស្រុកកែវសីម៉ា។ ពីរថ្ងៃក្រោយយើងបានទទួលដំណឹងថា អង្គការចាប់បាន និងបាញ់សម្លាប់អស់១៣នាក់។ ដូច្នេះកម្លាំងដែលបានចូលដីយួនមានតែ៤នាក់ប៉ុណ្ណោះ ហើយអ្នកទាំងនោះ ក៏មិនដែលទំនាក់ទំនងមកយើងវិញដែរ។ ក្រោយព្រឹត្តិការណ៍នេះបានកើតឡើង អង្គការបានចាត់តាំង ខាំ ដែលត្រូវជាកូនរបស់ បងខាំភូន ឲ្យដើររកចាប់ក្រុមដែលបានរត់ចូលដីយួន។ មិត្តខាំ មិនបានអនុវត្តតាមអង្គការទេ ហើយថែមទាំងធ្វើសកម្មភាពប្រឆាំងវិញ។ ដូច្នេះអង្គការបានសម្រេចចាប់ខ្លួន ខាំ នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៧។ ក្រោយមកបងឡាំង បានដកខ្ញុំពីក្រចេះឲ្យទៅក្ដាប់សភាពការនៅពាណិជ្ជកម្ម១០៥។ ពេលនោះខ្ញុំក៏បានជួបជាមួយមិត្តស៊ិន ថន និង បងខាំភូន។ នៅពេល បងខាំភូន ជួបខ្ញុំ គាត់ក៏បានប្រាប់ខ្ញុំថា គាត់លែងបានដឹកនាំខ្ញុំប្រជុំទៀតហើយ ដូច្នេះខ្ញុំត្រូវដឹកនាំប្រជុំជំនួសគាត់ បន្ទាប់ពីគាត់ត្រូវបានអង្គការដកទៅនៅភ្នំពេញ។ ខាំភូន បាននិយាយបន្តទៀតថា រឿងអង្គការបម្រុងដកគាត់នេះប្រាកដជាចាប់គាត់ហើយ ចំណែករឿងរ៉ាវរបស់យើងលើកមុនប្រាកដជាបែកការណ៍មិនខាន។ គាត់បន្តថា ពេលណាមានឱកាសល្អប្រាកដជារាយ បងឡាំង ព្រោះរឿងកូនគាត់ត្រូវអង្គការចាប់ និងបែកការណ៍មកពី បងឡាំង។ ថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៧៧ បងខាំភូន ត្រូវអង្គការដកមកនៅភ្នំពេញ។ ពេលខ្ញុំមកភ្នំពេញ ខ្ញុំបានដំណឹងថា បងខាំភូន រាយបងឡាំង ស្លាប់នៅមន្ទីរពាណិជ្ជកម្មតំបន់១០៥ នៅភ្នំពេញ។ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៧ អង្គការចាប់ខ្ញុំតែម្ដង។ **ដារ៉ារដ្ឋ មេត្តា**

***កំណត់ចំណាំ៖*** *រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហមដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយរបស់ ដាន យោន ហៅ ដួន ពិតប្រាកដណាទេ។*

# ការសម្តែងល្ខោននិយាយរឿង «ទម្លាយភាពស្ងៀមស្ងាត់» នៅខេត្តបាត់ដំបង

មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងអង្គការអម្រឹតាសិល្បៈ នឹងរៀបចំសម្តែងល្ខោននិយាយរឿង «ទម្លាយភាពស្ងៀមស្ងាត់» នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ នៅវិទ្យាស្ថានគរុកោសល្យបាត់ដំបង ចាប់ពីវេលាម៉ោង៥រសៀលតទៅ។ ដំណឹងនេះចាត់ទុកជាការអញ្ជើញដល់លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត គរុសិស្ស គរុនិស្សិត អ្នកស្រាវជ្រាវ មន្ត្រីរាជការ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល យាយ តា អ៊ុំ ពូ មីង ចូលរួមទស្សនាល្ខោននេះជាមួយយើងខ្ញុំដោយមិនតម្រូវឲ្យបង់ប្រាក់ឡើយ។

ខេត្តបាត់ដំបង គឺជាខេត្តចុងក្រោយនៃការម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» នៅក្នុងឆ្នាំ២០១៩នេះ បន្ទាប់ពីការសម្តែងនៅទីក្រុងភ្នំពេញ ខេត្តតាកែវ ខេត្តកំពង់-ចាម និងខេត្តព្រៃវែង កន្លងមក ដើម្បីជាការចែករំលែកដល់មនុស្សគ្រប់ជំនាន់ឲ្យស្វែងយល់ពីបទពិសោធន៍របស់អ្នករស់រានមានជីវិតនៅក្នុងរបបខ្មែរក្រហម ដែលត្រូវបានលាតត្រដាងដើម្បីការចងចាំ ការផ្សះផ្សា កសាងសន្តិភាព និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា នាពេលអនាគត។

ល្ខោននិយាយរឿង «ទម្លាយភាពស្ងៀមស្ងាត់» ជាសាច់រឿងល្ខោនដែលដកស្រង់ចេញពីរឿងរ៉ាវពិតរបស់អ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហម តាមរយៈការស្រាវជ្រាវ និង សម្ភាសន៍ជាមួយជនរងគ្រោះ និងជនដៃដល់នៅតាមភូមិឃុំនានាក្នុងប្រទេសកម្ពុជា។ អ្នកនិពន្ធជនជាតិហូឡង់ ២រូបគឺ អ្នកស្រី អាន់ម៉ារី ព្រីនស៍ និងអ្នកស្រី ណាន់ វ៉ាន់ ហូត សហការជាមួយ អម្រឹតាសិល្បៈ ដោយមានការជ្រោមជ្រែង លើកិច្ចការស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានផលិតល្ខោននេះឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអនុវត្តដំណើរការផ្សះផ្សា និងចាប់ផ្តើមស្តារសង្គមកម្ពុជាដ៏ខ្ទេចខ្ទាំឡើងវិញ។ អង្គការអម្រឹតាសិល្បៈ នឹងសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់»

ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ត្រូវបានសម្តែងនៅតាមបណ្តាភូមិឃុំមួយចំនួននៅក្នុងប្រទេសកម្ពុជា តាំងពីឆ្នាំ២០០៨ រហូតមកដល់ពេលបច្ចុប្បន្ន។ បើគិតមកដល់សព្វថ្ងៃ ប្រវត្តិនៃការកកើតល្ខោននិយាយនេះ មានអាយុកាល១០ឆ្នាំគត់។ នៅក្នុងឆ្នាំ២០១៨ ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ត្រូវបានធ្វើបច្ចុប្បន្នភាព ដោយដាក់បញ្ចូលឈុតថ្មីមួយទៀត ដែលបន្ថែមលើខ្លឹមសារចាស់ទាក់ទងនឹងដំណើរការស្វែងរកយុត្តិធម៌របស់សាលាក្តីខ្មែរក្រហម ដែលហៀបនឹងបញ្ចប់នាពេលអនាគតដ៏ខ្លីខាងមុខ។

ក្នុងរយៈពេល១០ឆ្នាំនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា និងអម្រឹតាសិល្បៈ ដោយមានការសហការយ៉ាងល្អពីក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចកិច្ចការជាច្រើន ហើយកិច្ចការទាំងនេះបានបែងចែកជា៣ដំណាក់កាលគឺៈ

ដំណាក់កាលទី១ គឺជាដំណាក់កាលនៃការតែងនិពន្ធ ដោយបានចាប់ផ្តើមនៅក្នុងខែមករា ឆ្នាំ២០០៨ នៅពេលដែលអ្នកនិពន្ធនិងអ្នកសសេរទំនុកល្ខោន អាណាម៉ារី ព្រីនស៍ និងណានវ៉ាន់ហូតបានធ្វើការស្រាវជ្រាវអំពីដំណើរការនៃការផ្សះផ្សានៅក្នុងប្រទេសកម្ពុជា តាមរយៈការអញ្ជើញរបស់អង្គការអម្រឹតាសិល្បៈ និងមានការសម្របសម្រួលក្នុងការចុះទៅសម្ភាសន៍ជាមួយជនរងគ្រោះ និងជនដៃដល់ពីអ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

តាមរយៈការស្រាវជ្រាវ និងចុះសម្ភាសន៍ជនរងគ្រោះ និងជនដៃដល់ អ្នកនិពន្ធនិងអ្នកសរសេរទំនុកល្ខោនបានតាក់តែងនូវសាច់រឿងចំនួន៧ រៀបរាប់អំពីជីវភាពប្រចាំថ្ងៃរបស់អ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហម ដែលបង្ហាញឲ្យឃើញពីភាពឈឺចាប់ និងភាពមិនចេះទ្រុឌទ្រោមក្នុងការប្រឈមទៅនឹងបទពិសោធន៍នានាស្ថិតក្រោមរបបខ្មែរក្រហម។

បន្ទាប់ពីការបញ្ចប់ការតែងនិពន្ធ និងហាត់សមការសម្តែងជាច្រើនម៉ោង ការសម្តែងដំបូងបង្អស់ ត្រូវបានធ្វើឡើងនៅក្នុងមជ្ឈមណ្ឌលពិព័រណ៍ជាតិ ក្នុងរាជធានីភ្នំពេញ នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៩គឺក្នុងសប្តាហ៍តែមួយជាមួយនឹងការចាប់ផ្តើមសវនាការ ជាផ្លូវការរបស់សាលាក្តីខ្មែរក្រហម។ បន្ទាប់ពីបញ្ចប់ការសម្តែងលើកដំបូងនេះ ការសម្តែងជាសាធារណៈលើកក្រោយៗទៀត គឺត្រូវបានបន្តទៅកាន់ខេត្តមួយចំនួននៅប៉ែកខាងត្បូងប្រទេសកម្ពុជា។

តាមរយៈការសម្តែងរបស់តួសម្តែងនៅក្នុងសាច់រឿងទាំង៧ អារម្មណ៍សោកស្តាយ ភ័យខ្លាច ទុក្ខព្រួយ ភ័ន្តច្រឡំ និងក្តីសង្ឃឹម ត្រូវបានបង្ហាញនៅចំពោះមុខទស្សនិកជនទាំងអស់ ដែលនេះសបញ្ជាក់ឲ្យឃើញពីការព្យាយាមរបស់ជនរងគ្រោះនៃរបបខ្មែរក្រហម ប្រឈមមុខនឹងរឿងហេតុទាំងឡាយក្នុងរបបខ្មែរក្រហម និងឆ្លុះបញ្ចាំងពីការផ្សះផ្សាជាមួយនឹងអតីតកាលដែលប្រកបដោយបញ្ហា។

នៅក្នុងដំណាក់កាលទី១នេះ ការសម្តែងជាសាធារណៈតាមបណ្តាខេត្តលើកដំបូងបង្អស់ បានប្រព្រឹត្តទៅប្រកបដោយជោគជ័យយ៉ាងធំធេង តាមរយៈការចូលរួមទស្សនាពីប្រជាជន សិស្ស គ្រូបង្រៀន និងប្រជាជននៅក្នុងសហគមន៍ចំនួនប្រមាណ៧ពាន់នាក់ និងការផ្សាភ្ជាប់ពីសាច់រឿងសម្តែងទៅនឹងប្រវត្តិឆ្លងកាត់របបខ្មែរក្រហមរបស់អ្នកទស្សនា។

គោលបំណងរបស់យើង គឺដើម្បីឲ្យប្រជាជនកម្ពុជាគ្រប់វ័យទទួលបានប្រយោជន៍ពីស្នាដៃនេះ តាមរយៈការប្រឈមចំពោះបញ្ហានានាទាក់ទងនឹងប្រវត្តិសាស្ត្រដ៏សោកសង្រេងដែលបានកើតមានឡើង តាមរយៈមជ្ឈដ្ឋានប្រកបដោយសុវត្ថិភាព ភាពច្នៃប្រឌិត និងសេចក្តីភ្ញាក់រឭក។ ប្រជាជនកម្ពុជាទទួលបានឱកាសក្នុងការលើកឡើងអំពីបទពិសោធន៍ផ្ទាល់ខ្លួន នៅមុននិងក្រោយពេលនៃការសម្តែងល្ខោន ដែលមានការសម្របសម្រួលពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ សកម្មភាពនេះក៏ផ្តល់ជាជំនួយដល់ប្រជាជនកម្ពុជាក្នុងការស្វែងរកវិធីសាស្ត្រសម្រាប់បំពេញដំណើរការនៃការផ្សះផ្សា និងព្យាបាលរបួសផ្លូវចិត្ត ក៏ដូចជាវិធីសាស្ត្រដទៃទៀតក្នុងការបន្តដំណើរឆ្ពោះទៅមុខទៀត។

ឆ្លើយតបទៅនឹងប្រតិកម្មដ៏វិជ្ជមាននៅក្នុងដំណាក់កាលទី១ ដំណាក់កាលទី២បានចាប់ផ្តើមឡើងជាមួយនឹងការរៀបចំការសម្តែងជាសាធារណៈនៅក្នុងខេត្តកំពត និងខេត្តតាកែវ នាខែកុម្ភៈ ឆ្នាំ២០១០។ ជាថ្មីម្តងទៀត ប្រជាជនកម្ពុជារាប់ពាន់អ្នកបានចូលទស្សនាការសម្តែងនេះ។ ប្រជាជនជាច្រើនបានចូលរួមនៅក្នុងកិច្ចពិភាក្សានៅក្រោយការសម្តែងបានបញ្ចប់ ដោយបានរៀបរាប់ពីទុក្ខវេទនា ការជ្រើសរើសខុសឬធ្វើមិនគប្បីរបស់ខ្លួននៅក្នុងអំឡុងពេលនៃរបប ប៉ុល ពត ជាដើម។ ចំណែកឯក្មេងៗជំនាន់ក្រោយ បានលើកឡើងជាសំណួរផ្សេងៗមកកាន់យើងខ្ញុំ។

ការសម្តែងលើកនេះ បានប្រព្រឹត្តទៅស្របពេលជាមួយនឹងការចាប់ផ្តើមសំណុំរឿង០០២ ដែលគឺជាសវនាការលើកទី២របស់សាលាក្តីខ្មែរក្រហម ពាក់ព័ន្ធនឹងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់រានមានជីវិត។ ដោយសារសារសំខាន់នៃសំណុំរឿង០០២ និងការយល់ឃើញអំពីតម្រូវការក្នុងការបញ្ជ្រាបទៅកាន់ប្រជាជនកម្ពុជា ដែលរស់នៅបែកខ្ញែកគ្នា (និងប្រជាជនស្ថិតនៅតំបន់ដាច់ស្រយាល) មជ្ឈមណ្ឌលឯកសារកម្ពុជាបានស្នើឲ្យអ្នកស្រី អាណាម៉ារី ព្រីនស៍ សរសេរជាឯកសារ និងថតល្ខោននេះជាសំឡេង ដើម្បីចាក់ផ្សាយតាមវិទ្យុ។ ការផ្សាយល្ខោននិយាយ «ទម្ងាយភាពស្ងៀមស្ងាត់» នៅតាមវិទ្យុជារៀងរាល់ថ្ងៃ បានចាប់ផ្តើមនៅក្នុងខែមេសា ឆ្នាំ២០១០ និងបន្តរហូតមក។

ល្ខោននិយាយ «ទម្ងាយភាពស្ងៀមស្ងាត់» ទទួលបាន

ផលប្រយោជន៍ ព្រមទាំងចូលរួមចំណែកដល់ភាពចំបាច់ដ៏វិសេសវិសាលក្នុងការបញ្ចប់ភាពស្ងៀមស្ងាត់ ស្របពេលដែលល្ខោននេះ ក្លាយជាមធ្យោបាយក្នុងការលើកឡើងអំពីកិច្ចពិភាក្សាដើម្បីចាប់ផ្តើមការផ្សះផ្សា។ ទោះបីជាបញ្ហាទាក់ទងនឹងសាលាក្តីខ្មែរក្រហមពុំត្រូវបានលើកឡើងនៅក្នុងល្ខោននេះក្តី ក៏កម្មវិធីនៅមុនពេលនិងក្រោយពេលសម្តែងមានរួមបញ្ចូលពីការពិភាក្សាដោយផ្អែកលើឥទ្ធិពលនៃសាលាក្តីខ្មែរក្រហម ដោយបានលើកឡើងអំពីតួនាទីរបស់សាលាក្តីខ្មែរក្រហម ក្នុងការស្តារជំនឿទុកចិត្តចំពោះប្រព័ន្ធច្បាប់ និងយុត្តិធម៌។

ថ្វីបើល្ខោននិយាយរឿង «ទម្ងាយភាពស្ងៀមស្ងាត់» ពុំមែនជាការគាត់តែងនិពន្ធ ដើម្បីស្នើសុំការលើកលែងទោសក្តី ក៏ល្ខោននេះ ត្រូវបានដាក់បញ្ចូលសកម្មភាពរបស់អ្នកដែលប្រព្រឹត្តខុសឆ្គងនៅក្នុងបរិបទមួយនិងបង្ហាញអំពីដំណើរការនិងមូលហេតុដែលកុមារាកុមារី និងយុវជនវ័យក្មេងៗសម្រេចជ្រើសរើសគាំទ្រខ្មែរក្រហម និងការដែលមិនអាចបកត្រឡប់ក្រោយបាននាពេលបន្ទាប់។

ដោយយល់ឃើញថា សាលាក្តីខ្មែរក្រហមបានបន្សល់ទុកនូវមន្ទិលសង្ស័យមួយចំនួន ព្រមទាំងសំណួរថ្មីៗជាច្រើន ដែលតម្រូវឲ្យធ្វើការឆ្លើយតប ដើម្បីអនុវត្តដំណើរការផ្សះផ្សា និងចាប់ផ្តើមស្តារសង្គមដ៏ខ្ទេចខ្ទាំនេះឡើងវិញ អ្នកនិពន្ធពិតជាចង់សាកល្បងរាល់បញ្ហាចោទឡើងនានា ក្នុងការបង្កើតរឿងទម្ងាយភាពស្ងៀមស្ងាត់ ក្នុងទម្រង់ថ្មី ដែលធ្វើការឆ្លើយតបច្បាស់លាស់ជាងមុនទៅកាន់សំណួរស្តីពីកម្មផល និងសាលាក្តីខ្មែរក្រហម។ នេះគឺជាដំណាក់កាលទីពីររបស់ខ្លួន ដែលបានបង្កើតឡើងនៅក្នុងឆ្នាំ២០១៨កន្លងទៅនេះ។

គម្រោងនេះ ដូចគ្នានឹងគម្រោងជាច្រើនទៀតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរ ដែលដើរតួនាទីជាកម្មវិធីស្តីពីការពិត និងការផ្សះផ្សាក្រៅប្រព័ន្ធនៅក្នុងប្រទេសកម្ពុជា។ តាមរយៈការធ្វើឲ្យប្រសើរឡើងនូវល្ខោននិយាយ ដើម្បីឆ្លើយតបទៅនឹងសំណួរនានាដែលបានលើកឡើងអំពីសាលាក្តីខ្មែរក្រហម ក្នុងនោះរួមមានបញ្ហាចម្បងស្តីពីកម្មផលផង មជ្ឈមណ្ឌលឯកសារកម្ពុជា មានបំណងចូលរួមជាមួយទស្សនិកជនទាំងឡាយក្នុងប្រទេសកម្ពុជា ក្នុងការស្វែងរកចម្លើយសម្រាប់សំណួរដ៏ពិបាក ដែលបានលើកឡើងអំពីគុណវិបត្តិនៃសាលាក្តីខ្មែរក្រហម និងត្រិះរិះពិចារណាអំពីបែបផែនផ្សេងៗ ដែលសាលាក្តីខ្មែរក្រហមអាចចូលរួមចំណែកក្នុងដំណើរការនៃការព្យាបាលរបួសផ្លូវចិត្ត និងការផ្សះផ្សានៅកម្ពុជា។ ***សោម ប៊ុនថន***



ទស្សនិកជនកំពុងទស្សនាការសម្តែងល្ខោននិយាយ«ទម្ងាយភាពស្ងៀមស្ងាត់»

# អតីតគណៈស្រុករងស្រុកសំឡូត ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ខ្ញុំឈ្មោះ ណុប ងឹម សព្វថ្ងៃរស់នៅឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ឪពុក របស់ខ្ញុំឈ្មោះ ណុប យី (ស្លាប់កាលពីឆ្នាំ១៩៧៩) និងមានម្តាយឈ្មោះ ប្រាក់ ង៉ែត (ស្លាប់កាលពីពេលថ្មីៗនេះ)។ ខ្ញុំគឺជាកូនទី២ ក្នុងចំណោមបងប្អូនចំនួន៨នាក់ ដែលមានប្រុស៤នាក់ និងស្រី៤នាក់។ ប្តីរបស់ខ្ញុំឈ្មោះ ព្រាប កប។ សព្វថ្ងៃយើងមានកូនចំនួន២នាក់ ប្រុសម្នាក់ និងស្រីម្នាក់។

កាលពីកុមារភាព គ្រួសាររបស់ខ្ញុំមានជីវភាពក្រខ្សត់ណាស់ ដូច្នេះហើយទើបខ្ញុំមិនមាន ឱកាសទៅរៀនសូត្រដូចកុមារដទៃទៀត។ ម្យ៉ាងទៀតខ្ញុំមានភារកិច្ចថែទាំប្អូនៗ ធ្វើការងារនៅផ្ទះ និងដាក់ចាយជ្រូកជាដើម។ ខ្ញុំត្រូវធ្វើការងារទាំងអស់នេះដើម្បីឲ្យបងរបស់ខ្ញុំមានឱកាសទៅរៀន សូត្រដូចសិស្សដទៃទៀត។ រហូតដល់ឆ្នាំ១៩៧២ ខ្ញុំបានចាកចេញពីភូមិកំណើតដើម្បីចូលទៅក្នុង ព្រៃធ្វើជាធ្វើកងទ័ពរំដោះ (ខ្មែរក្រហម) ក្នុងគោលបំណងប្រយុទ្ធប្រឆាំងជាមួយកងកម្លាំង រដ្ឋាភិបាល លន់ នល់ ដើម្បីដណ្តើមអំណាចថ្វាយសម្តេច នរោត្តម សីហនុ វិញ។

កាលពីដំបូង ខ្ញុំនិងប្រជាជន២០នាក់ប៉ុណ្ណោះដែលបានសម្រេចចិត្តចាកចេញពីភូមិទៅធ្វើ ការតស៊ូនៅក្នុងព្រៃ។ យើងបានទៅនៅក្នុងមន្ទីរ១៦០ ដែលមានទីតាំងស្ថិតនៅក្នុងព្រៃ និងភ្នំដំរី រមៀល។ ក្រោយមក បងប្អូនរបស់ខ្ញុំក៏បានចូលរួមជាមួយចលនាតស៊ូបដិវត្តន៍ (ខ្មែរក្រហម) ជាបន្តបន្ទាប់ដូចជារូបខ្ញុំដែរ។ ក្នុងអំឡុងពេលនោះ មន្ទីរ១៦០ បានធ្វើការហ្វឹកហាត់ រៀនសូត្រពីយុទ្ធ សាស្ត្រ ហាត់ពត់លត់ដំ និងបានអប់រំខ្ញុំថា «ប្រសិនបើអ្នកចូលរួមក្នុងចលនាតស៊ូបដិវត្តន៍ហើយ សូមកុំត្រឡប់ទៅផ្ទះវិញ ប្រសិនបើត្រឡប់ទៅវិញ សូមកុំត្រឡប់មកទៀត អ្នកគួរតែនៅរកស៊ីចិញ្ចឹម ឪពុកម្តាយរបស់អ្នកវិញចុះ»។ នៅក្នុងមន្ទីរ១៦០ កាលនោះ មាន សនជាប្រធាន និងជាយុទ្ធនារី ភាគច្រើន។ កាលនៅក្នុងមន្ទីរ១៦០ ខ្ញុំបានជួប តាម៉ុក ជាញឹកញាប់ព្រោះគាត់ដើរធ្វើការ និងបានប្រាប់អ្នកគ្រប់គ្រងថា សូមកុំបង្អត់បាយដល់ក្មេងៗទាំងនេះ ហើយត្រូវតែផ្តល់របបអាហារឲ្យក្មេងៗ ហូបឲ្យឆ្អែតគ្រប់ពេលដើម្បីជៀសវាងកុំឲ្យក្មេងទាំងនេះ រត់ត្រឡប់ទៅផ្ទះវិញ។ កន្លះខែក្រោយមក មន្ទីរ១៦០ ក៏បានផ្លាស់ទីតាំងទៅវត្តទូកដ្ហឹក ដែលជាកន្លែងហ្វឹកហាត់របស់យោធា។ នៅទីនោះ ក៏មានការបង្រៀនពីយុទ្ធសាស្ត្រហាត់លូន ដើរក្រញ៉ាំជើងឆ្កែ (ដើរទប់ខ្លួនកុំឲ្យរអិល) រៀនបាញ់កាំភ្លើង រៀនដោះគ្រាប់កាំភ្លើងជាដើម។ រីឯរបបអាហារវិញ នៅពេលព្រឹកគឺទទួលបានបបរ ហើយពេលថ្ងៃ និងល្ងាចទើបទទួលបានបាយ ប៉ុន្តែមានបាយបន្តិចបន្តួចប៉ុណ្ណោះ។ ចំពោះការហាត់រៀននេះ គឺមានសុទ្ធតែនារី និងមានតែគ្រូបង្រៀនឈ្មោះ ពូ យ៉ាវ និង អ៊ំខែម ប៉ុណ្ណោះជាមនុស្សប្រុស។ នៅអំឡុងពេលដែលហាត់រៀនអង្គភាពទ័ពបានបែងចែកជាពីរក្រុម ដោយមានមួយក្រុមធ្វើជាទាហាន លន់ នល់ និងមួយក្រុមទៀតធ្វើជាទាហានខ្មែរក្រហម។ ពេលនោះ សមាជិកនៅក្នុងអង្គភាពទ័ពក៏ ចាប់ផ្តើមស្រែកព្រមគ្នាថា «មិត្តយើងឡើង ខ្មាំងចុះមកហើយ» ប្រសិនបើមាននរណាម្នាក់ស្រែកខុស ច្បាស់ជានៅពេលល្ងាចថ្នាក់លើនឹងធ្វើការប្រជុំ ដើម្បីកសាងមិត្តនោះថា កុំឲ្យធ្វើដូច្នេះតទៅទៀតនៅថ្ងៃក្រោយ»។

នៅក្នុងព្រៃដំរីរមៀល គឺមានមន្ទីរជាច្រើនដែលតាំងមូលដ្ឋាននៅទីនោះ ហើយយាយ ចែម ក៏មានវត្តមាននៅទីនោះដែរ។ យាយចែម តែងតែចុះធ្វើការអប់រំនៅមូលដ្ឋាន ចំណែក ង តាទិត នៅខាងកងទ័ព និងមានប្រពន្ធឈ្មោះ យាយ គេន ធ្វើការតស៊ូជាសម្ងាត់នៅផ្ទះ។ នៅពេលដែលហ្វឹកហាត់បានរយៈពេលមួយខែ ខ្ញុំក៏ចេញទៅវាយជាមួយកងទ័ពវៀតណាមនៅសមរភូមិតាកែវ ត្រង់ម្តុំខាងជើងថ្នល់រទេះភ្លើង និងមាន

ការដឹកលេណដ្ឋានដើម្បីការពារខ្លួនទៀតផង។ លេណដ្ឋាននីមួយៗមានចំនួនបីនាក់ ដោយយុទ្ធជន និងយុទ្ធនារីត្រូវនៅដាច់ដោយឡែកពីគ្នា មិនអាចលាយឡំគ្នាបានឡើយ។ នាពេលនោះ ខ្ញុំនៅក្នុងកង៤៥ វរក-៤ ដែលមានមិត្ត រុំ គឺជាប្រធាន។ មិត្ត រុំ មកពីស្រុក ១០៦ (ស្រុកអន្លង់វែង)។ ខ្ញុំបានធ្វើការតស៊ូនៅសមរភូមិតាកែវអស់រយៈពេលមួយឆ្នាំ ដល់ក្រោយមក ខ្ញុំបានផ្លាស់ទៅវាយជាមួយកងទ័ពវៀតណាមនៅព្រំដែន (ភ្នំឌិន) ដែលមានកងកម្លាំងយុទ្ធនារីចូលរួមប្រមាណ៣០០នាក់ និងមានមិត្ត ខា (មកពីខេត្តតាកែវ) ធ្វើជាប្រធានគ្រប់គ្រង។ កាលនោះខ្ញុំមានតួនាទីគ្រប់គ្រងកងរយ។

រហូតដល់ខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុងនៅខែមេសា ឆ្នាំ១៩៧៥ តាម៉ុក ប្រធានភូមិភាគនិរតី បានចាត់តាំងខ្ញុំឲ្យទៅនៅស្រែអំបិល (នៅខេត្តកែប) ភូមិភាគនិរតី។ កាលនោះ ខ្ញុំគឺជាអនុប្រធានធ្វើស្រែអំបិល និងមាន យឹម គឺជាប្រធាន។ ការងារធ្វើស្រែអំបិលនាពេលនោះ មានដូចតទៅ៖ កងនារីស្រែអំបិលត្រូវពង្រាបផ្ទៃដីនៃស្រែអំបិលដែលកាលនោះមានទំហំ ៣០ម៉ែត្រ៤ជ្រុង សម្រាប់ស្រែអំបិលនីមួយៗ។ កងនារីស្រែអំបិលត្រូវបុកបង្ហាប់ដីឲ្យរាបស្មើទើបអាច បង្ហូរទឹកសមុទ្រចូល ហើយរយៈពេលមួយអាទិត្យក្រោយមក ទឹកសមុទ្រនឹងរីងខះក្លាយជាអំបិលសម្រាប់យកមកប្រើប្រាស់ និងផ្គត់ផ្គង់ដល់សហករណ៍។ កងនារីស្រែអំបិលសប្បាយរីករាយខ្លាំងណាស់ ហើយខ្ញុំក៏ហូបចុកគ្រប់គ្រាន់ រីឯការងារក៏មិនសូវលំបាកដែរ។ មូលហេតុដែលហូបចុកគ្រប់គ្រាន់ ព្រោះ តាម៉ុក បានប្រាប់ទៅខាងសេដ្ឋកិច្ចថា «អ្នកធ្វើស្រែអំបិលហត់នឿយខ្លាំងណាស់ ដូច្នេះមិនអាចឲ្យហូបបបរបានទេ គឺត្រូវឲ្យហូបបាយ»។ នៅអំឡុងពេលនោះ តាម៉ុក តែងតែ បង្រៀនដល់កងវររបស់ខ្ញុំជានិច្ច ព្រោះគាត់តែងតែយកចិត្តទុកដាក់ដល់យុទ្ធនារី ដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់គាត់។ នៅថ្ងៃមួយវេលាម៉ោង៥ទៀបភ្លឺកងទ័ពវៀតណាមក៏បានវាយសម្រុកចូល មកមន្ទីរស្រែអំបិលរបស់ខ្ញុំ ហើយក៏ចាប់បាននារី វ៉េត ដែលកំពុងដេកលក់លក់ និងដុតទាំងរស់ជាមួយចំបើង។ ពេលនោះ នារី វ៉េត បានស្រែកឲ្យសមាជិកក្រុម ប៉ុន្តែសមាជិកក្រុមទាំងអស់មិនហ៊ានចូលទៅជួយឡើយ។

នៅចុងឆ្នាំ១៩៧៧ ខ្ញុំ និងយុទ្ធនារី១០០នាក់ផ្សេងទៀតបានផ្លាស់ទៅរស់នៅស្រុកសំឡូត ខេត្តបាត់ដំបង។ ខ្ញុំរស់នៅទីនោះបានរយៈពេលបីខែ ក៏សម្រេចចិត្តរៀបការ។ ក្រោយមក តាម៉ុក បានយកជនពិការពីតាខ្មៅ៤០នាក់ មករស់នៅស្រុកសំឡូតដែរ។ ពេលនោះ ខ្ញុំមានតួនាទីជាគណៈស្រុករងស្រុកសំឡូត។ តាម៉ុក បានចាត់តាំងខ្ញុំឲ្យដឹកអង្ករ ១០ឡាន ប្រហុក ៣ឡាន អំបិល ២ឡាន ចាន ពាងទឹក ឆ្នាំង ស្លាបព្រា ដែលមានចំនួនសរុប២០ឡាន ពីខេត្តបាត់ដំបងយកមកស្រុកសំឡូត។ តាម៉ុក បានបែងចែកស្បៀងអាហារ និងសម្ភារទាំងនេះទៅតាមឃុំផ្សេងៗ និងចែកទៅ យុទ្ធនារីៗដែលទើបមកដល់ស្រុកសំឡូតដែរ។ ខ្ញុំនិងប្តីរបស់ខ្ញុំឈ្មោះ (ព្រាប កប) និងបង ឡេង ក៏បានគ្រប់គ្រងនៅស្រុកសំឡូតនេះ។ ពេលមានការប្រជុំម្តងៗនៅខេត្តបាត់ដំបង ខ្ញុំតែងតែធ្វើការផ្លាស់ប្តូរវេណគ្នាជានិច្ចដើម្បីទៅចូលរួមប្រជុំ។ នៅពេលទៅចូលរួមប្រជុំម្តងៗ ខ្ញុំតែងតែបេះក្រូច ពោធិសាត់ដែលដាំនៅក្នុងស្រុកសំឡូត ផ្ញើជូន តាម៉ុក និង អ៊ំទិត នៅបាត់ដំបង។

រហូតដល់ឆ្នាំ១៩៧៩ កងទ័ពវៀតណាម បានសហការជាមួយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានវាយផ្តួលរំលំរបបខ្មែរក្រហម។ នាពេលនោះ ខ្ញុំក៏មិនហ៊ានរស់នៅជាមួយប្រជាជនទៀតដែរ ព្រោះខ្ញុំមានការព្រួយបារម្ភថាខ្លាចប្រជាជនដែលមិនពេញចិត្តខ្ញុំ រាយការណ៍ ប្រាប់កងទ័ពវៀតណាមឲ្យសម្លាប់ខ្ញុំ។ ក្រោយមក ខ្ញុំក៏បានរត់គេចខ្លួនទៅរស់នៅក្នុងជំរំស្រះកែវក្នុងទឹកដីថៃ។ តមកទៀតខ្ញុំបានត្រឡប់មករស់នៅក្នុងភូមិបឹងបេង ក្នុងស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ រហូតដល់ឆ្នាំ២០០០ ខ្ញុំក៏បានសម្រេចចិត្តមករស់នៅស្រុកវាលវែង ខេត្តពោធិសាត់ និងបាន ប្រកបរបរធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃនេះ។

*រី លក្ខិណា*

# ការយល់ខុសរបស់ សារុន បានធ្វើឲ្យគាត់ធ្លាក់ខ្លួនជាពេជ្ឈឃាដ

ឈុតទី៤ ក្នុងចំណោមឈុតទាំង៨ នៃល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» គឺជាឈុតមួយបានឆ្លុះបញ្ចាំងពីរឿងរ៉ាវរបស់និស្សិតម្នាក់ ដែលធ្លាប់ស្រមៃចង់បានពិភពលោកមួយដែលប្រសើរជាងមុនៗ តួអង្គសំខាន់ក្នុងឈុតនេះ គឺឈ្មោះ សារុនៗ គាត់បានយល់ខុសចំពោះរបបខ្មែរក្រហមថា នឹងប្រែក្លាយប្រទេសកម្ពុជាឲ្យមានសុខសន្តិភាព និងល្អប្រសើរជាងមុនៗ ប៉ុន្តែនៅទីបំផុតរាល់អ្វីៗទាំងអស់មិនដូចការគិតរបស់គាត់ឡើយ ហើយបែរជាប្រែក្លាយរូបគាត់ទៅជាពេជ្ឈឃាដ និងអាចធ្វើអ្វីៗទៅតាមតែអង្គការបដិវត្តន៍បញ្ជាតែប៉ុណ្ណោះៗ



សុខ សាខន នៅប្រាសាទនគរបាជ័យ ខេត្តកំពង់ចាម

កាលពីតូច សារុន គឺជាសិស្សល្អម្នាក់នៅឯសាលារៀនក្នុងភូមិៗ ឪពុកម្តាយរបស់សារុន ពិតជាមានមោទកភាពចំពោះគាត់ខ្លាំងណាស់ៗ ឪពុក សារុន តែងតែខិតខំប្រឹងប្រែងធ្វើការដើម្បីឲ្យ សារុន អាចទៅរៀនសូត្របន្តក្នុងសាកលវិទ្យាល័យនៅទីក្រុងភ្នំពេញៗ ឪពុកម្តាយរបស់ សារុន តែងស្រមៃថា សារុន នឹងអាចក្លាយជាសាស្ត្រាចារ្យម្នាក់ៗ កាលណោះ គឺជាជំនាន់ លន់ នល់ ហើយស្ថានភាពមិនល្អទាល់តែសោះៗ នៅក្នុងប្រទេសមានភាពវឹកវរសម្បើមណាស់ៗ និស្សិតដូច សារុន គឺជាអ្នកដែលមានការស្រមើស្រមៃវែងឆ្ងាយ ដោយសារគាត់ចង់បានសង្គមមួយ និងពិភពលោកមួយដែលល្អជាងនេះៗ សារុន និងក្រុមនិស្សិត ក៏បានធ្វើបាតុកម្មដ៏ធំមួយប្រឆាំងរដ្ឋាភិបាល លន់ នល់ ហើយនិស្សិតជាច្រើននាក់ ក៏ត្រូវបានកងកម្លាំងរបស់ លន់ នល់ ចាប់ខ្លួនរួមទាំង សារុន ដែរៗ នៅក្នុងគុក ឆ្មាំបានធ្វើទារុណកម្ម សារុន យ៉ាងខ្លាំង ដោយវាយធ្វើបាប ថែមទាំងឆក់ខ្សែភ្លើង សារុន ទៀតផងៗ ប៉ុន្តែការដែលធ្វើបែបនេះ បានធ្វើឲ្យ សារុន ស្អប់របប លន់ នល់ កាន់តែខ្លាំងឡើងៗ

បន្ទាប់ពីកងកម្លាំងក្នុងរបប លន់ នល់ បានដោះលែង សារុន សារុន ក៏បានរត់ចូលក្នុងព្រៃ គឺពេលនោះហើយដែលគាត់បានជួបជាមួយក្រុមខ្មែរក្រហមៗ ខ្មែរក្រហមធ្វើការប្រយុទ្ធដើម្បីទទួលបាននូវសង្គមមួយដែលល្អប្រសើរជាងនេះ គឺប្រទេសមួយដែលពោរពេញទៅដោយសេរីភាព គ្មានអំពើពុករលួយ ហើយគ្រប់គ្នាមានអាហារហូបចុកគ្រប់គ្រាន់ៗ សារុន គឺពិតជាមានការជឿជាក់ដូចនេះមែនៗ ដូច្នេះ សារុន ក៏ចង់ចូលរួមជាមួយគេឯងដែរទៀត ដោយ សារុន យល់ឃើញថា គាត់មិនអាចបង្ហាញឲ្យខ្មែរក្រហមដឹងថា គាត់គឺជាអ្នកដែលរៀនសូត្របានខ្ពស់នោះទេៗ ពេលនោះ សារុន ក៏ខំប្រឹងធ្វើការដើម្បីឲ្យដៃឡើងគ្រើម និងហាលថ្ងៃដើម្បីឲ្យ

សម្បុរខ្មៅដូចអ្នកស្រែចម្ការ។ សារុន ខំដាក់ខ្លួនធ្វើការឲ្យបានល្អ ប៉ុន្តែនៅទីបញ្ចប់គាត់ធ្វើអ្វីៗតាមតែអង្គការចង់បាន។ សារុន ពួននៅក្រោមផ្ទះប្រជាជនដើម្បីលួចស្តាប់ប្រជាជននិយាយគ្នា និងបានចាប់ប្រជាជនដែលនិយាយអាក្រក់ពីអង្គការ។ សារុន បានធ្វើរឿងអាក្រក់ និងសាហាវជាច្រើន ហើយគាត់លែងគិតដូចមនុស្សទៀតហើយ។ សារុន ប្រៀបដូចជាសត្វឆ្កែមួយក្បាល គឺចាំតែមើលមុខចៅហ្វាយនាយ និងបក់កន្ទុយដោយខ្លាចចៅហ្វាយវាយតែប៉ុណ្ណោះ។

បន្ទាប់ពីបដិវត្តន៍ចប់ សារុន បានវិលត្រឡប់ទៅកាន់ស្រុកកំណើតវិញ ហើយនាពេលឥឡូវនេះគាត់រស់នៅដោយខ្លួនឯង និងមានតួនាទីជាគ្រូបង្រៀននៅសាលាបឋមសិក្សាដែលគាត់ធ្លាប់រៀនកាលពីមុន។ សារុន បានឮប្រជាជននិយាយថាខ្មែរក្រហមបានសម្លាប់ឪពុករបស់គាត់ នៅពេលដែលឪពុករបស់គាត់កំពុងធ្វើការនៅវាលស្រែ។ ឪពុកដ៏ស្លូតបូតរបស់ សារុន ដែលធ្លាប់តែស្រមៃថា សារុន នឹងក្លាយទៅជាសាស្ត្រាចារ្យម្នាក់ ប៉ុន្តែខ្មែរក្រហមបានវាយគាត់រហូតដល់ស្លាប់ ដោយសារតែគាត់ខ្សោយពេកគ្មានកម្លាំងធ្វើការងារឲ្យអង្គការ។ ជួនកាល សារុន ខឹង ហើយជួនកាលក៏ក្រៀមក្រំខួរក្បាលរបស់គាត់ពោរពេញទៅដោយភាពរញ៉េរញ៉ៃ។

សារុន មិនយល់ថាតើប្រទេសទាំងមូលត្រូវបានបោកបញ្ឆោតយ៉ាងដូចម្តេច? តើគាត់ត្រូវបានខ្មែរក្រហមបោកបញ្ឆោតដែរឬយ៉ាងណា? ត្រូវហើយ សារុន បានបន្ទោសខ្មែរក្រហមចំពោះការដែលនាំឲ្យគាត់ដើរផ្លូវខុស ប៉ុន្តែវាក៏ជាកម្មរបស់គាត់ដែរ។ ដូច្នេះ សារុន មិនអាចធ្វើអ្វីបានឡើយក្រៅពីបន្ទោសខ្លួនឯង។ សារុន បានដើរទៅផ្សារ ហើយបានឃើញម្តាយរបស់គាត់ ប៉ុន្តែម្តាយរបស់គាត់មិនមានការរាក់ទាក់មកកាន់គាត់ឡើយ។ ម្តាយរបស់គាត់បែរជាឈ្ងោកមុខចុះ ហើយដើរចេញទៅ។ សារុន ចង់ប្រាប់ម្តាយរបស់គាត់ថា គាត់ត្រូវការម្តាយខ្លាំងណាស់ ប៉ុន្តែម្តាយរបស់គាត់បែរជាខ្មាស់គេដែលមានកូនជាពេជ្ឈឃាដទៅវិញ។ ទោះជាយ៉ាងនេះក្តី ម្តាយរបស់ សារុន ក៏មានមោទកភាពចំពោះ សារុន ខ្លាំងណាស់ដែរ ព្រោះគាត់បានធ្វើជាគ្រូបង្រៀនដ៏ល្អម្នាក់ ព្រមទាំងមិនដែលវាយក្មេងៗ ហើយតែងតែអត់ធ្មត់ពន្យល់ក្មេងៗជានិច្ច។ សារុន ពិតជាចង់ឲ្យម្តាយរបស់គាត់អត់ទោសឲ្យគាត់ខ្លាំងណាស់ ប៉ុន្តែម្តាយរបស់គាត់ពិបាកនឹងលើកលែងទោសឲ្យគាត់។

តើ សារុន មានកំហុសដែរឬទេចំពោះការយល់ខុស និងបានប្រព្រឹត្តកំហុសនៅអំឡុងពេលរបបខ្មែរក្រហម?

ខាងក្រោមនេះ គឺជាកិច្ចពិភាក្សារវាងគរុសិស្សមួយក្រុមនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម និងការចែករំលែកបទពិសោធន៍របស់អតីតយោធាខ្មែរក្រហមដែលធ្លាប់ទទួលរងមនោគមន៍វិជ្ជាខ្មែរក្រហម ៖

**គរុសិស្ស**

គៀត ណាលី អាយុ ២១ឆ្នាំ ឯកទេសជីវវិទ្យា-ផែនដី ឆ្នាំទី១ នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម បានឲ្យដឹងថា «តួអង្គ សារុន មិនមែនជាមនុស្សអាក្រក់ឡើយ ព្រោះការចូលរួមជាមួយអង្គការបដិវត្តន៍ ដោយសារតែគាត់យល់ច្រឡំថា ខ្មែរក្រហមនឹងជួយរំដោះប្រទេសជាតិឲ្យល្អប្រសើរជាងមុន ប៉ុន្តែវាផ្ទុយពីការគិតរបស់គាត់ទាំងអស់។ ខ្មែរក្រហមបានបញ្ជាឲ្យគាត់សម្លាប់ប្រជាជនខ្មែរគ្នាឯង នាពេលនោះគាត់ពិតជាមានការសោកស្តាយខ្លាំងណាស់ចំពោះកំហុសរបស់គាត់»។ ណាលី បានបញ្ជាក់ថា «រាល់កំហុសទាំងនោះ គឺដោយសារតែ សារុន មានការរំពឹងទុកថា ប្រសិនបើគាត់ចូលជាមួយខ្មែរក្រហម គឺគាត់នឹងបានជួយប្រទេសជាតិឲ្យរួចផុតពីស្ថានភាពវឹកវរ ប៉ុន្តែបែរជាខ្មែរក្រហមបានដើរនូវគោលនយោបាយខុសពីការគិតរបស់គាត់ទៅវិញ។ បន្ទាប់ពីបដិវត្តន៍ចប់ សារុន បានផ្លាស់ប្តូរពីពេជ្ឈឃាដ មកជាគ្រូបង្រៀនដ៏ល្អម្នាក់ ព្រមទាំងមិនដែលវាយធ្វើបាប ឬនិយាយមិនល្អទៅកាន់សិស្សមួយណាឡើយ។ ទាំងនេះ បានបញ្ជាក់ឲ្យឃើញថា សារុន មិនមែនជាមនុស្សសាហាវព្រៃផ្សៃនោះទេ ដោយសារតែបរិបទសង្គម និងការចាញ់បោកនយោបាយរបស់ខ្មែរក្រហម បានធ្វើឲ្យគាត់ក្លាយជាមនុស្ស

ផ្សេងទៀត»។

រិទ្ធ ភារក្ស អាយុ១៩ឆ្នាំ ឯកទេសជីវវិទ្យា-ផែនដី ឆ្នាំទី១ នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម បានរៀបរាប់ថា «ប្រសិនបើខ្ញុំស្ថិតនៅក្នុងស្ថានភាពបែបនេះ ខ្ញុំក៏សម្រេចចិត្តធ្វើដូចតួអង្គ សារុន ដែរ ព្រោះនៅពេលដែល សារុនរត់ចូលព្រៃគាត់ក៏បានជួបខ្មែរក្រហមហើយខ្មែរក្រហមបានប្រាប់ថា នឹងជួយរំដោះប្រទេសជាតិឲ្យមានការរីកចម្រើន និងធ្វើឲ្យប្រជាជនមានការហូបចុកគ្រប់គ្រាន់។ យ៉ាងណាមិញ បរិបទសង្គម និងនយោបាយក៏បានបង្ខំឲ្យ សារុន ត្រូវតែសម្រេចចិត្តធ្វើបែបនេះ»។ ភារក្ស បានឲ្យដឹងថា «សារុន គឺមិនមានកំហុសនោះទេ ដោយសារតែគាត់ចង់ជួយប្រទេសជាតិ និងចង់ប្រែក្លាយប្រទេសឲ្យមានសុខសន្តិភាពពេញលេញ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ សារុន ក៏បានក្លាយជាគ្រូបង្រៀនដ៏ល្អម្នាក់ ហើយគាត់ក៏មិនដែលវាយធ្វើបាបសិស្សរបស់គាត់ម្តងណាឡើយ។ ខ្ញុំគិតថា សារុន គឺជាបុគ្គលគំរូដ៏ល្អម្នាក់ ដែលបានយកចំណេះដឹងដែលខ្លួនមានយកទៅចែករំលែកជាមួយសិស្សរបស់គាត់ ហើយជាផ្នែកមួយដែលគាត់បានជួយសង្គមជាតិ តាមរយៈការបង្រៀន។ ខ្ញុំជឿជាក់ថា សារុន ក៏មិនមែនជាមនុស្សសាហាវព្រៃផ្សៃដែរ ព្រោះអត្តចរិតរបស់គាត់គឺស្តែងចេញតាមរយៈការបង្រៀនសិស្ស ដោយគាត់មិនដែលវាយឬធ្វើបាប ជាពិសេសគាត់តែងតែអត់ធ្មត់ចំពោះសិស្សរបស់គាត់ជានិច្ច។

វ៉ូ វ៉ាន់សុខហេង អាយុ១៨ឆ្នាំ ឯកទេសភាសាខ្មែរ ឆ្នាំទី១ នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម បានមានប្រសាសន៍ថា «ដោយសារប្រទេសមានស្ថានភាពវឹកវរ និងមានការផ្សព្វផ្សាយពីការរំដោះប្រទេសឲ្យរួចផុតពីស្ថានភាពទាំងនេះ ដូច្នេះវាគឺជាកត្តាដែលជំរុញឲ្យ សារុន ចង់ចូលរួមជាមួយអង្គការបដិវត្តន៍។ ស្របពេលដែល សារុន កំពុងត្រូវការជំនួយដើម្បីរំដោះប្រទេសជាតិ ជាពិសេស កំពុងតែមានកំហឹងក្នុងចិត្តជាមួយរបប លន់ នល់ ដែលបានធ្វើបាបគាត់នៅអំឡុងពេលដែលគាត់ជាប់គុក»។ វ៉ាន់សុខហេង បានបញ្ជាក់ថា «ខ្ញុំគិតថា រឿងរ៉ាវទាំងអស់នេះមិនមែនជាកំហុសរបស់ សារុន ទេ ព្រោះដោយសារតែសភាពការណ៍ និងកត្តានយោបាយបានជំរុញឲ្យគាត់ធ្វើបែបនេះ។ ប្រសិនបើខ្ញុំគឺជាតួអង្គ សារុន ខ្ញុំក៏ប្រព្រឹត្តនូវសកម្មភាពដូច សារុន ដែរ ព្រោះយើងគ្មានជម្រើសនោះទេ ប្រសិនបើមិនស្តាប់បញ្ជារបស់អង្គការបដិវត្តន៍ យើងក៏មិនអាចគេចផុតពីសេចក្តីស្លាប់ដែរ។

វ៉ាន់សុខហេង បានបន្តថា «បន្ទាប់ពីខ្មែរក្រហមដួលរលំ សារុន បានក្លាយជាគ្រូបង្រៀនដ៏ល្អម្នាក់ មិនដែលវាយធ្វើបាបក្មេងៗ ព្រមទាំងមិនដែលប្រើប្រាស់នូវពាក្យសម្តីគ្រោតគ្រាតទៅកាន់កូនសិស្សរបស់គាត់ឡើយ។ ទាំងនេះ បានឆ្លុះបង្ហាញឲ្យឃើញថា សារុន គឺជាមនុស្សដែលមានចិត្តមេត្តាធម៌ និងចេះយោគយល់ទៅកាន់អ្នកដទៃ ប៉ុន្តែដោយសារតែបរិបទនយោបាយ និងមនោគមន៍វិជ្ជាខ្មែរក្រហមបានប្រែក្លាយរូបគាត់ទៅជាពេជ្ឈឃាដ និងហ៊ានធ្វើអ្វីៗដើម្បីអង្គការ។ វ៉ាន់សុខហេង បានបន្ថែមថា «ប្រសិនបើខ្ញុំគឺជាម្តាយរបស់ សារុន ខ្ញុំនឹងលើកលែងទោសឲ្យ សារុន ព្រោះ សារុន បានភ្ញាក់រឭកពីកំហុសរបស់គាត់ និងបានធ្វើអំពើល្អ។ ម្យ៉ាងទៀត រាល់ការសម្លាប់ប្រជាជនទាំងនេះ គឺដោយសារតែគាត់ជ្រុលខ្លួនហួសពេលទៅហើយ ដូច្នេះមិនអាចគេចវេះបង្គាប់បញ្ជារបស់អង្គការបដិវត្តន៍បានឡើយ។

## ជនរងគ្រោះនៃមនោគមន៍វិជ្ជារបស់ខ្មែរក្រហម

ខ្ញុំបាទឈ្មោះ សុខ សាខន អាយុ៥៧ឆ្នាំ បច្ចុប្បន្នមានទីលំនៅក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម។ កាលខ្ញុំមានអាយុ១៧ឆ្នាំ ខ្ញុំត្រូវបានខ្មែរក្រហមបង្ខំឲ្យធ្វើជាយោធា មានមូលដ្ឋានក្នុងស្រុកបាធាយ ខេត្តកំពង់ចាម ដោយខ្ញុំមិនអាចប្រកែកតវ៉ាឬគេចវេះបានឡើយ។ ក្រោយមក ខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យទៅហ្វឹកហាត់ និងរៀនសូត្រពីយុទ្ធសាស្ត្រយោធានៅសមរភូមិក្រែក ស្ថិតក្នុងខេត្តកំពង់ចាម ភូមិភាគបូព៌ា។ កាលនោះ ខ្ញុំបានរៀនពីការប្រើប្រាស់កាំភ្លើង គ្រាប់

លូន បាញ់បោះទៅតាមអង្គការចាត់តាំង។ មិនត្រឹមតែប៉ុណ្ណោះ ខ្មែរក្រហមក៏បានផ្សៀនខ្ញុំពីមនោគមន៍វិជ្ជាថា «សម្រាប់កងទ័ពខ្មែរក្រហមម្នាក់ គឺត្រូវតែសម្លាប់កងទ័ពវៀតណាមឲ្យបាន៣០នាក់។ ប្រសិនបើកងទ័ពវៀតណាមចាប់បានកងទ័ពខ្មែរក្រហមណាម្នាក់ គឺកងទ័ពនោះត្រូវតែសម្លាប់ខ្លួនដើម្បីជៀសវាងកុំឲ្យបែកការណ៍»។ ខ្ញុំជឿជាក់ និងហ៊ានធ្វើសកម្មភាពបែបនេះមែន សូម្បីតែលះបង់ជីវិតដើម្បីអង្គការក៏ខ្ញុំហ៊ានធ្វើដែរ។ នាពេលនោះ ខ្ញុំបានវាយតទល់ជាមួយកងទ័ពវៀតណាមជាញឹកញាប់ និងតែងនឹកស្រមៃក្នុងចិត្តថា ប្រសិនបើកងទ័ពវៀតណាមចាប់ខ្ញុំបាន ខ្ញុំនឹងសម្លាប់ខ្លួនព្រោះវាគឺជាបញ្ជារបស់អង្គការ។ ប្រសិនបើមិនធ្វើដូច្នេះទេ ខ្មែរក្រហមនឹងធ្វើទារុណកម្មសួរចម្លើយ ដូចជា ដកក្រចកដៃ ដកក្រចកជើងជាដើម។ ខ្ញុំបានធ្វើសកម្មភាពប្រយុទ្ធតទល់ជាមួយកងទ័ពវៀតណាម រហូតដល់របបខ្មែរក្រហមដួលរលំ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ខ្ញុំក៏វិលត្រឡប់មកស្រុកកំណើត ក្នុងខេត្តកំពង់ចាម និងប្រកបរបរធ្វើស្រែចម្ការ។ មួយឆ្នាំក្រោយមក ខ្ញុំក៏ស្ម័គ្រចិត្តចូលបម្រើកងទ័ពក្នុងរបបរដ្ឋកម្ពុជា ដោយមានគោលបំណងចង់ផ្តួលរំលំកងកម្លាំងខ្មែរក្រហមដែលនៅសេសសល់។ ខ្ញុំបានចូលបម្រើកងទ័ពរដ្ឋកម្ពុជាប្រហែលបួនឆ្នាំ ក្រោយមកខ្ញុំក៏សម្រេចចិត្តឈប់ ព្រោះខ្ញុំយល់ថា «ខ្មែរសម្លាប់ខ្មែរ»។ តមកទៀត ខ្ញុំក៏ត្រឡប់មករស់នៅភូមិកំណើតវិញ និងប្រកបរបរធ្វើស្រែចម្ការមកទល់សព្វថ្ងៃនេះ។

ហូ ជុនា



ក្រុមសិល្បករសម្តែងល្ខោននិយាយរឿង ទម្លាយភាពស្ងៀមស្ងាត់

# ភាពយន្តឯកសារឈ្មោះ ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ
# របស់មជ្ឈមណ្ឌលឯកសារកម្ពុជា




បញ្ចាំងរៀងរាល់ថ្ងៃសុក្រ
វេលាម៉ោង១០:០០ ព្រឹក
ទីតាំងនៅវិចិត្រសាលសិល្បៈ
សហសម័យវិទ្យាស្ថានស្លឹករឹត
អគារ H នៃវិទ្យាស្ថានជាតិអប់រំ
(មហាវិថីព្រះសីហនុ
រាជធានីភ្នំពេញ)










វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត ដែលមានទីតាំងស្ថិតនៅក្នុងអគារ H នៃវិទ្យាស្ថានជាតិអប់រំ ជាទីតាំងមួយដើរតួនាទីជាកន្លែងអប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រ និងកេរដំណែលបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងជាកន្លែងដែលដាក់បង្ហាញពីស្នាដៃសិល្បៈ និងវប្បធម៌តាមរយៈការតាំងពិព័រណ៍ ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និងការធ្វើបទបង្ហាញរបស់វាគ្មិននានា។ ជារួម វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត រួមចំណែកដល់ការលើកកម្ពស់និងគាំទ្រដល់វិចិត្រករកម្ពុជាទាំងអស់ ដោយផ្តល់ជូននូវបរិវេណខាងក្នុងបន្ទប់ធំនៃអគារចំណាស់កសាងឡើងក្នុងរជ្ជកាលបារាំង សម្រាប់ការដាក់តាំងពិព័រណ៍ពីកិច្ចការសិល្បៈរបស់ខ្លួន។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង ស៊ាង ចិន្តា ទូរសព្ទលេខ ០២៣ ២១១ ៨៧៥ អ៊ីម៉ែល truthchenda.s@dccam.org

# រឿងរ៉ាវរបស់ មុន សារឿន ហៅ មុន មុត អតីតប្រធានកង អនុសេនាធំនៃកងចល័ត តំបន់៥ ភូមិភាគពាយ័ព្យ

*អស់រយៈពេលប្រហែល ៤០ឆ្នាំកន្លងមកហើយ ដែលប្រជាជនកម្ពុជា បានរួចផុតពីការរស់នៅក្រោមការគ្រប់គ្រងដ៏ឃោរឃៅដែលប្រជាជនទូទៅស្គាល់ថា របបខ្មែរក្រហម។ របបខ្មែរក្រហមបានបន្សល់ទុកឲ្យអ្នករស់រានមានជីវិតនូវការចងចាំដែលមិនអាចបំភ្លេចបាន។ ខាងក្រោមនេះ គឺជាការរៀបរាប់អំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ មុន សារឿន ហៅ មុន មុត អតីតប្រធានកងចល័តនៅស្រុកព្រះនេត្រព្រះ៖*

ខ្ញុំឈ្មោះ មុន សារឿន និងនៅក្នុងរបបខ្មែរក្រហមខ្ញុំឈ្មោះ មុន មុត។ ខ្ញុំមានស្រុកកំណើតនៅ ភូមិស្រះខាងកើត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ ឪពុករបស់ខ្ញុំឈ្មោះ ជូ មុន ស្លាប់ក្នុងឆ្នាំ១៩៧៧ និងម្តាយឈ្មោះ អោ ដែង ស្លាប់ក្នុងឆ្នាំ១៩៩១។ ខ្ញុំគឺជាកូនទី៥ក្នុងចំណោមបងប្អូន៦នាក់ ស្រី២នាក់ និងប្រុស៤នាក់។ កាលនៅកុមារភាព ខ្ញុំបានចូលរៀននៅសាលាស្ថិតនៅក្នុងខេត្តបាត់ដំបងរហូតដល់ថ្នាក់ទី១១។ អំឡុងឆ្នាំ១៩៧៣ ខ្ញុំក៏បានឈប់រៀន និងបានវិលត្រឡប់មករស់នៅជាមួយឪពុកម្តាយដើម្បីជួយធ្វើស្រែចម្ការនៅស្រុកកំណើតវិញ។ ខ្ញុំមិនអាចបន្តការសិក្សានៅសាលាបានទៀតទេ ព្រោះការប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងយោធាខ្មែរក្រហមស្ថិតក្នុងស្ថានភាពកាន់តែខ្លាំងឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ។



មុន សារឿន

ក្នុងឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាចទាំងស្រុង ខ្ញុំទើបតែមានអាយុ ១៨ឆ្នាំតែប៉ុណ្ណោះ ហើយខ្ញុំត្រូវបានខ្មែរក្រហម កេណ្ឌឲ្យទៅលើកទំនប់ស្ថិតនៅការដ្ឋានការងារគោករំចេក។ ក្រោយមក នៅដើមឆ្នាំ១៩៧៦ ខ្ញុំត្រូវបានផ្លាស់ឲ្យទៅធ្វើការងារក្នុងការដ្ឋានមួយផ្សេងទៀតនៅជប់វ៉ារីដែលមានតាឆាងគឺជាប្រធានគ្រប់គ្រងនៅទីនោះ។ អំឡុងពេលនោះ អង្គការបានចាប់ផ្តើមជ្រើសរើសមនុស្សឲ្យចូលយោធា ដោយបានសាកសួរអំពីប្រវត្តិរូបរបស់ប្រជាជនម្នាក់ៗ។ ខ្ញុំត្រូវបានជ្រើសរើសឲ្យធ្វើជានីរសាររបស់ តាឆាង ព្រោះខ្ញុំគឺជាកសិករ និងពុំមានសាច់ញាតិធ្លាប់បម្រើការងារក្នុងរបប លន់ នល់ ឬជាប់និន្នាការពីសង្គមចាស់។ នៅក្នុងតួនាទីធ្វើជានីរសារ តាឆាង បានប្រើខ្ញុំឲ្យកាន់កាំភ្លើង និងធ្វើដំណើរទៅណាមកណាជាមួយគាត់គ្រប់ពេលវេលា រួមទាំងនីរសាររបស់គាត់៣នាក់ផ្សេងទៀត។ ខ្ញុំធ្វើជានីរសាររបស់

តាឆាង រហូតដល់ឆ្នាំ១៩៧៧ នៅពេលដែលគាត់ត្រូវបានអង្គការចាប់ខ្លួន ហើយក្រោយមក ការដ្ឋានដែល តាឆាង គ្រប់គ្រងត្រូវបានអង្គការរំសាយចោល។ បន្ទាប់មក អង្គការបានផ្លាស់ខ្ញុំឲ្យទៅធ្វើការងារនៅក្នុងកងចល័តតំបន់ ៥វិញ។ ប្រធានគ្រប់គ្រងកងចល័តតំបន់៥ឈ្មោះ តាវ៉ាល់។ ខ្ញុំត្រូវបានជ្រើសតាំងឲ្យធ្វើជាប្រធានកងអនុសេនាធំទី៣ ដែលមានតួនាទីគ្រប់គ្រងប្រជាជនថ្មីដែលអង្គការជម្លៀសមកពីភ្នំពេញឲ្យមកធ្វើការនៅការដ្ឋានការងារលើកទំនប់ត្រពាំងថ្ម ស្ថិតនៅក្នុងស្រុកភ្នំស្រុក។ នៅក្នុងកងអនុសេនាធំទី៣ ដែលខ្ញុំបានគ្រប់គ្រងមានសមាជិកប្រហែល ១០០នាក់ ទៅ ១២០នាក់ ដោយម្នាក់ៗត្រូវបានកំណត់ឲ្យជីកដីចំនួន ៣ម៉ែត្រគីបនៅក្នុងមួយថ្ងៃទោះបីជាឈឺយ៉ាងណាក៏ដោយ។ ខ្ញុំគឺជាអ្នកវាស់ដីដើម្បីរាប់ចំនួនម៉ែត្រគីប ដែលអ្នកនៅក្នុងក្រុមរបស់ខ្ញុំម្នាក់ៗបានជីករួចហើយ។ ក្រៅពីនេះ ខ្ញុំក៏ត្រូវជួយរែកដីអ្នកនៅក្នុងកងចល័តរួមដែរ ដើម្បីបង្គ្រប់ទៅតាមចំនួនម៉ែត្រគីបដែលថ្នាក់លើបានកំណត់ឲ្យធ្វើ។ នៅពេលល្ងាចបន្ទាប់ពីហូបបាយរួច ខ្ញុំត្រូវធ្វើរបាយការណ៍ និងស្ថិតិអំពីចំនួនកម្លាំងសរុប ចំនួនអ្នកធ្វើការ ចំនួនអ្នកឈឺ និងចំនួនម៉ែត្រគីបសរុប ដើម្បីរាយការណ៍ទៅឲ្យស្មៀន។ ក្រោយមកទៀត អង្គការចាប់ផ្ដើមបោសសម្អាតក្នុងជួរបក្សកាន់តែខ្លាំង ដោយថ្នាក់លើបានបញ្ជូនមនុស្សពីភូមិភាគនិរតីឲ្យទៅបោសសម្អាតនៅភូមិភាគពាយ័ព្យ។ អង្គការបានចាប់ខ្លួនកម្មាភិបាលជាច្រើនក្នុងភូមិភាគពាយ័ព្យនេះ ក្នុងនោះរួមមាន តាវ៉ាល់ ដែលជាប្រធានកងចល័តតំបន់៥ដែរ។ បន្ទាប់ពីចាប់ខ្លួន តាវ៉ាល់ អង្គការបានបញ្ជូន តាញ៉ាវ ឲ្យមកធ្វើជាប្រធានគ្រប់គ្រងនៅទីនោះជំនួសវិញម្ដង។ ចំណែកឯខ្ញុំមានតួនាទីធ្វើជាប្រធានកងអនុសេនាធំដដែល។ ក្រោយពីគ្រប់គ្រងបានរយៈពេលប្រហែល ៤ខែ តាញ៉ាវ ក៏ត្រូវបានអង្គការចាប់ខ្លួនទៀត។ បន្ទាប់ពី តាញ៉ាវ ត្រូវបានចាប់ខ្លួនពុំមានអ្នកមកគ្រប់គ្រងជំនួសនៅក្នុងកងចល័តតំបន់៥ ទៀតនោះទេ ដែលនេះគឺជាមូលហេតុធ្វើឲ្យកងកម្លាំងលើកទំនប់នៅត្រពាំងថ្មត្រូវបានបែកខ្ញែកគ្នាអស់។ ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យមកធ្វើការងារនៅមន្ទីរពេទ្យអន្លង់សារ គឺជាពេទ្យកងចល័តតំបន់៥។ នៅក្នុងមន្ទីរពេទ្យអន្លង់សារ មានអ្នកជំងឺប្រហែលជា ៥០នាក់ ទៅ ៦០នាក់ ដែលគ្រូពេទ្យដាក់ឲ្យដេកនៅក្នុងរោងប្រក់ស្បូវមួយ។ ខ្ញុំ គឺជាអ្នកចែកសម្ភារផ្សេងៗសម្រាប់អ្នកជំងឺដែលមានដូចជា អង្ករ និងស្ករជាដើម។ ក្រោយពីធ្វើការនៅមន្ទីរពេទ្យអន្លង់សារ បានប្រហែលជា ៣ខែ ទៅ៤ខែ ខ្ញុំក៏ត្រូវអង្គការបញ្ជូនឲ្យមកច្រូតស្រូវនៅភ្នំកំបោរ ដែលមានគ្នាប្រហែល ៣០នាក់ ទៅ ៤០នាក់។ ខ្ញុំច្រូតស្រូវនៅភ្នំកំបោរ បានរយៈពេលប្រហែល១ខែ ក៏ត្រូវផ្លាស់មកធ្វើការនៅកន្លែងថ្មីគឺការដ្ឋាន គោកគី ដែលគ្រប់គ្រងដោយប្រជាជនមកពីភូមិភាគនិរតីឈ្មោះ តាពាល់ និង តាហួត។ ខ្ញុំបានច្រូតស្រូវនៅក្នុងការដ្ឋាននោះរហូតដល់ផុតរដូវប្រមូលផល ទើបកងទ័ពវៀតណាម បានវាយចូលមកដល់នៅពេលដែលខ្ញុំកំពុងធ្វើការ។ ប្រជាជនធ្វើការងារ នៅការដ្ឋានជាមួយខ្ញុំបាននាំគ្នារត់ចូលព្រៃ បន្ទាប់មកបានធ្វើដំណើរឆ្ពោះទៅតំបន់ជួរភ្នំដងរែកដែលមានព្រំប្រទល់ជាប់នឹងប្រទេសថៃ ជាមួយប្រជាជនមកពីភូមិភាគផ្សេងៗទៀត។

បន្ទាប់មកខ្ញុំបានចូលរួមជាមួយចលនាតស៊ូរបស់លោក ស៊ឺន សាន នៅក្នុងព្រៃបន្តទៀត។ ក្នុងអំឡុងពេលនោះ ខ្ញុំមានតួនាទីជាប្រធានកងអនុសេនាតូច ដែលដំបូងមានទីតាំងស្ថិតនៅបន្ទាយអំពិល ប៉ុន្តែក្រោយមកខ្ញុំត្រូវបញ្ជូនទៅនៅជំរំណងចាន់ វិញ។ ខ្ញុំធ្វើជាទាហាននៅទីនោះរហូតដល់ពេល អ៊ុនតាក់ ចូលប្រទេសកម្ពុជា ទើបខ្ញុំធ្វើមាតុភូមិនិវត្តន៍ត្រឡប់មកស្រុកកំណើតវិញ។ ក្នុងឆ្នាំ១៩៨៧ ខ្ញុំបានរៀបការជាមួយនារីម្នាក់ឈ្មោះ នោ គឹមនាង ដែលមានទីកន្លែងកំណើតនៅស្រុក ស្រីស្នំ ខេត្តសៀមរាប។ ក្រោយមកខ្ញុំ និងប្រពន្ធមានកូនចំនួន៥នាក់ ប្រុស ៤ នាក់ ស្រី ១នាក់។ សព្វថ្ងៃនេះខ្ញុំនិងក្រុមគ្រួសារនៅបន្តរស់នៅឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យដដែលដោយប្រកបមុខរបរធ្វើស្រែចម្ការ។

***ដាត ចាន់សុនិតា***

# រឿងរ៉ាវរបស់ប្រជាជនចេញពីសហគមន៍អន្លង់វែង

(តពីលេខមុន)

១១) ម៉ឹក សារ៉េត

នៅពេលខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ ខ្ញុំមានអាយុ១៣ឆ្នាំ រស់នៅភូមិក្លាំងហាយ ឃុំក្លាំងហាយ ស្រុកស្រីស្នំ ខេត្តសៀមរាប។ ឪពុករបស់ខ្ញុំធ្វើស្រែ ភ្ជួររាស់ ចំណែកម្តាយជាអ្នកមើលថែចិញ្ចឹមជ្រូក និងដាក់បាយជ្រូក។ នៅសម័យនោះ ដីស្រែ ដំណាំ មាសប្រាក់ និងសម្ភារផ្សេងៗ ត្រូវបានខ្មែរក្រហមប្រមូលដាក់ជាសម្បត្តិរួមនៅក្នុងសហករណ៍។ មិនថាអ្នកនៅជនបទ ឬអ្នកដែលបានជម្លៀសមកពីភ្នំពេញទេ គឺខ្មែរក្រហមដកហូតយកកម្មសិទ្ធិផ្ទាល់ខ្លួនទាំងអស់។ ការងារនៅសម័យនោះ ខ្មែរក្រហមបានបែងចែកទៅតាមវ័យ។ មនុស្សចាស់ត្រូវធ្វើការនៅក្នុងភូមិ រួមមាន ដាក់បាយជ្រូក ចិតបន្លែ និងដាំបាយជាដើម។ រីឯមនុស្សពេញកម្លាំងត្រូវចូលក្នុងកងចល័ត ធ្វើការងារជីកប្រឡាយ និងលើកទំនប់។ ក្មេងៗ ឃ្វាលគោ និងកាប់ទន្ទ្រានខែត្រធ្វើជី។ បើទោះបីជាប្រជាជនធ្វើការនឿយហត់យ៉ាងណាក៏ដោយ ក៏មិនហ៊ានរអ៊ូរទាំដែរ ព្រោះខ្លាចអង្គការចោទថា ខ្ជិលច្រអូស និងរងទារុណកម្ម។ ម្ហូបអាហារដែលខ្មែរក្រហមបានចែកឲ្យ គឺមនុស្សម្នាក់ទទួលបានបាយមួយវែក និងសម្លមួយចាន រួចហើយយកទៅហូបរួមគ្នា ដោយក្នុងមួយថ្ងៃប្រជាជនទទួលបានអាហារពីរពេល។ ដោយហូបមិនឆ្អែត ប្រជាជនភាគច្រើនបានធ្លាក់ខ្លួនស្គមស្គាំងសល់តែស្បែកដណ្តប់រាងកាយប៉ុណ្ណោះ។

នៅក្នុងរបបខ្មែរក្រហម ប្រជាជនទាំងអស់គឺតម្រូវឲ្យស្លៀកពាក់ខ្មៅ។ កុមារក៏ត្រូវស្លៀកពាក់ខ្មៅ និងប្រដេះដែរ ហើយប្រសិនបើប្រជាជនណាមានខោអាវពណ៌ផ្សេងៗត្រូវយកទៅជ្រលក់ភក់ដើម្បីឲ្យពណ៌ស្រអាប់វិញ។ ខ្ញុំបានដឹង



ក្រុមនិស្សិតស្ម័គ្រចិត្តមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងកំពុងសម្ភាសន៍ប្រជាជននៅក្នុងសហគមន៍អន្លង់វែង ខេត្តឧត្តរមានជ័យ អំពីបទពិសោធន៍ក្នុងសម័យខ្មែរក្រហម

ខ្មែរក្រហមមិនអនុញ្ញាតឲ្យយុវជន និងយុវនារីជ្រើសប្តីប្រពន្ធដោយខ្លួនឯងទេ គឺខ្មែរក្រហមជាអ្នករៀបចំប្តីប្រពន្ធឲ្យអ្នកទាំងនោះ។ ការរៀបការត្រូវបានប្រជាជនទូទៅហៅថា «ការឡើងចាប់អារម្មណ៍» ដោយគ្រាន់តែហៅឈ្មោះយុវជន និងយុវនារីឡើងធ្វើការប្តេជ្ញាចិត្តយកគ្នាជាប្តីប្រពន្ធ និងស្មោះត្រង់បម្រើអង្គការប៉ុណ្ណោះ។ នៅរបបខ្មែរក្រហម មនុស្សដែលស្ថិតនៅក្នុងវ័យដែលអាចរៀបការបាន គឺចាប់ពីអាយុ១៨ឆ្នាំឡើងទៅ។ ប្តីប្រពន្ធខ្លះក៏បានសមនឹងបំណង ឯខ្លះទៀតក៏ខកបំណង ដោយសារអ្នកទាំងពីរមិនបានស្រឡាញ់គ្នាពីមុនមក។ ក្រោយពេលរៀបការរួច បើភាគីណាម្នាក់មិនព្រមរួមរស់នៅជាមួយគ្នាឬមិនចុះសម្រុងគ្នា ហើយកងឈ្លបស៊ើបដឹង ឈ្លបនឹងយកគូនោះទៅសម្លាប់ចោលមិនខាន។ នៅរបបខ្មែរក្រហម មិនមានថ្នាំពេទ្យសម្រាប់ព្យាបាលអ្នកជំងឺឡើយ គឺមានតែថ្នាំខ្មែរបុរាណ ដែលផ្សំពីឫសឈើជាច្រើនមុខ ហើយស្ងួនឲ្យមានរាងជាអាចម៍ទន្សាយ។ ថ្នាំប្រភេទនេះសម្រាប់ព្យាបាលជំងឺពេលចុកពោះ ឬក្តៅខ្លួនបន្តិចបន្តួចប៉ុណ្ណោះ។

ប្រជាជនអាចទាក់ទង និងនិយាយលេងជាមួយសាច់ញាតិ ប៉ុន្តែត្រូវប្រយ័ត្នពាក្យសម្តីមិនត្រូវឲ្យប៉ះពាល់ដល់អង្គការឡើយ បើពុំដូច្នេះទេឈ្លបនឹងយកទៅកសាងមិនខាន។ បងប្អូនឬប្តីប្រពន្ធបើចង់ជួបគ្នាត្រូវតែស្នើសុំប្រធានក្រុមទើបអាចជួបគ្នាបាន។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំមិនត្រូវបានខ្មែរក្រហមជម្លៀសចេញពីភូមិទេ។

នៅចុងឆ្នាំ១៩៧៨ និងដើមឆ្នាំ១៩៧៩ ខ្មែរក្រហមបានសម្លាប់ប្រជាជនកាន់តែច្រើនដោយបានជីករណ្តៅ រួចហើយវាយប្រជាជនទាំងនោះទម្លាក់ចូលក្នុងរណ្តៅនោះតែម្តង។ សំណាងល្អ កងទ័ពរណសិរ្សសង្គ្រោះជាតិកម្ពុជា និងកងទាហានវៀតណាមបានមករំដោះប្រជាជនទាន់ពេលវេលា។ ប្រជាជនកម្ពុជាសប្បាយចិត្តយ៉ាងខ្លាំង ព្រោះបានរួចខ្លួនពីសេចក្តីស្លាប់។ ខ្ញុំបានរស់នៅភូមិដដែល ក្រោយមកដោយសារភាពខ្វះដីធ្លីធ្វើស្រែចម្ការ ខ្ញុំក៏បានផ្លាស់ប្តូរលំនៅមករស់នៅឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ជាមួយនឹងប្តីរហូតមកដល់សព្វថ្ងៃ។

**១២) ណាង ធី**

ខ្ញុំជាកូនកសិករដែលមានជីវភាពមធ្យម។ នៅកំឡុងពេលដែលមានការប្រយុទ្ធគ្នារវាងកងកម្លាំងរំដោះខ្មែរក្រហមជាមួយនឹងកងទ័ពសាធារណរដ្ឋខ្មែររបស់លន់នល់ នៅក្នុងឆ្នាំ១៩៧០ ខ្ញុំរស់នៅជាមួយឪពុកម្តាយ។ នៅក្នុងសម័យនោះប្រជាជន រួមទាំងគ្រួសាររបស់ខ្ញុំ បានរស់នៅជាមួយភាពភ័យខ្លាច ដោយសារការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិក។ គ្រួសារខ្ញុំ និងប្រជាជនតែងនាំគ្នារត់រកទីកន្លែងសុវត្ថិភាព និងបានជីកត្រង់សេដើម្បីលាក់ខ្លួន។

នៅក្នុងកំឡុងសង្គ្រាមរវាងកងកម្លាំងរំដោះខ្មែរក្រហម និងកងទ័ពសាធារណរដ្ឋខ្មែរ ខ្ញុំជាមួយនឹងប្រជាជនដទៃទៀតត្រូវបានកងកម្លាំងរំដោះខ្មែរក្រហមជម្លៀសឲ្យទៅតំបន់ផ្សេងដោយប្រាប់ថាខ្លាចអាមេរិកមកទម្លាក់គ្រាប់បែក។ ពេលនោះប្រជាជនអាចយកកម្មសិទ្ធិរបស់ខ្លួនទៅជាមួយបាន។ ក្នុងពេលជម្លៀសដំបូង ខ្មែរក្រហមបានប្រើពាក្យទន់ភ្លន់ទៅកាន់ប្រជាជន។

ក្រោយមក នៅពេលដែលយោធាខ្មែរក្រហមបានទទួលជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ ខ្ញុំនិងប្រជាជនក៏បានត្រឡប់មកភូមិកំណើតខ្លួនវិញ។ ពេលនោះខ្មែរក្រហមចាប់ផ្តើមបែងចែកប្រជាជនឲ្យធ្វើការតាមកង មានដូចជា កងស្ត្រីចំណាស់ត្រូវមើលថែក្មេងតូចៗ។ កងមនុស្សពេញកម្លាំងត្រូវធ្វើស្រែ លើកភ្លឺ លើកទំនប់ លើករងដាំដំឡូង និងឡើងត្នោត។ ចំណែកក្មេងតូចៗ ត្រូវឃ្វាលគោក្របី រើសលាមកសត្វ និងកាប់ទន្ទ្រានខែត្រមកចិញ្ច្រាំធ្វើជី។ ក្នុងពេលនោះអង្គការបានចាត់តាំងខ្ញុំឲ្យធ្វើពេទ្យនៅក្នុងឃុំដើម្បីព្យាបាលជំងឺ។ អង្គការបានចាត់តាំងចាស់ៗដែលធ្លាប់ផ្សំថ្នាំ ឬស្គាល់ថ្នាំបុរាណ ឲ្យទៅកាប់ឫសឈើដើម្បីកិនលាយបញ្ចូលគ្នា បន្ទាប់មកស្ងួនឲ្យមានរាងដូចអាចម៍ទន្សាយ។ ថ្នាំនេះអាចត្រឹមតែជួយព្យាបាលជំងឺ ផ្តាសាយ ឬគ្រុនក្តៅបន្តិចបន្តួចប៉ុណ្ណោះ។

ដំបូង អង្គការឲ្យប្រជាជនធ្វើការងារស្រាល និងបានអនុញ្ញាតឲ្យសម្រាកហើយបើករបបអាហារឲ្យហូបចុកគ្រប់គ្រាន់ៗ ប៉ុន្តែមិនយូរប៉ុន្មានអង្គការចាប់ផ្តើមរឹតបន្តឹងនិងបង្ខំឲ្យប្រជាជនឲ្យធ្វើការជាទម្ងន់ ហើយមិនឲ្យហូបចុកគ្រប់គ្រាន់ឡើយ។ អង្គការបែងចែកប្រជាជនឲ្យរស់នៅជាសហករណ៍ ធ្វើការងាររួម និងហូបចុករួមៗ រាល់ទ្រព្យសម្បត្តិផ្សេងៗត្រូវទុកជាសម្បត្តិរួមរបស់អង្គការ។ របបអាហារប្រចាំថ្ងៃមានត្រឹមតែបបរ លាយជាមួយដើមចេក ឬគល់ល្ហុងប៉ុណ្ណោះ។ ក្រោយមក ខ្ញុំត្រូវបានអង្គការផ្លាស់ឲ្យមកធ្វើជានីរសារស្រុកវិញ។ ទោះបីខ្ញុំមិនសូវលំបាកដូចប្រជាជននៅក្នុងសហករណ៍ក៏ដោយ ក៏ការងារ និងការហូបចុករបស់ខ្ញុំមិនមានអ្វីខុសប្លែកពីប្រជាជនទាំងនោះដែរ។

ជារឿយៗខ្មែរក្រហមតែងតែធ្វើបាបប្រជាជន ដោយយកប្រជាជនទៅធ្វើទារុណកម្ម និងសម្លាប់ចោល។ ភាគច្រើនអ្នកដែលអង្គការយកទៅសម្លាប់នោះ ត្រូវបានចោទថា ជាទាហាន មន្ត្រីរដ្ឋការ គ្រូបង្រៀន និស្សិត និង បញ្ញវន្ត នៅក្នុងរបប លន់ នល់ និងសង្គមចាស់ៗ ក្នុងចំណោមនោះ សាច់ញាតិរបស់ខ្ញុំក៏ត្រូវបានអង្គការយកទៅសម្លាប់ម្នាក់ដែរ ដោយអង្គការបានចោទថាជាអ្នករដ្ឋការតាមរយៈការឆ្លើយដាក់ពីមិត្តភក្តិស្គាល់គ្នាម្នាក់ ដែលធ្លាប់ជាចៅហ្វាយស្រុកនៅរបបសាធារណរដ្ឋខ្មែរ។ តាមពិតសាច់ញាតិរបស់ខ្ញុំ មិនមែនជាមន្ត្រីរដ្ឋការទេ។ ដើម្បីកុំឲ្យបែកការណ៍ អង្គការបានយកមនុស្សទៅសម្លាប់នៅទីកន្លែងឆ្ងាយពីភូមិ។ ប្រជាជនមួយចំនួនទៀតបានស្លាប់ដោយសារហូបចុកមិនគ្រប់គ្រាន់ ជំងឺ និងធ្វើការហួសកម្លាំង។ ដោយសារតែស្រេកឃ្លានខ្លាំងពេក ប្រជាជនខ្លះបានលួចដាំបបរលាយជាមួយកន្ទក់ ឬលួចគាស់ដំឡូង សណ្តែកនិងកាច់ពោតហូបចម្អែតក្រពះ ប៉ុន្តែប្រសិនឈ្លបឃើញ អ្នកលួចនោះនឹងត្រូវយកទៅសម្លាប់មិនខាន។

នៅពេលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាសហការជាមួយកងទ័ពវៀតណាមវាយចូលមក ខ្ញុំក៏បានរត់គេចខ្លួនពីភូមិ។ ចំណែកកម្មាភិបាលខ្មែរក្រហមដទៃទៀតត្រូវបានកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមបានចាប់ដាក់ឡាន រួចដឹកទៅឃុំឃាំង។ ខ្ញុំបានរួចខ្លួន ដោយសារខ្ញុំបានគេចខ្លួនទៅរស់នៅលាយឡំជាមួយប្រជាជននៅក្នុងភូមិ។ ក្រោយមក ខ្ញុំក៏បានចូលធ្វើជាទាហានប៉ារ៉ា ព្រោះខ្ញុំខ្លាចកងទ័ពវៀតណាមចាប់យកទៅដាក់គុក។ ប៉ុន្តែមិនយូរប៉ុន្មាន ខ្ញុំក៏បានចូលសារភាពនៅចំពោះកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលមានអ្នកជំនាញការវៀតណាមនៅទីនោះដែរ។ ខ្ញុំត្រូវបានជំនាញការវៀតណាមនាំទៅសួរចម្លើយ និងបានសារភាពពីទោសកំហុស។

ខ្ញុំនៅតែសោកស្តាយចំពោះអំពើឃោរឃៅ ដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម និងនៅតែចងចាំនូវហេតុការណ៍ទាំងនោះ។ ខ្ញុំសូមផ្តាំទៅក្មេងជំនាន់ក្រោយ សូមខិតខំសិក្សាស្វែងយល់ឲ្យបានច្រើន ជាពិសេសប្រវត្តិសាស្ត្រខ្មែរក្រហម ដើម្បីយល់ដឹងពីទុក្ខលំបាករបស់ប្រជាជនក្នុងសម័យនោះ និងធ្វើយ៉ាងណាកុំឲ្យរបបដ៏ឃោរឃៅនោះកើតឡើងម្តងទៀត។ សព្វថ្ងៃ ខ្ញុំរស់នៅក្នុងឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

### ១៣) ជយ រ៉ែន

មុនខ្មែរក្រហមឡើងកាន់អំណាចខ្ញុំ រស់នៅក្នុងឃុំកំពង់ក្តី ស្រុកជីក្រែង ខេត្តសៀមរាប។ នៅពេលខ្មែរក្រហមឡើងគ្រប់គ្រងប្រទេស ខ្ញុំនៅវ័យក្មេង ហើយត្រូវបានអង្គការចាត់តាំងឲ្យចូលក្នុងកងកុមារ។ ការងាររបស់កងកុមារ មានដូចជា ដើររើសអាចម៍គោ កាប់ដើមទន្ទ្រានខែត្រ និងកាប់ដីដំបូកយកមកលាយធ្វើជាជីដាក់ស្រែ។ ក្រៅអំពីការងារទាំងនេះ អង្គការបានចាត់តាំងខ្ញុំឲ្យទៅលើកភ្លឺស្រែ និងទៅរកខស។ ខ្ញុំក៏ដូចជាកុមារផ្សេងទៀតត្រូវបានអង្គការបំបែកចេញពីគ្រួសារ ឲ្យទៅរស់នៅតាមកងដែលមានកុមារសរុបប្រហែល ១០០ ទៅ២០០នាក់។ ខ្ញុំមានបងប្អូន៩នាក់ ត្រូវបានអង្គការបំបែកឲ្យរស់នៅឆ្ងាយៗពីគ្នា នៅតាមរៀងៗខ្លួន។ បងប្អូនទាំងអស់របស់ខ្ញុំ ត្រូវបានអង្គការបង្ខំឲ្យធ្វើការងារធ្ងន់ ដូចជា លើករង ដាំដំឡូង ដឹកប្រឡាយ និងលើកទំនប់។

ក្រោយមក អង្គការចាត់តាំងខ្ញុំឲ្យទៅលើកទំនប់មួយមានឈ្មោះថា «ទំនប់ម្កាក់» ដែលស្ថិតនៅឆ្ងាយពីផ្ទះរបស់ខ្ញុំ។ ពេលនោះខ្ញុំបានឃ្លាតឆ្ងាយពីគ្រួសារម្តងទៀត។ នៅសម័យខ្មែរក្រហម ការជួបជុំគ្រួសារកម្រនឹងមានណាស់។ មួយខែ ឬពីរខែ ទើបខ្ញុំសុំអង្គការត្រឡប់មកជួបជុំគ្រួសារបានមួយថ្ងៃ រួចហើយក៏ត្រឡប់ទៅសហករណ៍វិញ។ ខ្ញុំធ្លាប់បានទៅរៀនជាមួយក្មេងៗដទៃទៀត។ ក្នុងមួយថ្ងៃ ខ្ញុំនិងក្មេងៗដទៃទៀតរៀនបានតែមួយម៉ោងប៉ុណ្ណោះ រួចហើយក៏ត្រឡប់ទៅធ្វើការវិញ។ អង្គការបានប្រាប់កុមារថា កុមារចាំបាច់ត្រូវរៀនធ្វើស្រែចម្ការ និងរៀនពីមនោគមរបស់ខ្មែរក្រហមឲ្យច្រើន ពុំចាំបាច់រៀនអ្វីទៀតទេ។ កុមារត្រូវបានអង្គការបង្រៀនឲ្យចេះតាមដានរាល់សកម្មភាពរបស់ឪពុកម្តាយ និងរាយការណ៍ជូនអង្គការវិញ។ ខ្ញុំនិងប្រជាជនដទៃទៀតទទួលបានរបបអាហារតិចតួចណាស់ បើធៀបទៅនឹងទំហំការងារដែលអង្គការបង្ខំឲ្យធ្វើរាល់ថ្ងៃ។ របបអាហារប្រចាំថ្ងៃ គឺខ្ញុំទទួលបានបបរាវមួយ ឬពីរវែក សម្រាប់ហូបក្នុងមួយពេល ចំណែកអ្នកជំងឺទទួលបានរបបអាហារកាន់តែតិចជាងខ្ញុំទៅទៀត។ របបអាហារពេលថ្ងៃ អង្គការផ្តល់របបបាយ និងអំបិលគ្រួសខ្លះ។ ហេតុការណ៍មួយដែលខ្ញុំចាំមិនភ្លេចនោះគឺខ្ញុំបានឃើញយោធាខ្មែរក្រហមចងអ្នកទោសមួយខ្សែ រួចបណ្តើរទៅក្រោយភូមិ។ ខណៈនោះយោធាខ្មែរក្រហមបានបញ្ជាអ្នកទោសទាំងអស់ជីករណ្តៅដោយខ្លួនឯង។ បន្ទាប់ពីជីករួចយោធាខ្មែរក្រហមបានឲ្យទឹកអ្នកទោសទាំងនោះផឹក និងយកក្រមាមកបង់ភ្នែកអ្នកទោសទាំងនោះ រួចហើយបាញ់រះទៅលើអ្នកទោសនោះទម្លាក់ចូលទៅក្នុងរណ្តៅតែម្តង។ ចំណែកឯអ្នកទោសផ្សេងទៀតត្រូវបានឈ្លបខ្មែរក្រហមយកទៅដាក់នៅមន្ទីរសន្តិសុខកំពង់ក្តី។ ខ្ញុំបានឃើញឆ្មាំគុក បង្ខំអ្នកទោសឲ្យធ្វើការធ្ងន់ ថែមទាំងបង្អត់អាហារអ្នកទោសទៀត។

នៅចុងឆ្នាំ១៩៧៨ ខ្ញុំបានឮដំណឹងថាកងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលគាំទ្រដោយកងទ័ពវៀតណាម ចូលមករំដោះប្រជាជនកម្ពុជា។ ខ្ញុំសប្បាយចិត្តណាស់ព្រោះបានរួចពីរបបដ៏ឃោរឃៅនេះ។ ខ្ញុំបានរៀបការនៅឆ្នាំ១៩៨៥ នៅពេលខ្ញុំអាយុបាន២៥ឆ្នាំ ជាមួយប្រពន្ធឈ្មោះ ម៉ឹង លាត ដែលរស់នៅក្នុងភូមិជាមួយគ្នា។ អ្វីដែលខ្ញុំសោកស្តាយនោះគឺការបាត់ដំណឹងបងប្អូនរបស់ខ្ញុំចំនួនពាទាក់ដែលខ្មែរក្រហមបានបញ្ជូនឲ្យទៅធ្វើកងទ័ព។ នៅឆ្នាំ២០០៤ ខ្ញុំបាននាំប្រពន្ធកូនមកប្រកបរបរធ្វើចម្ការ និងលក់ដូរនៅឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ខ្ញុំសូមផ្តាំផ្ញើទៅក្មេងជំនាន់ក្រោយឲ្យស្វែងយល់ពីរបបខ្មែរក្រហមឲ្យបានច្បាស់លាស់ និងចូលរួមទប់ស្កាត់កុំឲ្យរបបយង់ឃ្នងនេះកើតឡើងម្តងទៀត។

១៨) បាក់ លឹម



ប្រាក់ លឹម

ខ្ញុំមានអាយុ៧៧ឆ្នាំ មានមុខរបរជាកសិករ។ នៅក្នុងឆ្នាំ១៩៧៥យោធាខ្មែរក្រហមបានឡើងគ្រប់គ្រងប្រទេស ខ្ញុំរស់នៅក្នុងសហករណ៍មួយនៅឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ ប្រជាជនដែលរស់នៅក្នុងភូមិ ត្រូវបានខ្មែរក្រហមបំបែកចេញពីគ្រួសារឲ្យទៅធ្វើការងាររួម រស់នៅរួម និងហូបរួម។ ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យធ្វើស្រែប្រាំង និងស្រែវស្សា។ ខ្ញុំត្រូវចេញទៅធ្វើការតាំងពីម៉ោង៦ព្រឹក

ដល់ម៉ោង១១ ឬ១២ ថ្ងៃត្រង់ និងពីម៉ោង១រសៀល ដល់ម៉ោង៥ល្ងាច។ បន្ទាប់ពីសម្រាកហូបបាយល្ងាច ពេលខ្លះខ្ញុំត្រូវធ្វើការបន្តរហូតដល់ម៉ោង១១ ឬ១២យប់។

ចំពោះការហូបចុករបស់ប្រជាជននៅក្នុងស្រុកព្រះនេត្រព្រះ ដំបូងអង្គការចែករបបអង្ករ១កំប៉ុងសម្រាប់មនុស្សពីរនាក់។ លុះក្រោយមកអង្គការដាំបបរដាក់អង្ករ១កំប៉ុងសម្រាប់មនុស្ស ១០នាក់ធ្វើឲ្យប្រជាជនមានការស្រេកឃ្លានយ៉ាងខ្លាំង។ អង្គការបានបែងចែកប្រជាជនជាពីរប្រភេទ គឺ ១) ប្រជាជនថ្មី គឺជាប្រជាជនដែលខ្មែរក្រហមជម្លៀសមកពីខេត្តក្រុងផ្សេងៗ និង ២) ប្រជាជនមូលដ្ឋាន គឺជាប្រជាជនដែលមានដើមកំណើតនៅក្នុងភូមិប្រាសាទនេះ។ ខ្ញុំគឺជាប្រជាជនមូលដ្ឋាន។ ប្រជាជនថ្មីនិងប្រជាជនមូលដ្ឋានមានការងារដូចៗគ្នា។ អ្នកដែលធ្វើជាកងចល័តគឺគ្មានពេលសម្រាកគ្រប់គ្រាន់ឡើយ។

នៅពេលដែលមានមនុស្សឈឺនៅក្នុងសហករណ៍គឺមានមន្ទីរពេទ្យដើម្បីសម្រាកនិង គ្រូពេទ្យព្យាបាល ប៉ុន្តែគ្រូពេទ្យទាំងនោះមិនមានជំនាញច្បាស់លាស់ឡើយ។ គ្រូពេទ្យភាគច្រើន គឺចេះតែចាក់ថ្នាំ និងចេះដេររបួសបន្តិចបន្តួចប៉ុណ្ណោះ។ ថ្នាំដែលគ្រូពេទ្យផ្តល់ឲ្យអ្នកជំងឺ ពេលនោះ គឺជាប្រភេទថ្នាំដែលផ្សំពីឫសឈើជាច្រើនមុខកិនលាយបញ្ចូលគ្នារួចសម្ងួតឲ្យស្ងួត បន្ទាប់មកលុញឲ្យមានរាងមូលៗដែលមានសណ្ឋានដូចជាអាចម៍ទន្សាយ។ ពេទ្យសហករណ៍ បានចែកថ្នាំទាំងនេះឲ្យអ្នកជំងឺលេប ទោះបីអ្នកជំងឺនោះឈឺគ្រុនក្តៅ ផ្តាសាយ និងរាក។ ប្រសិនបើមានអ្នកជំងឺឈឺធ្ងន់ គ្រូពេទ្យនឹងប្រើទឹកដូងចាក់ឲ្យអ្នកជំងឺនោះ។ ប៉ុន្តែប្រសិនបើអ្នកជំងឺឈឺយូរ អង្គការនឹងចោទអ្នកជំងឺនោះថា គ្រុនសតិអារម្មណ៍មិនខាន ហើយអង្គការនឹងកត់សម្គាល់អ្នកជំងឺនោះជាមុខសញ្ញាដើម្បីយកទៅកសាង និងរៀនសូត្រមិនខាន។ ជារឿយៗ ខ្ញុំបានឃើញកងឈ្លបខ្មែរក្រហមយកសាកសពចេញពីមន្ទីរពេទ្យក្បែរភូមិរបស់ខ្ញុំ។

នៅជំនាន់នោះអង្គការបានឲ្យក្មេងៗទៅរៀននៅក្នុងរោងវែងជិតកន្លែងធ្វើការ ប៉ុន្តែការរៀននោះគឺផ្តោតសំខាន់លើការដាំពោត សណ្តែក និងស្រូវជាដើម។ ប៉ុន្តែប្រសិនបើអង្គការរកឃើញអ្នកលួចដំឡូង ពោត និងដំណាំហូបផ្លែផ្សេងៗ អង្គការនឹងយកអ្នកទាំងនោះទៅសម្លាប់ចោលមិនខាន។ ការរៀនសូត្រនៅក្នុងសម័យនោះមិនទាក់ទងនឹងអក្សរច្រើនទេ។ ចំណែកគ្រូបង្រៀន អង្គការបានជ្រើសរើសចេញពីប្រជាជនថ្មីដែលជម្លៀសមកពីទីក្រុងភ្នំពេញ មករស់នៅក្នុងភូមិប្រាសាទនេះតែម្តង។

ខ្ញុំធ្លាប់បានឃើញការរៀបការរបស់យុវជន និងយុវនារីនៅជំនាន់នោះ ដែលការរៀបការមួយលើកៗ មានចាប់ពី៤០គូឡើងទៅ។ គូស្វាមីភរិយាថ្មីទាំងនោះត្រូវឡើងប្តេជ្ញាចិត្តថាយកគ្នាជាប្តីប្រពន្ធ និងស្ម័គ្រចិត្តបម្រើអង្គការ។ ពិធីរៀបការនោះមានការចូលរួមពីប្រធានសហករណ៍ ហើយអំណោយដែលអង្គការផ្តល់ឲ្យគូស្វាមីភរិយាថ្មីនោះ គឺមានតែក្រណាត់ខ្មៅមួយដុំ និងក្រមាមួយប៉ុណ្ណោះ។ នៅសម័យនោះ ប្រសិនបើនរណាម្នាក់ហ៊ានប្រព្រឹត្តខុសសីលធម៌ អង្គការនឹងយកទៅសម្លាប់ចោលជាមិនខាន។

នៅពេលមួយ អង្គការបានចាត់តាំងឲ្យខ្ញុំទៅរកវល្លិ៍ ប៉ុន្តែបានហាមឃាត់ខ្ញុំមិនឲ្យដើរទៅតំបន់ផ្សេងទៀតឡើយ។ នៅពេលដែលមេក្រុមរបស់ខ្ញុំមិននៅខ្ញុំបានលបដើរចូលទៅតំបន់មួយក្បែរនោះ ព្រោះខ្ញុំឆ្ងល់ថា ហេតុអ្វីបានជាអង្គការហាមខ្ញុំ។ ស្រាប់តែខ្ញុំដើរមិនទាន់ដល់ទីតាំងផង ក៏ខ្ញុំធំក្លិនស្អុយចេញពីព្រៃ ប៉ុន្តែខ្ញុំនៅតែបន្តដើរទៅមុខរហូតប្រទះឃើញអន្លង់មួយមានបណ្តោយ ប្រហែល១០ម៉ែត្រ។ នៅក្នុងអន្លង់នោះមានសាកសពមនុស្សប្រមាណ ៥០នាក់ដែលមិនទាន់បានកប់។ ពេលនោះ ខ្ញុំរន្ធត់ និងភ័យខ្លាចយ៉ាងខ្លាំង។ បន្ទាប់មក ខ្ញុំក៏ប្រញាប់ដើរតម្រង់មកកន្លែងរកវល្លិ៍វិញ។ ខ្ញុំមិនដែលបាននិយាយរឿងដែលខ្ញុំបានប្រទះឃើញប្រាប់នរណាឡើយ នៅពេលត្រឡប់មកសហករណ៍វិញ។ ប្រជាជនមួយចំនួននៅក្នុងភូមិរបស់ខ្ញុំ ក៏ត្រូវបានអង្គការយកទៅសម្លាប់ដែរ ចំណែកវត្តចំនួន៤ត្រូវបានវាយបំផ្លាញ ហើយអង្គការបានបញ្ជាឲ្យ

ព្រះសង្ឃ និង អាចារ្យនៅវត្តទៅធ្វើការងារដូចប្រជាជនធម្មតាវិញ។

នៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ខ្ញុំ និងគ្រួសារបានផ្លាស់មករស់នៅ ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យរហូតមកដល់បច្ចុប្បន្ននេះ។ ខ្ញុំសំណូមពរឲ្យក្មេងជំនាន់ក្រោយត្រូវខិតខំប្រឹងប្រែងសិក្សា និងត្រិះរិះពិចារណាមុនពេលសម្រេចចិត្តធ្វើអ្វីមួយ ហើយធ្វើយ៉ាងណាដើម្បីទប់ស្កាត់កុំឲ្យប្រទេសកម្ពុជាធ្លាក់ចូលក្នុងរបបខ្មែរក្រហមម្តងទៀត។

**១៥) ឆែក ធំ**

នៅក្នុងសម័យ លន់ នល់ ខ្ញុំបានបួសជាព្រះសង្ឃ ពេលនោះបានឃើញការទម្លាក់គ្រាប់បែក ជាច្រើនលើកច្រើនសារនៅស្រុកកំណើតរបស់ខ្ញុំនៅភូមិគោកតាសុខ ឃុំពន្លៃ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។ ពេលនោះ ខ្ញុំត្រូវបានទាហានលន់ នល់ តាមសម្លាប់ ដូច្នេះហើយទើបខ្ញុំសម្រេចចិត្តរត់ចេញពីផ្ទះ ស្របពេលដែលកងកម្លាំងរំដោះខ្មែរក្រហមកំពុងកៀរប្រជាជនចូលក្នុងព្រៃ។ រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានឡើងគ្រប់គ្រងប្រទេស ពេលនោះខ្មែរក្រហមបានបញ្ជូនខ្ញុំ និងគ្រួសារមកភូមិគោកតាសុខវិញ។ ប្រហែលបីខែក្រោយមក ខ្មែរក្រហមបានជម្លៀសប្រជាជនដែលរស់នៅក្នុងទីក្រុងមកដល់ភូមិរបស់ខ្ញុំកំពុងរស់នៅដែរ។ ប្រជាជនថ្មីទាំងនោះបានសង់ខ្ទមសម្រាប់ស្នាក់នៅរៀងៗខ្លួន។ចំណែកការហូបចុកប្រជាជនថ្មីទាំងនោះពុំមានបាយហូបគ្រប់គ្រាន់ឡើយ គឺមានតែបបរប៉ុណ្ណោះ។ ស្ត្រីដែលទើបនឹងសម្រាលកូនខ្ចី ក៏ត្រូវខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើការដកស្ទូងជាធម្មតាដែរ ដោយទុកកូនឲ្យចាស់ៗក្នុងភូមិមើលថែទាំ។ ប្រសិនបើនរណាម្នាក់មិនព្រមចេញទៅធ្វើការ ឬធ្វើការដោយមិនយកចិត្តទុកដាក់ នោះអង្គការយកទៅរៀនសូត្រមិនខានឡើយ។ សម័យនោះ មិនមានពេទ្យព្យាបាលអ្នកជំងឺឲ្យបានដិតដល់ឡើយ។ ខ្ញុំធ្លាប់ឈឺគ្រាចៀក



ឆែក ធំ និងប្រពន្ធ ព្រមទាំងចៅ

ប៉ុន្តែដោយសារពេទ្យព្យាបាលមិនបានត្រឹមត្រូវ បណ្តាលឲ្យត្រចៀករបស់ខ្ញុំស្តាប់មិនច្បាស់។ នៅក្នុងរបបខ្មែរក្រហម គ្រួសាររបស់ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើស្រែ ជាចដីដាក់ស្រូវ កាប់ទន្ទ្រានខែត្រ ជីកប្រឡាយ ដោយយើងចាប់ផ្តើមធ្វើតាំងពីព្រលឹមរហូតដល់យប់។ នៅខណៈនោះ ខ្មែរក្រហមក៏បានប្រកាសរកអ្នកមានចំណេះដឹង និសិត្ស បញ្ញវន្ត សាស្ត្រាចារ្យ ឲ្យមកធ្វើការ បន្ទាប់មកអ្នកទាំងនេះក៏បាត់ខ្លួនគ្មានដំណឹងរហូតមកដល់សព្វថ្ងៃ។

នៅឆ្នាំ១៩៧៦ ខ្ញុំបានចូលរួមពិធីរៀបការ ដែលខ្មែរក្រហមបានរៀបចំឲ្យយុវជន និងយុវនារី។ ក្រោយពីរៀបការរួច គូស្វាមីភរិយាថ្មីទាំងនោះត្រូវចេញទៅធ្វើការវិញ។

នៅដើមខែមិថុនា ឆ្នាំ១៩៧៧ ប្រពន្ធរបស់ខ្ញុំសម្រាលបានកូនប្រុសម្នាក់។ កំឡុងពេលមានកូនខ្ចី ប្រពន្ធរបស់ខ្ញុំត្រូវខ្មែរក្រហមចាត់តាំងឲ្យចេញទៅធ្វើការជាធម្មតា ដោយទុកកូនឲ្យចាស់ៗនៅក្នុងភូមិជួយមើលថែទាំ។ ក្រោយមកខ្ញុំបានឮដំណឹងថា មានកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមចូលមកជួយសង្គ្រោះ ដូច្នេះខ្ញុំនិងប្រពន្ធកូនក៏បានត្រឡប់មករស់នៅក្នុងភូមិវិញ មួយរយៈក្រោយមកខ្ញុំបានទទួលដំណឹងថាមានការជ្រើសរើសគ្រូបង្រៀន ខ្ញុំក៏បានដាក់ពាក្យប្រឡងនៅស្រុកថ្មពួកជាប់។ នៅឆ្នាំ១៩៩០ ខ្ញុំបានក្លាយជាគ្រូបង្រៀន។ ក្រោយពេលចូលនិវត្តន៍ ខ្ញុំបានផ្លាស់មករស់នៅឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ និងរស់នៅយ៉ាងមានសុភមង្គលនៅទីនេះ។ សព្វថ្ងៃ ខ្ញុំមានអាយុ៧២ឆ្នាំ រស់នៅជាមួយកូនបីនាក់ និងចៅតូចៗ។

### ១៦) គង់ សឿត

ខ្ញុំមានអាយុ៥៧ឆ្នាំ បច្ចុប្បន្នរស់នៅឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើការចាប់ពីម៉ោង៧ព្រឹក រហូតដល់ម៉ោង១២ថ្ងៃត្រង់ ទើបខ្មែរក្រហមបានអនុញ្ញាតឲ្យខ្ញុំក៏ដូចជាប្រជាជនដទៃទៀតឈប់សម្រាកហូបអាហារ។ បន្ទាប់ពីហូបអាហារថ្ងៃត្រង់រួច នៅម៉ោង១:០០រសៀល ខ្ញុំបានចាប់ផ្តើមបន្តធ្វើការរហូតដល់ម៉ោង៧យប់។ រៀងរាល់ថ្ងៃ ខ្ញុំទទួលបានរបបអាហារបីពេល ដោយពេលព្រឹកខ្ញុំហូបបបរ ពេលថ្ងៃត្រង់ហូបបាយ និងពេលល្ងាចហូបបបរ ជាមួយម្ហូបដែលភាគច្រើនមានតែសម្លត្រកួនប៉ុណ្ណោះ។ ការងារប្រចាំថ្ងៃដែលខ្មែរក្រហមបានចាត់តាំងឲ្យខ្ញុំធ្វើនៅពេលនោះ មានដូចជា ៖ លើកភ្លឺស្រែ ជញ្ជូនដីដាក់ស្រែ ជីកប្រឡាយ និងលើកទំនប់។ ខ្ញុំបានធ្វើការងារទាំងនេះ រហូតដល់របបខ្មែរក្រហមដួលរលំក្នុងឆ្នាំ១៩៧៩។ ប៉ុន្តែអ្វីដែលខ្ញុំមិនអាចបំភ្លេចបាននោះ គឺស្នាមរបួសដែលបានបន្សល់ទុករហូតមកដល់សព្វថ្ងៃនេះ។

បន្ទាប់ពីខ្មែរក្រហមដួលរលំនៅក្នុងឆ្នាំ១៩៧៩ ខ្ញុំនិងប្រជាជនដទៃទៀត ត្រូវបានខ្មែរក្រហមជម្លៀសចេញពីតំបន់ដែលកងទ័ពវៀតណាមគ្រប់គ្រង។ ខ្ញុំបានធ្វើដំណើរដោយថ្មើរជើងនិងកាត់តាមព្រៃដោយគ្មានគោលដៅច្បាស់លាស់។ ក្នុងអំឡុងពេលដែលរត់គៀសខ្លួន ខ្ញុំក៏បានជាន់ចម្រូងឫស្សីលាបពិស ដែលយោធាខ្មែរក្រហមបានដាក់ដើម្បីបង្អាក់ដំណើររបស់ខ្មាំងសត្រូវ។ បន្ទាប់ពីជាន់ចម្រូងឫស្សីនេះភ្លាម ខ្ញុំក៏ចាប់ផ្តើមឈឺចុកចាប់រហូតដល់សន្លប់នៅនឹងកន្លែង។ ពេលនោះ ខ្ញុំត្រូវបានប្រជាជនដែលរួមដំណើរជាមួយគ្នាជួយសង្គ្រោះ ដោយបានអូសខ្ញុំទៅកន្លែងស្ងាត់កំបាំងដើម្បីព្យាបាល។ មួយសន្ទុះក្រោយមក ខ្ញុំអាចធ្វើដំណើរបន្តទៅមុខរហូតដល់ទល់ដែនកម្ពុជា-ថៃ ប៉ុន្តែជើងរបស់ខ្ញុំនៅឈឺនៅឡើយ។

នៅពេលមកដល់ព្រំដែនថៃ ខ្ញុំបានប្រទះឃើញក្រុមយោធាថៃចាប់ស្រីក្មេងៗដែលរត់គេចខ្លួនមកជាមួយខ្ញុំយកទៅរំលោភទៀតផង។ ពេលនោះការរស់នៅនិងការរត់គៀសខ្លួនមានការលំបាកខ្លាំងណាស់ ហើយខ្ញុំក៏មិននឹកស្មានថា ខ្ញុំអាចមានជីវិតរស់រហូតមកដល់សព្វថ្ងៃនេះដែរ។

### ១៧) ផន ម៉ៅ

បន្ទាប់ពីខ្មែរក្រហមឡើងកាន់កាប់អំណាចក្នុងឆ្នាំ១៩៧៥ ខ្ញុំនិងគ្រួសារត្រូវបានខ្មែរក្រហមបំបែកឲ្យរស់នៅកងផ្សេងៗគ្នា នៅក្នុងខេត្តសៀមរាប។ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំង

ឲ្យនៅក្នុងកងចល័ត ហើយការរស់នៅរបស់ខ្ញុំពិតជាមានការលំបាកខ្លាំងណាស់ ជាពិសេសរបបអាហារប្រចាំថ្ងៃ ដោយមានតែបបរលាយត្រកួន ព្រលិត គល់ចេក និងគល់ល្ហុងប៉ុណ្ណោះ។ ចំណែកការងារប្រចាំថ្ងៃរបស់ខ្ញុំ គឺលើកទំនប់ ជីកប្រឡាយ ស្ទូងស្រូវ និងច្រូតកាត់។ ប្រសិនបើមាននរណាម្នាក់ហ៊ានជំទាស់នឹងបទបញ្ជាថ្នាក់លើ ខ្មែរក្រហមនឹងយកអ្នកនោះទៅធ្វើទារុណកម្មឬសម្លាប់ចោលភ្លាម។

ខ្មែរក្រហមមិនអនុញ្ញាតឲ្យប្រជាជន ដែលមានជំងឺបន្តិចបន្តួចឈប់សម្រាកព្យាបាលឡើយ ផ្ទុយទៅវិញបានបង្ខំឲ្យធ្វើការដូចប្រជាជនដទៃ។ ខ្ញុំនិងប្រជាជនផ្សេងទៀតត្រូវធ្វើការយ៉ាងហោចណាស់១០ម៉ោងក្នុងមួយថ្ងៃ។ ដោយពេលព្រឹកខ្ញុំបានចាប់ពីម៉ោង៧ ដល់ម៉ោង១២ថ្ងៃត្រង់ និងពេលរសៀលពីម៉ោង១ ដល់ម៉ោង៦ល្ងាច។ ពេលយប់ខ្លះ ខ្ញុំត្រូវបានខ្មែរក្រហមបញ្ជាឲ្យរម្ងាស់ថ្នាំរហូតដល់ម៉ោង៤ទៀបភ្លឺទៀតផង។ ក្នុងយប់ខ្លះ ខ្ញុំសម្រាកបានតែបីម៉ោងប៉ុណ្ណោះ។ ចំពោះការរៀបអាពាហ៍ពិពាហ៍នៅក្នុងសម័យខ្មែរក្រហមក៏មានការបែងចែកជាពីរប្រភេទដែរ គឺការរៀបការរវាងប្រជាជនមូលដ្ឋានជាមួយនឹងប្រជាជនមូលដ្ឋាន និងការរៀបការរវាងប្រជាជនថ្មីជាមួយនឹងប្រជាជនថ្មី។ ពិធីរៀបការនេះត្រូវបានរៀបចំឡើងដោយកម្មាភិបាលខ្មែរក្រហម ដោយខាងបុរស និងនារីចាប់ដៃគ្នា ហើយឡើងប្តេជ្ញាចិត្តចំពោះមុខអង្គការ និងគោរពទង់បដិវត្តន៍។ ប្រសិនបើខ្មែរក្រហមផ្សំផ្គុំឲ្យជួបមនុស្សដែលខ្លួនមិនស្រឡាញ់ សាមីខ្លួនទាំងសងខាងក៏មិនហ៊ានបដិសេធដែរ ព្រោះខ្លាចទទួលរងទណ្ឌកម្មធ្ងន់ធ្ងរ និងខ្លាចខ្មែរក្រហមយកទៅសម្លាប់ចោល។ ជួនកាលមាននារីខ្លះហ៊ានសម្លាប់ខ្លួនដោយសារមិនពេញចិត្តនឹងគូរបស់ខ្លួន។ ខ្មែរក្រហមបានតម្រូវឲ្យប្រជាជនទាំងអស់ស្លៀកសម្លៀកបំពាក់ខ្មៅ ទោះបីជាក្នុងពិធីរៀបការក៏ដោយ។ ពេលរៀបការរួច ខ្មែរក្រហមបានអនុញ្ញាតឲ្យគូស្វាមីភរិយាថ្មីអាចឈប់សម្រាកមួយថ្ងៃរួចហើយត្រូវធ្វើការបម្រើជូនអង្គការវិញ ទៅតាមការងាររៀងៗខ្លួន ដែលមានរយៈពេលមួយខែទើបអាចជួបគ្នាម្តងទៀត។

ខ្ញុំបានធ្វើការនៅក្នុងកងចល័តរហូតដល់របបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ទើបត្រឡប់មកភូមិកំណើតវិញ ហើយក្រោយមក ខ្ញុំក៏ផ្លាស់មកខេត្តឧត្តរមានជ័យ។ បច្ចុប្បន្ន ខ្ញុំមានអាយុ៦១ឆ្នាំ រស់នៅក្នុងភូមិទួលប្រាសាទ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង។

តាមរយៈសាច់រឿងខាងលើ ប្រជាជនក្នុងសហគមន៍អន្លង់វែងបាននិយាយរឿងរ៉ាវផ្សេងៗ និងបទពិសោធន៍ជូរចត់ដែលខ្លួនឆ្លងកាត់កាលពីសម័យសង្រ្គាម ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ ក្នុងអំឡុងរបបខ្មែរក្រហម និងពេលក្រោយមក។ ប៉ុន្តែសម្រាប់អតីតខ្មែរក្រហម និងប្រជាជនមួយចំនួនដែលធ្លាប់បានរស់នៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក នៅតែមិនចង់និយាយពីការជាប់ទាក់ទងរបស់ខ្លួន ជាមួយអំពើឃោរឃៅរបស់ តាម៉ុក និងមេដឹកនាំខ្មែរក្រហមមួយចំនួនទៀតនៅក្នុងតំបន់អន្លង់វែង។ អតីតខ្មែរក្រហមទាំងនេះក៏បានព្យាយាមលាក់ពីអត្តសញ្ញាណរបស់ខ្លួន ហើយក៏មិនចង់បង្ហាញពីតួនាទីពិតប្រាកដរបស់ខ្លួនដែរ។ ជារឿយៗអ្នកទាំងនេះហាក់ចង់បង្ហាញថា តាម៉ុក ជាមនុស្សល្អ និងបានចាត់ទុកខ្លួនឯងថាជាជនរងគ្រោះដែរ ដោយបានលើកឡើងពីការរត់ភៀសខ្លួនពីសង្រ្គាម ការឈឺចាប់ ការបែកបាក់ក្រុមគ្រួសារនៅក្នុងអំឡុងពេលរបបខ្មែរក្រហមត្រូវបានដួលរំលំចេញពីអំណាច។ ទោះបីជារបបខ្មែរក្រហមបានផុតរលត់ទៅហើយ ហើយសាលាក្តីខ្មែរក្រហមបានកាត់ទោស និងកំពុងដំណើរកាត់ទោសមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតខ្មែរក្រហមមួយចំនួនទៀត ហើយគ្រោងបញ្ចប់សំណុំរឿងទាំងអស់នៅពេលឆាប់ខាងមុខនេះក៏ដោយ ក៏ជនរងគ្រោះដែលនៅរស់រានមានជីវិតនៅតែចង់ដឹងរឿងរ៉ាវឪពុកម្តាយបងប្អូន និងសាច់ញាតិរបស់ខ្លួនដែលបានស្លាប់ ពីអតីតកម្មាភិបាល និងយោធាខ្មែរក្រហមផ្សេងទៀតដែរ។

***សម្ភាសន៍ដោយនិស្សិតស្ម័គ្រចិត្តមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង***

***រៀបរៀងដោយ៖ សោម ប៊ុនថន***

# រឿងខ្ញុំនៅក្នុងរបបខ្មែរក្រហម



ប៉ែន ចាន់ថន

ខ្ញុំឈ្មោះ ប៉ែនចាន់ថនអាយុ៦២ឆ្នាំមានស្រុកកំណើតនៅឃុំរការ (បច្ចុប្បន្នសង្កាត់រកាក្នុង) ស្រុកទ្រាំង (ក្រុងដូនកែវ) ខេត្តតាកែវ។ ឪពុកខ្ញុំឈ្មោះ ប៉ែន ផាន់ (ស្លាប់ដោយសារសង្រ្គាមក្នុងសម័យលន់ នល់) និងម្ដាយឈ្មោះ សៀង ខែម (ស្លាប់នៅក្នុងសម័យខ្មែរក្រហម)។ ខ្ញុំមានបងប្អូនចំនួន៤នាក់ ស្រី២នាក់ និងប្រុស២នាក់។ នៅសម័យសង្គមរាស្ត្រនិយម ខ្ញុំបានរៀននៅស្រុកកំណើតក្នុងខេត្ត តាកែវ។ បន្ទាប់ពីកើតមានរដ្ឋប្រហារទម្លាក់ សម្ដេចព្រះនរោត្តមសីហនុ ចេញពីតំណែងក្នុង ខែមីនា ឆ្នាំ១៩៧០ នៅក្នុងប្រទេសកើតមានការប្រយុទ្ធគ្នារវាងកងទ័ព លន់ នល់ និង យោធាខ្មែរក្រហម។ អំឡុងពេលនោះរដ្ឋាភិបាល លន់ នល់ បានចាប់ប្រជាជនសិស្ស និស្សិត ដែលកំពុងសិក្សាយកទៅធ្វើជាកងទ័ពច្បាំងជាមួយខ្មែរក្រហម។ ដោយមើលឃើញថាគ្មានសុវត្ថិភាពម្ដាយខ្ញុំបានបញ្ជូនខ្ញុំឲ្យទៅបួសជាព្រះសង្ឃនៅវត្តសិង្ហ ស្ថិតនៅក្នុងឃុំរការក្នុង ក្រុងស្វាយដូនកែវ ខេត្តតាកែវ នៅខែមករា ឆ្នាំ១៩៧៥។

ក្នុងខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះ ឡើងកាន់អំណាច ខ្មែរក្រហមបានជម្លៀសប្រជាជនទូទាំងប្រទេស ដែលរស់នៅតាមទីក្រុងនានាឲ្យទៅរស់នៅតាមសហករណ៍នៅតាមទីជនបទ។ អំឡុងពេលនោះ ព្រះសង្ឃដែលបួសនៅក្នុងវត្តសិង្ហរួមទាំងខ្ញុំមានចំនួន ១៧អង្គ ត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅនៅវត្តចម្ប៉ា ក្នុងឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ។ នៅទីនោះខ្មែរក្រហមបានធ្វើការបែងចែកព្រះសង្ឃជាពីរផ្នែកគឺ ព្រះសង្ឃខាងផ្នែកសេដ្ឋកិច្ច និងព្រះសង្ឃសមរភូមិមុខ។ លោកសង្ឃខាងផ្នែកសេដ្ឋកិច្ចមានតួនាទីនៅក្នុងកុដិ ដាំបន្លែ ឡើងត្នោត ស្ទូងស្រូវ និងនិមន្តបិណ្ឌបាតតាមភូមិ។ ចំណែកឯលោកសង្ឃសមរភូមិមុខវិញ ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅជីកបារាយណ៍ និងលើកទំនប់ជាដើម។ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើជាលោកសង្ឃសេដ្ឋកិច្ចចាប់ពីខែមេសា ឆ្នាំ១៩៧៥ រហូតដល់ដើមឆ្នាំ១៩៧៦ ទើបខ្មែរក្រហមតម្រូវឲ្យលោកសង្ឃទាំងអស់ផ្សឹកទៅរស់នៅតាមសហករណ៍ដូចប្រជាជនទូទៅដែរ។ បន្ទាប់ពីផ្សឹករួច ខ្ញុំបានទៅរស់នៅជាមួយម្ដាយនៅកន្លែងការដ្ឋានដែលគាត់ធ្វើការនៅជិតទីរួមខេត្តតាកែវ។ នៅទីនោះខ្ញុំត្រូវបានមេភូមិប្រើឲ្យទៅដឹកអំបិលនៅខេត្តកំពត ដោយគាត់បានប្រគល់កង់មួយដល់ខ្ញុំសម្រាប់ដឹកអំបិល។ ជារៀងរាល់ថ្ងៃ ខ្ញុំត្រូវក្រោកពីដេកនៅម៉ោង៣ទៀបភ្លឺ ហើយជិះកង់ធ្វើដំណើរទៅខេត្តកំពត ដើម្បីដឹកអំបិលយកមកខេត្តតាកែវ។ សម្រាប់របបអាហារ ខ្ញុំទទួលបានអង្ករមួយកំប៉ុងក្នុងមួយថ្ងៃ នៅពេលដែលខ្ញុំដឹកអំបិលមកដល់កន្លែងវិញទាន់ពេលល្ងាច។ ប្រសិនបើតាមផ្លូវធ្វើដំណើរកង់ខូច ហើយខ្ញុំមិនអាចដឹកអំបិលមកវិញទាន់ពេលនោះ ខ្ញុំមិនត្រូវទទួលបានរបបអាហារឡើយ។ ក្រោយមក

ទៀត ខ្ញុំក៏ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅរែកទំនប់នៅសហករណ៍ស៊ីធស្វាគូ ដែលមានទីតាំងនៅខាងកើតឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ។

នៅដើមឆ្នាំ១៩៧៧ ខ្មែរក្រហមបានជម្លៀសខ្ញុំឲ្យទៅនៅការដ្ឋានជីកទំនប់ ក្នុងឃុំអង្គតាសោមក្នុង ស្រុកត្រាំកក់។ មានថ្ងៃមួយខ្ញុំបានទទួលដំណឹងថាម្តាយខ្ញុំឈឺពីពូម្នាក់ ដែលជាអ្នកជិតខាងកាលពីសម័យសង្គមរាស្ត្រនិយម។ ខ្ញុំបានសុំប្រធានកងទៅមើលម្តាយឈឺ ដោយសន្យាថាពេលទៅដល់ឃើញមុខម្តាយហើយនឹងត្រលប់មកឲ្យទាន់ម៉ោងធ្វើការវិញ ប៉ុន្តែប្រធានកងមិនបានអនុញ្ញាតឲ្យខ្ញុំទៅនោះទេ។ ដោយសារតែកន្លែងដែលម្តាយខ្ញុំរស់នៅមានចម្ងាយត្រឹមតែ២គីឡូម៉ែត្រពីកន្លែងដែលខ្ញុំធ្វើការ ខ្ញុំក៏សម្រេចចិត្តលួចទៅជួបម្តាយ។ ពេលធ្វើដំណើរទៅដល់ខ្ញុំក៏បានជួបនឹងកងឈ្លប។ ពួកកងឈ្លបបានចាប់ខ្ញុំចងស្លាបសេកមកក្រោយ ហើយយកខ្សែបន្លា ៤ ទៅ ៥គូ ដែលទើបវេញរួចយកមកវាយវាត់លើខ្លួនខ្ញុំឈឺស្ទើរតែដាច់ខ្យល់ស្លាប់។ បន្ទាប់ពីវាយខ្ញុំអស់ចិត្តហើយ កងឈ្លបទាំងនោះបានដាក់ទណ្ឌកម្មខ្ញុំឲ្យរែកទឹកពីត្រពាំងយកទៅដាក់ក្នុងស្រែប្រាំង ដោយឲ្យកងឈ្លបម្នាក់អង្គុយចាំមើល។ ខ្ញុំរែកទឹកនៅត្រពាំងនោះអស់រយៈពេល៩ថ្ងៃ ដោយមិនអនុ-ញ្ញាតឲ្យឈប់សម្រាកឡើយ។ ក្រោយមកទៀត អង្គការបានធ្វើការជ្រើសរើសប្រជាជនឲ្យទៅកាប់ព្រៃនៅស្រុកអង្គរបុរី។ ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យទៅកាប់ព្រៃ ដោយមួយថ្ងៃត្រូវកាប់ឆ្ការព្រៃដែលមានទទឹង១០ម៉ែត្រ និងបណ្តោយ ១០០ម៉ែត្រ។ នៅទីនោះមានប្រជាជនជាច្រើនត្រូវស្លាប់ដោយសារតែការធ្វើការហួសកម្លាំង មូសខាំ និងពស់ចឹកជាដើម។

នៅក្នុងឆ្នាំ១៩៧៨ អង្គការបានប្រើខ្ញុំឲ្យទៅឃ្វាលក្របីវិញម្តង។ ក្រោយមកទៀតមុនពេល វៀតណាមវាយចូលបានប៉ុន្មានខែ ខ្មែរក្រហមបានប្រើខ្ញុំឲ្យផលិតថ្មពិលសម្រាប់ដាក់វិទ្យុ ដោយខ្មែរក្រហមបានប្រគល់ឆ្នាំងអាលុយមីញ៉ូមមួយមកឲ្យខ្ញុំសម្រាប់ធ្វើថ្មពិល។ អំឡុងពេលនោះខ្ញុំបានស្តាប់វិទ្យុ ហើយក៏បានស្តាប់ពុប៉ុស្តិ៍វៀតណាមដែលនិយាយជាភាសាខ្មែរប្រកាសថា ប្រទេសខ្មែររជិតរំដោះហើយ ខ្មែរក្រហមនឹងត្រូវដួលរលំក្នុងពេលឆាប់ៗខាងមុខនេះ។ នៅពេលដែលវៀតណាមវាយចូលក្នុងដើមឆ្នាំ១៩៧៩ ខ្ញុំ និងអ្នកស្រុកមួយចំនួនមិនបានភៀសខ្លួនទៅជាមួយពួកខ្មែរក្រហមនោះទេ ដោយពួននៅក្បែរសមរភូមិមុខប្រយុទ្ធ តាមព្រំដែននៅក្នុងខេត្តតាកែវ ដដែល។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំខ្ញុំ និងគ្រួសារបានត្រលប់ទៅរស់នៅក្រុងដូនកែវ ខេត្តតាកែវ។

នៅឆ្នាំ ១៩៨៦ខ្ញុំបានធ្វើការនៅសាលាឃុំរការក្នុង ក្រុងដូនកែវ ខេត្តតាកែវ។ ខ្ញុំបានរៀបការជាមួយនារីម្នាក់ឈ្មោះ ភួង មុំ តាំងពីឆ្នាំ ១៩៧៩ ដោយចំណងអាពាហ៍ពិពាហ៍ខ្ញុំទទួលបានកូនចំនួន៥នាក់។ ក្រោយមក នៅឆ្នាំ២000 ភរិយារបស់ខ្ញុំបានទទួលមរណៈភាព។ ខ្ញុំក៏បានរៀបការជាមួយប្រពន្ធក្រោយ ឈ្មោះ ណុប សុភាព សព្វថ្ងៃគឺជាគ្រូបង្រៀននៅវិទ្យាល័យ ជាស៊ីមតាកែវ ក្នុងក្រុងដូនកែវ។ ខ្ញុំខ្ញុំទទួលបានកូនចំនួន៣នាក់ថែមទៀត។ ចំណែកឯតួនាទីរបស់ខ្ញុំនាពេលបច្ចុប្បន្នគឺជាចៅសង្កាត់រងទី១ នៅសង្កាត់រការក្នុង ក្រុងដូនកែវ ខេត្តតាកែវ។

**ដាត ចាន់សុនិត**



បឹងតាម៉ុក មើលពីក្លោងទ្វារចូល ស្ថិតនៅទីរួមខេត្តតាកែវ
(រូបថត៖បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការចាប់ផ្តើម និងការបញ្ចប់ជីវិតជាយោធា

ខ្ញុំឈ្មោះ ភេម ញាញ់ អាយុ៥៥ឆ្នាំ កើតនៅឃុំចាន់ស ស្រុកសូត្រនិគម ខេត្តសៀមរាប។ នៅឆ្នាំ១៩៧៧ ខ្មែរក្រហម បានចាត់តាំងខ្ញុំឲ្យទៅរស់នៅក្នុងកងកុមារ និងធ្វើការជាមួយ កុមារជាច្រើននាក់ផ្សេងទៀត ដែលមានទីតាំង ស្ថិតនៅមិន ឆ្ងាយប៉ុន្មានពីភូមិដែលខ្ញុំរស់នៅ។ ប្រធានកងកុមារបាន អនុញ្ញាតឲ្យខ្ញុំ និងកុមារនៅក្នុងកងរៀនសូត្រនៅពេលព្រឹក ហើយធ្វើការងារបម្រើអង្គការបដិវត្តន៍នៅពេលថ្ងៃ។ ប៉ុន្តែ ការរៀនសូត្រនៅពេលនោះ គ្រូមិនបានកំណត់ពេលវេលា និងដាក់កាលវិភាគឲ្យបានច្បាស់លាស់ឡើយ គឺក្នុងមួយថ្ងៃ គ្រូបង្រៀនតែមួយម៉ោង ឬពីរម៉ោងប៉ុណ្ណោះ។

ខ្ញុំ និងកុមារនៅក្នុងកង មានពេលវេលាតិចតួចណាស់ ដើម្បីរៀនលេខ និងអក្សរ ប៉ុន្តែយើងត្រូវចំណាយពេលវេលា យ៉ាងច្រើន សម្រាប់ធ្វើការបម្រើអង្គការ ដោយយើងចាប់ ផ្តើមធ្វើការចាប់ពីពេលចេញពីរៀនរហូតដល់ម៉ោងប្រាំល្ងាច។ ជារៀងរាល់ថ្ងៃ អង្គការបានបញ្ជាឲ្យកុមារទាំងអស់ ដើរដេញ សត្វចាបកុំឲ្យស៊ីស្រូវនៅក្នុងស្រែ រើសកួរស្រូវកាប់ដីដាំដំឡូង និងកាប់ដើមទន្ទ្រានខែត្រមកចិញ្ច្រាំធ្វើជីដើម្បីដាក់ស្រែ។ នៅ ក្នុងកង ខ្ញុំនិងសមាជិកកុមារជាច្រើននាក់បានទទួលរបប អាហារពីរពេលក្នុងមួយថ្ងៃ (គឺនៅម៉ោងដប់មួយ ឬម៉ោងដប់ ពីរ និងម៉ោងប្រាំល្ងាច) ដោយក្នុងម្នាក់ទទួលបានបបរមួយ កូនចានតូច។ ខ្ញុំនិងកុមារជាច្រើននាក់នៅក្នុងកងបានរស់នៅ ក្រោមភាពអត់ឃ្លាន ដូច្នេះហើយមានពេលខ្លះកុមារមួយ ចំនួនដែលរស់នៅក្នុងកងជាមួយខ្ញុំបានសម្រេចចិត្តលួចដក ដំឡូង និងបេះបោចផលដំណាំផ្សេងៗដែលអង្គការបានហាម ប្រាម មកធ្វើជាអាហារដើម្បីហូបចម្អែតក្រពះ។ កុមារមួយ ចំនួនត្រូវបានអង្គការចាប់ខ្លួនបាន រួចយកមកឃុំឃាំង និង វាយសួរចម្លើយ ហើយខ្លះទៀតត្រូវសម្លាប់ចោលនៅនឹង កន្លែង។

ក្រោយពីកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាម រំដោះប្រជាជនចេញពីរបប ខ្មែរក្រហមនៅឆ្នាំ១៩៧៩ ខ្ញុំនិងកុមារជាច្រើននាក់ផ្សេងទៀត មានឱកាសបានវិលត្រលប់ជួបជុំឪពុកម្តាយក្រុមគ្រួសារនៅ ភូមិកំណើតវិញ។ ប៉ុន្តែផ្ទះសម្បែង ទ្រព្យសម្បត្តិ និងសត្វ ពាហនៈរបស់ខ្ញុំគ្មានសេសសល់ឡើយ។ ខ្ញុំបានសម្រេចចិត្ត



ភេម ញាញ់ ឆ្នាំ២០១៦
(រូបថត ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចាកចេញពីភូមិ ទៅរស់នៅជាមួយអ៊ំប្រុសរបស់ខ្ញុំនៅភូមិ ផ្សេងវិញ។ ខ្ញុំបានធ្វើស្រែចម្ការ និងរស់នៅជាមួយអ៊ំប្រុស។

មកដល់ឆ្នាំ១៩៨១ កងកម្លាំងយោធាខ្មែរក្រហមដែល មានមូលដ្ឋាននៅលើភ្នំដងរែកបានចុះមកវាយប្រយុទ្ធជាមួយ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រ

ចិត្តវៀតណាមនៅសមរភូមិភ្នំគូលែន។ នៅពេលនោះកងទ័ពស្ម័គ្រចិត្តវៀតណាម ក៏បានតាមចាប់ប្រជាជនមួយចំនួននៅក្នុងភូមិ រួមទាំងខ្ញុំដែរ ដោយសង្ស័យថា មានទំនាក់ទំនងជាមួយយោធាខ្មែរក្រហម។ ដោយសារភ័យខ្លាច ខ្ញុំ និងប្រជាជនប្រមាណប្រាំនាក់ទៀតបាននាំគ្នារត់គេចខ្លួន និងបានទៅរស់នៅក្នុងព្រៃក្បែរភ្នំគូលែន។ មួយរយៈក្រោយមក ខ្ញុំ និងសមាជិកនៅក្នុងក្រុមបានជួបនឹងយោធាខ្មែរក្រហមដែលឈរជើងនៅសមរភូមិភ្នំគូលេន។

បន្ទាប់ពីបានស្គាល់កងយោធាខ្មែរក្រហមទាំងនោះ ខ្ញុំនិងសមាជិកក្រុមក៏បាននាំគ្នារស់នៅ និងធ្វើកិច្ចការផ្សេងៗឲ្យយោធាខ្មែរក្រហម។ ក្រោយមក យោធាខ្មែរក្រហមទាំងនោះ បានឃោសនាអូសទាញក្រុមរបស់ខ្ញុំឲ្យចូលរួមក្នុងចលនាតស៊ូរបស់ខ្លួន ដោយបាននិយាយថា យួននឹងចាប់អារកប្រសិនបើខ្ញុំនាំគ្នាត្រលប់ទៅភូមិវិញ។ ឮបែបនេះ ខ្ញុំនិងសមាជិកក្រុមភិតភ័យ និងមិនហ៊ានត្រលប់ទៅផ្ទះទេ។ យើងទាំងអស់គ្នាបានបន្តរស់នៅជាមួយខ្មែរក្រហមទៀត។

លុះដល់ចុងឆ្នាំ១៩៨១ ខ្មែរក្រហមបានបញ្ចូលខ្ញុំ និងសមាជិកក្រុមឲ្យចូលជាយោធាពេញសិទ្ធិ ក្រោមការបញ្ជាផ្ទាល់ពី តានី ប្រធានវរសេនាធំលេខ៣៣០ ក្រោមចំណុះឲ្យកងពលលេខ៩៨០ ដែលដឹកនាំដោយ តាសារ៉ាយ។ នៅក្នុងវរសេនាធំលេខ៣៣០ មានកម្លាំងសរុបជាងមួយរយនាក់។ នៅទីនោះ ខ្ញុំរួមជាមួយកងកម្លាំងខ្មែរក្រហម បានប្រយុទ្ធគ្នាជាញឹកញាប់ ជាមួយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាម។ នៅពេលវាយប្រយុទ្ធនៅសមរភូមិដីក្រែង វរសេនាធំលេខ៣៣០ ទទួលបានជំនួយពី តាម៉ុក ដោយមេបញ្ជាការខ្មែរក្រហមដែលគ្រប់គ្រងកម្លាំងទាំងអស់ ត្រូវទៅទទួលលុយពី តាម៉ុក នៅតំបន់អន្លង់វែង ដើម្បីយកមកទិញសម្ភារ និងស្បៀងអាហារដើម្បីផ្គត់ផ្គង់ដល់កងទ័ពនៅសមរភូមិមុខៗ ទោះជាមានការផ្គត់ផ្គង់ស្បៀងអាហារពី តាម៉ុក មួយផ្នែកធំក៏ដោយ ក៏ការហូបចុកប្រចាំថ្ងៃរបស់ខ្ញុំហាក់នៅមិនទាន់មានភាពគ្រប់គ្រាន់នៅឡើយ។ ដូច្នេះខ្ញុំ និងសមាជិកក្រុមត្រូវដើរធ្វើឃោសនាដល់ប្រជាជនដើម្បីសុំជំនួយបន្ថែម ដូចជា ស្រូវ អង្ករ ដើម្បីផ្គត់ផ្គង់កងកម្លាំងដែលកំពុងតែប្រយុទ្ធតទល់ជាមួយកងទ័ពវៀតណាម។ នៅពេលដល់រដូវដាំដុះនិងប្រមូលផលម្តងៗ ខ្ញុំនិងសមាជិកក្រុមបានជួយប្រជាជន ដកស្ទូង ច្រូតកាត់ និងភ្ជួររាស់ ដើម្បីឲ្យប្រជាជនស្រឡាញ់ និងស្រណោះអាណិតយើង ជាពិសេសផ្តល់ការរាយការណ៍មកដល់យើង។

រហូតដល់ឆ្នាំ១៩៨៦ ខ្ញុំត្រូវរបួសបាក់ដៃ ដោយសារការបាញ់ប្រហារ ពីកងកម្លាំងរបស់រដ្ឋាភិបាល។ កងកម្លាំងរដ្ឋាភិបាលបានស៊ើបដឹងទីតាំងដែលខ្ញុំនិងសមាជិកក្រុម បោះទីតាំងតាមរយៈប្រជាជនដែលកងកម្លាំងរដ្ឋាភិបាលចាប់ខ្លួនបាន។ ប្រជាជនទាំងនោះតែងតែមកកាប់ឈើពីក្នុងព្រៃក្បែរទីតាំងរបស់ខ្ញុំជារៀងរាល់ថ្ងៃដើម្បីទៅលក់ឲ្យអ្នកទន្លេ ហើយធ្លាប់ហូបបាយនៅកន្លែងខ្ញុំជាញឹកញាប់ទៀតផង។ ប្រជាជនទាំងនោះ ត្រូវបានកងទ័ពរដ្ឋាភិបាលចាប់ខ្លួននៅពេលដឹកឈើចេញពីព្រៃ ហើយបញ្ជាឲ្យនាំផ្លូវមកកាន់ទីតាំងឈរជើងរបស់ខ្ញុំវិញ។ ខ្ញុំ និងកងកម្លាំងដែលបានបោះតង់ស្នាក់នៅមិនឆ្ងាយពីផ្លូវរទេះ ពុំបានដឹងពីហេតុការណ៍នេះឡើយ រហូតដល់មានការផ្ទុះអាវុធឡើង។ បន្ទាប់ពីផ្ទុះអាវុធភ្លាម ខ្ញុំបានរងរបួសត្រង់ដៃ ចំណែកកងកម្លាំងរបស់ខ្ញុំក៏បានវាយរុញច្រានកងទ័ពរដ្ឋាភិបាលឲ្យដកថយវិញដែរ។ បន្ទាប់មក ខ្ញុំត្រូវបានកម្លាំងនៅក្នុងអង្គភាពបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យ។ មួយរយៈក្រោយមក ដៃរបស់ខ្ញុំបានជាសះស្បើយ ហើយក៏ត្រូវបានថ្នាក់លើរបស់ខ្ញុំបញ្ជូនឲ្យទៅឈរជើងនៅសមរភូមិដីក្រែងវិញ។ នៅទីនោះ មានការប្រយុទ្ធគ្នាជាញឹកញាប់ដោយ ដូច្នេះខ្ញុំត្រូវត្រៀមប្រយុទ្ធជាប្រចាំ។ រយៈពេលបីខែក្រោយមក ខ្ញុំត្រូវរបួសត្រង់ភ្លៅម្តងទៀត ដោយសារវាយប្រយុទ្ធជាមួយកងទ័ពវៀតណាម។ នៅពេលរបួសភ្លៅរបស់ខ្ញុំបានធូរស្បើយ ខ្ញុំក៏បានធ្វើដំណើរមកនៅជំរំដប់ម្ភៃនៅលើភ្នំដងរែកវិញ ព្រោះជាកន្លែងដែលមានសុវត្ថិភាព។

រហូតដល់ឆ្នាំ១៩៨៧ ខ្ញុំនិងកងកម្លាំងខ្មែរក្រហមដែល

រស់នៅជំរំដប់ម្ភៃ ត្រូវបានថ្នាក់លើបញ្ជូនឲ្យត្រលប់មកក្រោម ហើយខ្ញុំធ្វើដំណើរដោយថ្មើរជើងមកសមរភូមិដីក្រែនវិញ។ ខ្ញុំបានវាយប្រយុទ្ធតទល់ជាមួយកងទ័ពវៀតណាមបន្តទៀត មុនពេលដែលកងទ័ពវៀតណាម ដកចេញពីប្រទេសកម្ពុជា នៅឆ្នាំ១៩៨៩។ ទោះបីមិនមានវត្តមានកងទ័ពវៀតណាម នៅកម្ពុជាក៏ដោយ ក៏ស្ថានការណ៍នៅក្នុងប្រទេសកម្ពុជាហាក់នៅមិនទាន់ស្ងប់ស្ងាត់ដែរ គឺកងកម្លាំងខ្មែរក្រហម និងរដ្ឋាភិបាលនៅភ្នំពេញនៅបន្តវាយប្រយុទ្ធគ្នាឥតឈប់ឈរ ជាពិសេសគឺក្នុងសមរភូមិដីក្រែនដែលខ្ញុំឈរជើងតែម្តង។

រហូតដល់ឆ្នាំ១៩៩២ នៅមុនពេលបោះឆ្នោតមួយឆ្នាំ ខ្ញុំបានធ្វើដំណើរពីសមរភូមិដីក្រែនមកកាន់តំបន់អន្លង់វែងម្តងទៀត ដោយខ្ញុំបានធ្វើដំណើរដោយថ្មើរជើងជាមួយ តានី គឺជាមេបញ្ជាការរបស់ខ្ញុំ និងកងកម្លាំងខ្មែរក្រហមប្រមាណ ៣០នាក់ផ្សេងទៀត ឆ្លងកាត់តាមព្រៃស្អាក ដោយចំណាយពេលពីរថ្ងៃ។ នៅតាមផ្លូវ យើងពុំបានជួបប្រទះនឹងការវាយប្រយុទ្ធគ្នាទេ ដោយសារតែសភាពការណ៍នៅពេលនោះបានស្ងប់ស្ងាត់មួយរយៈ។ ក្រោយពេលទៅដល់តំបន់អន្លង់វែង យើងក៏បានបន្តដំណើរទៅកាន់ជំរំអូរត្រាវ ក្នុងទឹកដីថៃ ដើម្បីប្រមូលផ្តុំកម្លាំងឡើងវិញ។

នៅក្នុងឆ្នាំ១៩៩២ដដែល ខ្ញុំក៏លាឈប់ពីយោធា ដោយបានផ្លាស់ឈ្មោះ ពីយោធាដែលត្រូវឡើងទៅប្រយុទ្ធនៅសមរភូមិ មកជាយោធាពិការវិញដើម្បីគ្រប់គ្រងក្រុមគ្រួសារកងទ័ពនៅសមរភូមិក្រោយ។ នៅពេលនោះ ខ្ញុំបានគិតថា នៅសល់តែកម្លាំងខ្មែរ និងខ្មែរប៉ុណ្ណោះ ហេតុនេះខ្ញុំមិនចង់ធ្វើសង្គ្រាមតទៀតទេ។ ខ្ញុំមានគំនិតចង់រត់ចូលទៅសារភាពជាមួយរដ្ឋាភិបាលជាយូរណាស់ហើយ ប៉ុន្តែខ្ញុំខ្លាចខាងរដ្ឋាភិបាលមិនទទួលស្គាល់ ហើយសម្លាប់ចោល ដូច្នេះហើយទើបខ្ញុំបន្តរស់នៅជាមួយខ្មែរក្រហម។ លុះដល់ពេលមានសមាហរណកម្មនៅឆ្នាំ១៩៩៨ ខ្ញុំមានការសប្បាយចិត្តយ៉ាងខ្លាំង ដោយបានរួចផុតពីការធ្វើសង្គ្រាម និងទុក្ខវេទនា។ ខ្ញុំគ្មានបំណងប្រាថ្នាអ្វីក្រៅតែពីចង់បានសន្តិភាព សម្រាប់ឲ្យកូនចៅជំនាន់ក្រោយរបស់យើង រស់នៅដោយភាពសម្បូរសប្បាយ និងបានរៀនបានសូត្រឡើយ។

**ស្ងួត វិចិត្រ**


ផ្លូវលំស្ថិតនៅ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ (រូបថត៖បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ដំណឹងជ្រើសរើសនិស្សិតស្ម័គ្រចិត្ត

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសនិស្សិតស្ម័គ្រចិត្តចំនួន០៥រូប (អ្នកសរសេរអត្ថបទ ២រូប អ្នកបកប្រែ ២រូប និងក្រាហ្វិកកុំព្យូទ័រ ១រូប) ក្នុងចំណោមនិស្សិតសាកលវិទ្យាល័យនានាឲ្យមកបម្រើការងារចាប់ពីខែមិថុនា ឆ្នាំ២០១៩ ដល់ខែសីហា ឆ្នាំ២០១៩ ហើយអាចបន្តទៅតាមគុណភាពការងារ។

១) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការបកប្រែអត្ថបទពីភាសាអង់គ្លេសមកជាភាសាខ្មែរ ឬពីភាសាខ្មែរទៅភាសាអង់គ្លេស។ អត្ថបទដែលនឹងត្រូវបកប្រែគឺអត្ថបទខ្លីនិងវែង ដែលមានលក្ខណៈប្រវត្តិសាស្ត្រ ច្បាប់ និងអត្ថបទពិភាក្សានានា សរសេរដោយមេធាវី សាស្ត្រាចារ្យ អ្នកស្រាវជ្រាវបរទេស ឬសរសេរ ដោយប្រជាជនកម្ពុជា។

២) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការសរសេរអត្ថបទ សម្រាប់បោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តី «ស្វែងរកការពិត» និងគេហទំព័រ http://www.khmerrougehistory.org

៣) អ្នកក្រាហ្វិកកុំព្យូទ័រ ឬរចនាទស្សនាវដ្តី តម្រូវឲ្យចេះប្រើប្រាស់កម្មវិធី InDesign និងកម្មវិធីផ្សេងៗទៀត ដែលទាក់ទងនឹងការរចនាទស្សនាវដ្តី។

ក្នុងអំឡុងពេលធ្វើការងារស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និស្សិតស្ម័គ្រចិត្តទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យចូលរួមវគ្គបណ្តុះបណ្តាល និងបន្តការសិក្សានៅតាមសាកលវិទ្យាល័យនានា ដែលជាដៃគូសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចជា ព្រះរាជាណាចក្រថៃ ហ្វីលីពីន ហុងកុង ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ជាដើម។

**លក្ខខណ្ឌសម្រាប់និស្សិតដែលអាចដាក់ពាក្យបាន មានដូចខាងក្រោម ៖**

១) និស្សិតកំពុងសិក្សាតាមសាកលវិទ្យាល័យរដ្ឋ និងឯកជននានា ដែលអាចប្រើប្រាស់ភាសាអង់គ្លេស។

២) មានអត្តចរិតថ្លៃថ្នូរ ម៉ឺងម៉ាត់ ព្យាយាម និងមានទំនួលខុសត្រូវចំពោះការងារ។

៣) មានចំណាប់អារម្មណ៍ផ្នែកការងារប្រវត្តិសាស្ត្រ ច្បាប់ និងសារព័ត៌មាន។

និស្សិតដែលមានលក្ខណៈសម្បត្តិដូចខាងលើ ហើយមានចំណាប់អារម្មណ៍នឹងការងារស្ម័គ្រចិត្តនេះ សូមផ្ញើពាក្យសុំបម្រើការងារមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង៥ល្ងាច។

**សូមភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ៖**

១) លិខិតសុំធ្វើការងារ ១ច្បាប់ (Cover Letter) ដោយបញ្ជាក់អំពីទឹកចិត្តផ្ទាល់ខ្លួនចំពោះការងារឲ្យបានច្បាស់លាស់ និងក្បោះក្បាយ ដែលសរសេរដោយសាម៉ីខ្លួន។

២) ប្រវត្តិរូបសង្ខេប ១ច្បាប់ (Resume)។

សូមផ្ញើមកកាន់អាសយដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬ អ៊ីម៉ែល៖ truthbunthorn.s@dccam.org។ ប្រសិនបើមានចម្ងល់ សូមទូរសព្ទមកលេខ៖ ០២៣ ២១៤ ០០៩ ឬ ០១២ ៩៩៦ ៧៥០។ **សូមអរគុណ!**

# ដោយសារសង្គ្រាមទើបខ្ញុំបានមករស់នៅស្រុកវាលវែង

ស្រុកវាលវែងស្ថិតនៅក្នុងខេត្តពោធិសាត់ និងមានចម្ងាយប្រមាណ១៣០គីឡូម៉ែត្រពីទីរួមខេត្ត ដោយយើងត្រូវធ្វើដំណើរតាមផ្លូវលេខជាតិ៥៥។ ស្រុកវាលវែងពីសម័យខ្មែរក្រហមស្ថិតនៅក្នុងតំបន់៦ ភូមិភាគពាយ័ព្យ។ ស្រុកនេះសម្បូរទៅដោយព្រៃ និងឈើល្អៗជាច្រើនប្រភេទ ដូចជា ៖ បេង នាងនួន ធ្នង់ ស្រឡៅ កកោះ និងក្រញូង ជាដើម។ មិនត្រឹមតែប៉ុណ្ណោះ ស្រុកវាលវែងក៏សម្បូរសត្វព្រៃជាច្រើនប្រភេទ ដែរដូចជា៖ ដំរី ខ្លា ទន្សោង ខ្ទីង ឈ្លូស ជ្រូកព្រៃដោយសារតំបន់នេះសម្បូរជ្រោះ និងភ្នំៗ ស្រុកវាលវែងមានភូមិសាស្ត្រខាងកើតជាប់ស្រុកក្រវាញ ខាងជើងជាប់ស្រុកសំឡូតក្នុងខេត្តបាត់ដំបង ខាងត្បូងជាប់ខេត្តកោះកុង និងខាងលិចជាប់ខេត្តត្រាត ប្រទេសថៃ។ សព្វថ្ងៃស្រុកវាលវែង មានឃុំចំនួន៥ ដូចជា ឃុំអន្លង់រាប ឃុំក្រពើពីរ ឃុំប្រម៉ោយ និងឃុំថ្មដា។ ប្រជាជនចំណូលថ្មីដែលបានចូលមករស់នៅតំបន់វាលវែងនេះ ភាគច្រើន គឺជាអតីតយោធា និងកម្មាភិបាលខ្មែរក្រហម ដែលបានរត់ភៀសខ្លួនបន្ទាប់ពីរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩ និងក្នុងអំឡុងសង្គ្រាមស៊ីវិលក្នុងទសវត្សរ៍ឆ្នាំ១៩៨០។

គឹម ឡៃ គឺជាអតីតនារីពេទ្យខ្មែរក្រហមម្នាក់ ដែលបានចូលមករស់នៅស្រុកវាលវែងតាំងពីឆ្នាំ១៩៨៥ រហូតដល់



រូបថតនៅ ស្រុកវាលវែង ខេត្តពោធិសាត់ ខែឧសភា ឆ្នាំ២០១១ (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បច្ចុប្បន្នៗ សព្វថ្ងៃ គីម ឡៃ មានអាយុ៦៣ឆ្នាំ បានរៀបរាប់ថា៖ ខ្ញុំមានស្រុកកំណើតនៅភូមិថ្មក្រែ ឃុំថ្មក្រែ ស្រុកក្រចេះ (បច្ចុប្បន្នស្រុកចិត្របុរី) ខេត្តក្រចេះ។ ខ្ញុំមានឪពុកឈ្មោះ គង់ គីប ម្តាយឈ្មោះ ប៉ាន់ សាមីន និងមានបងប្អូនពីរនាក់ ស្រីមួយ ប្រុសមួយ។ ឪពុកម្តាយខ្ញុំ ប្រកបមុខរបរធ្វើស្រែចម្ការនៅពេលនោះ។ ខ្ញុំបានរស់នៅជាមួយឪពុកម្តាយរបស់ខ្ញុំ និងបានរៀនសូត្រនៅសាលាបឋមសិក្សាថ្មក្រែបានត្រឹមថ្នាក់ទី១០ (ចាស់)។ ក្រោយមក ខ្ញុំបានឈប់រៀនដោយសារប្រទេសជាតិមានសង្គ្រាម និងរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ នៅឆ្នាំ១៩៧០។ នៅពេលនោះសង្គ្រាមក៏ចាប់ផ្តើមផ្ទុះឡើងកាន់តែខ្លាំងនៅទូទាំងប្រទេសកម្ពុជា។ ចលនាបដិវត្តន៍របស់ខ្មែរក្រហម និងទាហានវៀតកុង (វៀតណាមខាងជើង) ក៏បានចូលមកក្នុងភូមិកាន់តែច្រើន ដែលធ្វើឲ្យប្រជាជនមានការភ័យខ្លាចយ៉ាងខ្លាំង។ ចំណែកកងទ័ពខាងរដ្ឋាភិបាលសាធារណរដ្ឋខ្មែររបស់ លន់ នល់ ក៏បានវាយប្រហារ និងទម្លាក់គ្រាប់បែកទៅលើទីតាំងរបស់ខ្មែរក្រហម និងវៀតកុងទាំងនោះជាបន្តបន្ទាប់។ ប៉ុន្តែការទម្លាក់គ្រាប់នោះបានបណ្តាលឲ្យប្រជាជនរងរបួស និងស្លាប់ជាច្រើននាក់ទៅវិញ។ ស្របពេលនោះ កម្លាំងយុវជនរស់នៅក្នុងភូមិខ្លះក៏ត្រូវបានកងទ័ព លន់ នល់ កេណ្ឌយកទៅធ្វើទាហាន និងបញ្ជូនឲ្យឡើងទៅប្រយុទ្ធនៅលើសមរភូមិដែរ។

ខ្ញុំបានស្ម័គ្រចូលរួមជាមួយចលនាបដិវត្តន៍ខ្មែរក្រហម នៅឆ្នាំ១៩៧០ បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ភ្លាមៗ។ ចូលដំបូង ខ្ញុំនៅក្នុងអង្គភាពសមាគមនារីភូមិ។ មកដល់ឆ្នាំ១៩៧១ អង្គការចាត់តាំងខ្ញុំឲ្យចូលអង្គភាពមន្ទីរពេទ្យស្រុក ដើម្បីជួយព្យាបាលប្រជាជន និងកងយុវជន-យុវនារីនៅតាមអង្គភាព ដែលមានជំងឺ និងរងរបួសដោយសារឡើងទៅប្រយុទ្ធតទល់នឹងកងទ័ពរបស់ លន់ នល់។ កាលនោះមន្ទីរពេទ្យមិនមានថ្នាំល្អៗសម្រាប់ព្យាបាលអ្នកជំងឺទេ ថ្នាំភាគច្រើនផលិតខ្លួនឯងដោយយកឫស ឈើមកផ្សំ សូនជាគ្រាប់សម្រាប់អ្នកជំងឺលេប។

នៅចន្លោះពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៤ ខ្ញុំត្រូវបានអង្គការបញ្ជូនមកធ្វើការនៅមន្ទីរពេទ្យតំបន់៥០៥ ដែលកាលនោះគណៈតំបន់ឈ្មោះ យី គួន បានចាត់តាំងឲ្យបុគ្គលិកមន្ទីរពេទ្យទាំងអស់យកចិត្តទុកដាក់ព្យាបាលអ្នករបួសជាយោធាខ្មែរក្រហមដែលវាយប្រយុទ្ធជាមួយកងទ័ព លន់ នល់។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលរបបខ្មែរក្រហមឡើងកាន់អំណាចទូទាំងប្រទេស អង្គការបានចាត់តាំងអង្គភាពយោធាមួយចំនួនធ្វើស្រែ ខ្លះបានធ្វើជាកម្មកររោងចក្រ ខ្លះទៀតទៅការពារព្រំដែននៅខាងស្រុកស្នួល ខេត្តក្រចេះ។ ខ្ញុំមានវាសនាបានធ្វើនារីពេទ្យប្រចាំតំបន់៥០៥ ដដែល ដែលកាលនោះមានបុគ្គលិកពេទ្យសរុបទាំងប្រុសទាំងស្រីមានចំនួន ៣០០នាក់ ដោយរាប់បញ្ចូលទាំងអង្គភាពព្យាបាលជំងឺទូទៅ



ជាងចម្លាក់នៅ ស្រុកវាលវែង ខេត្តពោធិសាត់ កំពុងឆ្លាក់រូបព្រះ
ខែឧសភា ឆ្នាំ២០១១
(រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អគ្គភាពពេទ្យផ្នែកផលិតសេរ៉ូមនិងអគ្គភាពស្លថ្នាំ។ នៅចន្លោះពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ ប្រជាជនភាគច្រើនកើតជំងឺហើម ដោយសារខ្វះខាតអាហាររូបត្ថម្ភ ធ្វើការផារលើសកម្លាំង និងហូបអាហារគ្មានអនាម័យជាដើម។ នៅឆ្នាំ១៩៧៨ ពេលមានកម្មាភិបាលភូមិភាគនិរតីចូលមកគ្រប់គ្រងតំបន់៥០៥ កម្មាភិបាលខ្មែរក្រហមចាស់ដែលធ្លាប់បានគ្រប់គ្រងតំបន់៥០៥ មួយចំនួន ត្រូវអង្គការចាប់ខ្លួនដោយមិនបានដឹងមូលហេតុ។ មិនយូរប៉ុន្មានអង្គការបានចាប់ខ្លួនប្រធានមន្ទីរពេទ្យមួយចំនួនថែមទៀត រួមមានឈ្មោះ រស់ (អនុធនសិស្ស) ឡែម (ភេទស្រី) នាថ និង យ៉ាត។ នៅឆ្នាំ១៩៧៨ បុគ្គលិកនៅអគ្គភាពពេទ្យមានការព្រួយបារម្ភយ៉ាងខ្លាំងដោយសារការបន្តចាប់ខ្លួននេះ។ នៅខណៈនោះក៏មានយោធារងរបួសកាន់តែច្រើនដោយសារការឡើងទៅវាយប្រយុទ្ធជាមួយកងទ័ពវៀតណាម ត្រូវបានបញ្ជូនតាមឡានមកព្យាបាលនៅមន្ទីរពេទ្យតំបន់ស្ទើររាល់ថ្ងៃ ហើយអ្នករបួសខ្លះក៏ត្រូវបានដឹកតាមកាណូតបន្តទៅព្យាបាលនៅភ្នំពេញទៀត។ ទោះបីក្រុមគ្រូពេទ្យខិតខំជួយព្យាបាលយ៉ាងណាក៏ដោយក៏នៅមានអ្នករងរបួសស្លាប់ច្រើនដែរ ដោយសារខ្វះថ្នាំពេទ្យព្យាបាល។ សាកសពទាំងនោះភាគច្រើនមានវ័យក្មេង ត្រូវបានដឹកជញ្ជូនតាមឡានយកទៅកប់ដោយមិនមានសាច់ញាតិ ឬកូនចៅមកទទួលឡើយ។

ខ្ញុំបានធ្វើការនៅមន្ទីរពេទ្យ តំបន់៥០៥ រហូតដល់ឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមវាយចូលមកប្រទេសកម្ពុជា។ ពេលនោះ ខ្ញុំមិនហ៊ានរត់ត្រលប់ទៅរកស្រុកកំណើតដើម្បី



ទេសភាពស្រុកវាលវែង ខេត្តពោធិសាត់ ខែឧសភា ឆ្នាំ២០១១ (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជួបឪពុកម្តាយបងប្អូនឡើយ ដោយទី១) ខ្ញុំគិតថា ខ្ញុំគឺជាកម្មាភិបាលពេទ្យ ដូច្នេះខ្លាចកងទ័ពវៀតណាមចាប់ និងធ្វើបាប ទី២) ខ្ញុំគិតថា ប្រជាជនស្អប់កម្មាភិបាលខ្មែរក្រហមធ្លាប់ធ្វើបាបខ្លួន ដូច្នេះហើយទើបខ្ញុំសម្រេចចិត្តរត់ចូលព្រៃម្តងទៀត ជាមួយនារីពេទ្យខ្មែរក្រហមរាប់រយនាក់ទាំងមិនស្គាល់ទិសតំបន់។ កាលនោះ ខ្ញុំមានអាយុ២០ឆ្នាំ។ នៅក្នុងព្រៃខ្ញុំបានជួបរឿងរ៉ាវជាច្រើនដែលយើងមិននឹកស្មានដល់។ ខ្ញុំបានឃើញមនុស្សជាច្រើនបានស្លាប់ អ្នកខ្លះស្លាប់នៅលើអង្រឹង អ្នកខ្លះស្លាប់នៅក្រោមដើមឈើជាដើម។ អ្នកទាំងនោះ ស្លាប់ដោយសារតែខ្វះទឹក អត់អាហារ និងកើតជំងឺគ្រុនចាញ់។ ខ្ញុំមានសំណាងបានរត់ចូលព្រៃជាមួយអង្គភាពពេទ្យសរុបជាង៣០០នាក់ ប៉ុន្តែក្រោយមកសមាជិកពេទ្យខ្លះទៀតបានរត់បែកគ្នា និងខ្លះទៀតបានស្លាប់ នៅសល់សមាជិកសរុបប្រហែល៥០នាក់ប៉ុណ្ណោះ បានឡើងដល់ភ្នំដងរែក សំដៅមកស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ខ្ញុំបានជួប តាម៉ុក នៅពេលដែល តាម៉ុក កំពុងប្រមូលកម្លាំងយុវជនយុវនារីទាំងអស់ឲ្យចូលរួមប្រយុទ្ធប្រឆាំងជាមួយកងទ័ពវៀតណាម។ ខ្ញុំបានចូលអង្គភាពយោធា ក្នុងកងពល៦១២ ដែលមានប្រធានកងពលឈ្មោះ តាហឿន និងតាឈាន។

នៅឆ្នាំ១៩៨២ តាម៉ុក បានរៀបចំឲ្យខ្ញុំមានប្តីឈ្មោះ ជ័យ សារី។ បន្ទាប់ពីរៀបការរួច តាម៉ុក បានបញ្ជូនខ្ញុំ និងប្តីទៅសមរភូមិកោះកុងដើម្បីវាយប្រយុទ្ធតទល់ជាមួយកងកម្លាំងរដ្ឋាភិបាល និងកងទ័ពវៀតណាម។ នៅទីនោះ ខ្ញុំមានផ្ទៃពោះកូនបីខែ ចំពេលដែលអង្គការចាត់តាំងប្តីរបស់ខ្ញុំឲ្យចុះទៅធ្វើការនៅសមរភូមិខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តកំពង់ឆ្នាំង។ នៅពេលប្តីរបស់ខ្ញុំត្រលប់មកវិញ ខ្ញុំកើតបានកូនស្រីមួយអាយុពីរខែរួចទៅហើយ។ នៅពេលដែលកូនរបស់ខ្ញុំធំបន្តិច ខ្ញុំត្រូវជួយដឹកជញ្ជូនគ្រាប់ទៅឲ្យ យោធាខ្មែរក្រហមនៅសមរភូមិមុខ។ នៅឆ្នាំ១៩៨៥ កងទ័ពវៀតណាមបានវាយសម្រុកយ៉ាងខ្លាំងក្លាទៅលើមូលដ្ឋានយោធារបស់ខ្មែរក្រហម ធ្វើឲ្យយោធា និងគ្រួសារខ្មែរក្រហមរត់ភៀសខ្លួនចូលទៅក្នុងទឹកដីថៃ។ ខ្ញុំ និងកូន បានរត់ទៅរស់នៅជំរំសុខសាន្តបានមួយរយៈទើបត្រឡប់មករស់នៅស្រុកវាលវែង ខេត្តពោធិ៍សាត់វិញ។ ពេលខ្ញុំមកដល់ដំបូង ខ្ញុំសង្កេតឃើញស្រុកនេះមានព្រៃឈើដុះដុំជិត និងសត្វព្រៃជាច្រើនប្រភេទ។ ទោះបីខ្ញុំត្រឡប់មករស់នៅក្នុងទឹកដីខ្មែរហើយក៏ដោយ ក៏នៅពេលនោះសង្គ្រាមនៅតែបន្តឡើង ហើយប្តីរបស់ខ្ញុំត្រូវចេញទៅប្រយុទ្ធនៅសមរភូមិមុខជាញឹកញាប់ដែលធ្វើឲ្យខ្ញុំមានការព្រួយបារម្ភជានិច្ច។ លុះត្រាតែបានឃើញប្តីរបស់ខ្ញុំត្រលប់មកផ្ទះវិញ ទើបខ្ញុំបានធូរស្បើយ និងសប្បាយចិត្ត។

នៅឆ្នាំ១៩៩៣ ទោះបីមានការរៀបចំបោះឆ្នោតដែលចូលរួមពីគ្រប់ភាគីជម្លោះ និងពាក់ព័ន្ធដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិក៏ដោយ ក៏កម្លាំងខ្មែរក្រហមមិនព្រមចូលរួមដែរ ហើយបានធ្វើសង្គ្រាមបន្តទៀត។ នៅឆ្នាំ១៩៩៦ កម្មាភិបាល និងយោធាខ្មែរក្រហមមួយចំនួនធំនៅប៉ៃលិន ក្រោមការដឹកនាំរបស់ អៀង សារី បានចុះចូលជាមួយរដ្ឋាភិបាលនៅភ្នំពេញ។ ចំណែកកម្មាភិបាល និងយោធាខ្មែរក្រហមមួយចំនួនទៀតដែលមិនទុកចិត្តរដ្ឋាភិបាល និងការចុះចូលនេះ ក៏បានរត់ទៅចូលរួមជាមួយ តាម៉ុក នៅអន្លង់វែង និងមួយចំនួនទៀតបានមកនៅខាងស្រុកវាលវែង។

មកដល់ឆ្នាំ១៩៩៨ ទើបកម្លាំងយោធាដែលនៅសេសសល់ចុងក្រោយរបស់ខ្មែរក្រហមនៅតំបន់អន្លង់វែង បានធ្វើសមាហរណកម្ម ចុះចូលជាមួយរាជរដ្ឋាភិបាលភ្នំពេញ ក្រោមគោលនយោបាយធានានូវអាយុជីវិត ទ្រព្យសម្បត្តិ តួនាទីដល់អតីតយោធាខ្មែរក្រហមទាំងនោះ។ ខ្ញុំបានសប្បាយរីករាយយ៉ាងខ្លាំង ព្រោះបានរស់នៅជួបជុំប្តី និងកូនៗវិញ។ ខ្ញុំបានប្រកបមុខរបរធ្វើស្រែចម្ការនៅភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ទោះបីមានជីវភាពមិនសូវធូរធាក៏ដោយ។ ចំណែកកូនចៅរបស់ខ្ញុំក៏អាចចូលរៀននៅសាលា ហើយខ្ញុំក៏អាចទៅវត្តធ្វើបុណ្យ ទៅមន្ទីរពេទ្យព្យាបាលជំងឺ និងទៅផ្សារទិញរបស់របរដែរ។

*សុខ វណ្ណៈ*

# ហួន យន ៖ អតីតគ្រូពេទ្យមើលថែជំងឺ តាម៉ុក

ខ្ញុំឈ្មោះ ហួន យន កើតនៅក្នុងឆ្នាំ១៩៥១ និងមានស្រុកកំណើតនៅភូមិត្រពាំងគ្រាច ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ ឪពុកខ្ញុំឈ្មោះ ហួន ហៀង និងម្តាយឈ្មោះ វ៉ែន អ៊ីន។



ហួន យន (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំគឺជាកូនទី១នៅក្នុងចំណោមបងប្អូន៥នាក់គឺ ស្រី២នាក់ និងប្រុស៣នាក់។ កាលពីនៅកុមារភាព ខ្ញុំបានទៅរៀននៅសាលាក្នុងវត្តលាយបូរ រហូតដល់ថ្នាក់ទី៧។ ក្នុងឆ្នាំ១៩៦២ ខ្ញុំក៏បានឈប់រៀនដោយសារគ្រួសាររបស់ខ្ញុំផ្លាស់ទីលំនៅទៅរស់នៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់។ រហូតមកដល់ឆ្នាំ១៩៦៨ ខ្ញុំបានវិលត្រឡប់មករស់នៅស្រុកកំណើតវិញ ដោយខ្ញុំបានបួសជាព្រះសង្ឃនៅក្នុងវត្តលាយបូរ រហូតដល់ឆ្នាំ១៩៧០។

អំឡុងឆ្នាំ១៩៧១ ខ្មែរក្រហមចាប់ផ្តើមធ្វើការជ្រើសរើសយោធា ដែលនៅពេលនោះខ្ញុំត្រូវបានជ្រើសរើសឲ្យចូលទៅហាត់កងទ័ពនៅក្នុងភូមិភាគនិរតី។ តាម៉ុក គឺជាអ្នកគ្រប់គ្រងតំបន់នោះ។ ខ្ញុំធ្វើជាយោធាខ្មែរក្រហមដល់ ឆ្នាំ១៩៧៣ ក៏ត្រូវបានតាម៉ុក ផ្លាស់ប្តូរខ្ញុំឲ្យទៅធ្វើជាពេទ្យនៅក្នុងកងពលលេខ២។ តាវ៉ើន គឺជាប្រធានដែលគ្រប់គ្រងនៅក្នុងកងពល។ គាត់ គឺជាកូនប្រសាររបស់តាម៉ុក។ ពេលនោះគ្រូពេទ្យឈ្មោះ រឿន គឺជាពេទ្យចាស់នៅក្នុងកងពលលេខ២ បានបង្ហាត់បង្រៀនខ្ញុំអំពីវិធីសាស្ត្រសង្គ្រោះអ្នករបួសនៅក្នុងសមរភូមិ ដូចជា របៀបរុំរបួស របៀបចងរបួស អ្នកបាក់ឆ្អឹងដងកាំបិត បាក់ឆ្អឹងជើង និងបាក់ឆ្អឹងក្បាលជាដើម។ ក្រោយមកទៀត តាម៉ុក បានបញ្ជូនខ្ញុំឲ្យទៅរៀនពេទ្យធ្មេញនៅទីក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៧៥។ ខ្ញុំបានរៀនអំពីរបៀបព្យាបាលធ្មេញពុក របៀបត្បារយកសរសៃ របៀបដាក់ថ្នាំទៅក្នុងឫសធ្មេញ និងរបៀបថតធ្មេញពីបុរសម្នាក់ឈ្មោះ ធុក (ឈ្មោះដើម ឌី ផុន)។ ធុក គឺជាវេជ្ជបណ្ឌិតដែលធ្លាប់បានទៅរៀននៅប្រទេសបារាំង អស់រយៈពេល៦ឆ្នាំ ខាងឯកទេសព្យាបាលធ្មេញ។ ខ្ញុំរៀនជំនាញពេទ្យធ្មេញនេះរហូតដល់ឆ្នាំ១៩៧៨ ដោយខ្ញុំត្រូវរៀនទាំងទ្រឹស្តី និងការអនុវត្តន៍ជាក់ស្តែង។ ខ្ញុំរៀនទ្រឹស្តីពេលយប់ចាប់ពីម៉ោង៧យប់ រហូតដល់ម៉ោង៩យប់។ ចំណែកពេលថ្ងៃខ្ញុំត្រូវអនុវត្តន៍ជាក់ស្តែងតាមរយៈការព្យាបាលអ្នកជំងឺដោយ

ផ្ទាល់ៗ ក្រោយមក តាម៉ុក ក៏បានចាត់តាំងខ្ញុំឲ្យមករៀនពេទ្យផ្នែកវះកាត់នៅក្នុងខេត្តតាកែវៗ ខ្ញុំបានរៀនជំនាញវះកាត់ពី តា ដួន ជឿន (បងប្រុសរបស់ ដួន ប្រាសិទ្ធ) អស់រយៈពេលប្រហែល៧ខែ ដោយគាត់បានបង្រៀនខ្ញុំអំពីរបៀបវះពោះមនុស្ស របៀបកាត់ពោះវៀនធំ របៀបវះយកកូនចេញពីក្នុងពោះ និងរបៀបសម្រាលកូនជាដើមៗ អំឡុងពេលនោះខ្ញុំបានព្យាបាលយោធាខ្មែរក្រហមដែលរងរបួសដោយសារធ្វើសង្រ្គាមជាមួយនិងកងទ័ពវៀតណាម ដោយក្នុងមួយយប់ខ្ញុំវះកាត់តពោះវៀនយោធាបានតែ២នាក់ប៉ុណ្ណោះ ក្រោពីនេះ យោធាទាំងនោះត្រូវស្លាប់អស់ជាច្រើននាក់ៗ នៅក្នុងខែកក្កដា ឆ្នាំ១៩៧៨ អង្គការបានចាត់តាំងឲ្យខ្ញុំរៀបការជាមួយនារីម្នាក់ដែលជាគ្រូពេទ្យធ្វើការនៅកន្លែងជាមួយខ្ញុំៗ គាត់មានស្រុកកំណើតនៅភូមិគោដើងលែង ឃុំអង្គរការ ស្រុកត្រាំកក់ ខេត្តតាកែវៗ នៅដើមឆ្នាំ១៩៧៩ នៅពេលដែលកងទ័ពវៀតណាមវាយចូលមកដល់កន្លែងបន្ទាយទាហានដែលខ្ញុំកំពុងធ្វើការខ្ញុំក៏បានរត់ភៀសខ្លួនទៅតំបន់ជួរភ្នំដងរែកដែលមានព្រំប្រទល់ជាប់នឹងព្រំប្រទល់ប្រទេសថៃៗ អំឡុងពេលនោះ ខ្ញុំបានរស់នៅតំបន់អន្លង់វែងជាមួយ តាម៉ុក ដោយខ្ញុំមានតួនាទីគឺជាគ្រូពេទ្យមើលថែជំងឺរបស់គាត់ៗ ខ្ញុំបានរស់នៅអន្លង់វែងជាមួយ តាម៉ុក អស់រយៈពេលប្រហែល ១២ ឆ្នាំៗ ក្រោយមក ខ្ញុំបានចូលធ្វើការជាមួយអង្គការសហប្រជាជាតិនៅក្នុងជំរុំអូរត្រាវ ដោយខ្ញុំមានតួនាទីគឺជាគ្រូពេទ្យៗ

ក្នុងឆ្នាំ១៩៩៣ អ៊ុនតាក់ បានរៀបចំឲ្យមានការធ្វើមាតុភូមិនិវត្តន៍ដោយនាំប្រជាជនដែលរស់នៅក្នុងជំរំនានាឲ្យរត់ភៀសខ្លួនតាមព្រំដែនប្រទេសថៃ ឲ្យវិលត្រលប់មករស់នៅស្រុកកំណើតវិញៗ នៅពេលនោះខ្ញុំ និងគ្រួសារបានវិលត្រឡប់មករស់នៅក្នុងភូមិកណ្ដាល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យវិញ ដោយខ្ញុំនិងប្រពន្ធមានកូនចំនួន៥នាក់ ស្រី៣នាក់ ប្រុស២នាក់ៗ អំឡុងឆ្នាំ២០០០ ប្រពន្ធរបស់ខ្ញុំបានស្លាប់បាត់បង់ជីវិតៗ បន្ទាប់ពីប្រពន្ធរបស់ខ្ញុំស្លាប់អស់រយៈពេល៣ឆ្នាំ ខ្ញុំក៏បានសម្រេចចិត្តរៀបការជាមួយស្ត្រីម្នាក់ទៀតឈ្មោះ លុយ សាវ៉ាន់ ដែលត្រូវជាប្រពន្ធទី២របស់ខ្ញុំរហូតដល់សព្វថ្ងៃនេះៗ គាត់មានស្រុកកំណើតនៅភូមិអង្គនរាយណ៍ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវៗ ខ្ញុំ និងប្រពន្ធទី២ មានកូនចំនួន១នាក់ទៀត ហើយគាត់ប្រកបមុខរបរជាអ្នកលក់ដូរនៅក្នុងផ្សារៗ រហូតមកដល់ពេលបច្ចុប្បន្ននេះ កូនទាំង៦នាក់របស់ខ្ញុំ បានរៀបការនិងកសាងក្រុមគ្រួសារដោយខ្លួនឯងរួចអស់ហើយ ចំណែកខ្ញុំ រស់នៅជាមួយប្រពន្ធទី២តែពីរនាក់ប៉ុណ្ណោះៗ

**ផាត ចាន់សុនិត**


ចំការស្វាយរបស់អ្នកភូមិ ស្ថិតនៅឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ (រូបថតៈបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការងាររបស់ស្ត្រីនៅក្នុងរបបខ្មែរក្រហម

ស្ត្រី បានរួមចំណែកយ៉ាងច្រើនក្នុងការជួយអភិវឌ្ឍន៍គ្រួសារ និងសង្គមជាតិឲ្យកាន់តែរីកចម្រើនៗ ស្ត្រី គឺជាធនធានមនុស្ស និងជាកម្លាំងចលករដែលមិនអាចខ្វះបានៗ ដូច្នេះក្នុងការកសាងប្រទេសមួយឲ្យមានការអភិវឌ្ឍ ឬរីកចម្រើនជឿនលឿន និងប្រកបដោយភាពយូរអង្វែងទៅបានគឺមិនអាចខ្វះស្ត្រីបានទេៗ សូម្បីតែរបបខ្មែរក្រហមដែលត្រូវបានប្រជាជនខ្មែរគ្រប់គ្នាស្អប់ខ្ពើម និងចាត់ទុកថាជារបបដ៏សាហាវឃោរឃៅ ក៏យើងសង្កេតឃើញថា របបនេះក៏បានផ្តល់តួនាទីដល់ស្ត្រីដែរ ដូចជាគណៈភូមិ គណៈឃុំ និងគណៈស្រុកៗ ស្ត្រីក៏ត្រូវបានខ្មែរក្រហមជ្រើសរើសឲ្យចូលធ្វើពេទ្យ យោធា និងកងឈ្លបដើម្បីធ្វើការតាមដានខ្មាំងដែរៗ ទោះបីយ៉ាងណា ស្ត្រីមួយចំនួនត្រូវបានខ្មែរក្រហមតម្រូវឲ្យធ្វើការដល់ហួសកម្លាំង និងបាត់បង់អាយុជីវិតៗ ក្រោយរបបខ្មែរក្រហមបានដួលរលំស្ត្រីមានតួនាទីដ៏សំខាន់ និងបានចូលរួមស្តារប្រទេសឡើងវិញៗ

ទូច ភាន ភេទស្រី កើតឆ្នាំ១៩៤៧ ស្ថិតនៅក្នុងភូមិប៉ោយសំរោង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យៗ ទូច ភាន បានរៀបរាប់ថា ខ្ញុំមានបងប្អូនស្រី៨នាក់ ហើយខ្ញុំគឺជាកូនទី១ៗ ឪពុកម្តាយរបស់ខ្ញុំបានស្លាប់អស់ហើយៗ សព្វថ្ងៃខ្ញុំរស់នៅជាមួយប្អូនស្រីរបស់ខ្ញុំម្នាក់ឈ្មោះ


ទូច ភាន (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទូច រើន។ កាលពីក្មេងខ្ញុំមិនបានរៀនសូត្រទេព្រោះឪពុកម្តាយខ្ញុំក្រ ហើយខ្ញុំត្រូវនៅជួយមើលថែប្អូនៗ ខ្ញុំបានរៀបការនៅអាយុ១៩ឆ្នាំ គឺមុនពេលដែល លន់ នល់ ធ្វើរដ្ឋប្រហារ។ នៅពេលរៀបការរួច ខ្ញុំបានបែកផ្ទះទៅរស់នៅជាមួយប្តី និងបានប្រកបរបបរធ្វើស្រែ ដាំត្រសក់ ដាំឪឡឹក និងដាំសណ្តែកដាដើម។

លុះដល់ឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមចូលមកដល់ប្តីរបស់ខ្ញុំ និងខ្ញុំបានធ្វើការផ្សេងគ្នា។ យើងបានចេញទៅធ្វើការនៅតាមកងចល័ត តាមគោលដៅឆ្ងាយៗមិនដែលបានមកជួបគ្នានោះទេ។ ខ្មែរក្រហមបានជ្រើស និងចាត់តាំងខ្ញុំឲ្យទៅកាប់ព្រៃ ដកស្ទូង និងជម្រះមន។ មួយថ្ងៃខ្ញុំទទួលបានអាហារពីរពេល គឺពេលថ្ងៃត្រង់ និងពេលល្ងាច ប៉ុន្តែមិនមានបាយហូបទេ គឺមានតែបបរមួយកូនចានតូចប៉ុណ្ណោះ។ រយៈពេល១ឆ្នាំក្រោយមក ខ្ញុំក៏ត្រូវបានខ្មែរក្រហមបញ្ជូនទៅធ្វើការនៅស្ពានស្រែង។ ខ្ញុំមានតួនាទីជាប្រធានគ្រប់គ្រងសមាជិក១០នាក់។ ខ្ញុំទទួលបញ្ជាពីថ្នាក់លើឲ្យដឹកនាំសមាជិកក្រុមលើកទំនប់ប្រឡាយតូចៗដើម្បីតភ្ជាប់គ្នា ដោយក្នុងម្នាក់ជីកឲ្យបាន១ម៉ែត្រគីប។ នៅទីនោះ ខ្ញុំហូបមិនឆ្អែតឡើយ។ ពេលថ្នាក់លើសួរថាយើងហូបឆ្អែតទេ ខ្ញុំឆ្លើយថាឆ្អែតទាំងអស់គ្នា ព្រោះឆ្លើយថាមិនឆ្អែត ខ្លាចអង្គការយកទៅកសាង។ មួយរយៈក្រោយមក ខ្ញុំបានផ្លាស់ទៅនៅក្នុងអង្គភាពពេទ្យត្រពាំងថ្ម ដែលមានសមាជិកប្រមាណ១០នាក់។ ខ្ញុំមានភារកិច្ចដាំបាយឲ្យអ្នកជំងឺ ឲ្យថ្នាំអ្នកជំងឺ ចាក់ថ្នាំឲ្យអ្នកជំងឺ និងមើលថែអ្នកជំងឺពេលយប់។ អ្នកជំងឺភាគច្រើន ឈឺរាករូស វិលមុខ និងហត់ហេវអស់កម្លាំង។ ខ្ញុំបានយកសឺរ៉ាំងបូមទឹកដូង ចាក់តាមសសៃរ ឬសាច់ដុំទៅអ្នកជំងឺ ហើយអ្នកជំងឺភាគច្រើនដែលមកព្យាបាលនៅអង្គភាពរបស់ខ្ញុំ បានធូរស្បើយ។ ខ្ញុំបានដាំបាយឲ្យអ្នកជំងឺ៣ខ្ទះធំៗ ហើយដួស១ឆ្នាំងធំទុកសម្រាប់ពេទ្យ។ ចំណែកសម្លយើងមិនមានហូបគ្រប់គ្រាន់ទេ។ យើងមានសម្លហូបច្រើននៅពេលណាដែលមានត្រី ហើយបន្លែយើងចូលទៅបេះស្លឹករស្មៀងនៅក្នុងព្រៃ។ ខ្ញុំបានធ្វើការនៅត្រពាំងថ្មបានរយៈពេលជាង១ឆ្នាំ កងទ័ពវៀតណាមបានវាយចូលមក។ ខ្ញុំនិងប្តីបានរត់ទៅតាមខ្មែរក្រហម និងរស់នៅភ្នំឆត្របានរយៈពេលបីខែ ក៏សម្រេចចិត្តមករស់នៅក្នុងស្រុកកំណើតវិញ។ ខ្ញុំបានគិតថា បើខ្ញុំចូលរួមជាមួយខ្មែរក្រហមតស៊ូទៀតក៏មិនបានអ្វីត្រលប់វិញដែរ ហើយកងទ័ពយួនវាយចូលមកកាន់តែខ្លាំងដែរ។ ក្រោយមកខ្ញុំនិងប្តីក៏បានលែងលះគ្នា ហើយប្តីខ្ញុំក៏ទៅយកប្រពន្ធថ្មីទៀត។ ខ្ញុំរស់នៅជាស្ត្រីមេម៉ាយ ហើយសព្វថ្ងៃខ្ញុំសុំកាន់សីលប្រាំបីនិងតែងតែទៅវត្តសូត្រព្រះធម៌ដើម្បីឲ្យចិត្តជ្រះស្រឡះ និងរួចផុតពីទុក្ខសោកទាំងឡាយ។

ព្រំ គិតម៉ាន់


ទេសភាពវាលស្រែ ស្ថិតនៅក្នុងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ (រូបថត៖បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# «ឆ្នាំព្រៃ» នឹងជួយឲ្យមានការយល់ដឹងពីប្រវត្តិសាស្ត្រ និងសារសំខាន់នៃព្រៃឈើ

ឆ្នាំព្រៃនឹងលើកទឹកចិត្តឲ្យមនុស្សគ្រប់គ្នាឲ្យស្វែងយល់ពីប្រវត្តិសាស្ត្រនិងតម្លៃនៃការថែរក្សាព្រៃឈើ។ ខ្សែភាពយន្តឯកសារនេះ នឹងបង្ហាញពីជីវិតសត្វព្រៃ ធនធានធម្មជាតិ និងព្រៃឈើនៅក្នុងស្រុកអន្លង់វែង ដែលជាតំបន់កាន់កាប់ចុងក្រោយរបស់ខ្មែរក្រហម ស្ថិតនៅភាគជើងនៃប្រទេសកម្ពុជា។ តំបន់អន្លង់វែងនេះ គឺជាតំបន់ដែលធ្លាប់កើតមានអំពើឃោរឃៅ ការកាប់សម្លាប់របស់ក្រុមខ្មែរក្រហម និងតំបន់ដែលទទួលបានសន្តិភាពនៅក្នុងប្រទេសកម្ពុជាដែរ។

ខ្សែភាពយន្ត ឆ្នាំព្រៃ បានលើកឡើងពីគំនិតផ្តួចផ្តើម និងការខិតខំប្រឹងប្រែងរបស់ព្រះសង្ឃមួយអង្គព្រះនាម ប៊ុន សាលួត ក្នុងការដឹកនាំការងារអភិរក្សព្រៃឈើដែលនៅសេសសល់នៅក្នុងទឹកដីស្រុកអន្លង់វែង ដែលបានដឹកនាំថតដោយ អ៊ូច មករា ប្រធានផលិតកម្ម Sleuk Rith Motion Picture នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ ការបង្ហាញអំពីតំបន់អន្លង់វែង មិនត្រឹមតែជាគោលបំណងមួយរបស់ភាពយន្តឯកសារនេះតែប៉ុណ្ណោះទេ ក៏ប៉ុន្តែដើម្បីលុបបំបាត់ និងកែច្នៃភាពសាហាវឃោរឃៅរបស់របបខ្មែរក្រហមឲ្យទៅជាស្មារតីជាតិរួមគ្នាថ្មីមួយ ដែលមានយូរលង់ដំណាលគ្នាទៅនឹងការកកើតព្រៃឈើនៅតំបន់នេះដែរ។ ឆ្នាំព្រៃ គឺជាខ្សែភាពដែលមានសុទិដ្ឋិនិយម ហើយនឹងការជឿជាក់លើយុវវ័យ




សិស្សានុសិស្សនិងគ្រូមកចូលរួមទស្សនាការបញ្ចាំងកុនឯកសារឆ្នាំព្រៃ នៅវត្តលង្កា ក្រុងភ្នំពេញ
(រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជំនាន់ក្រោយដែលនឹងយកគំរូតាមព្រះតេជគុណ ប៊ុន សាលួត ដែលជាការប្តេជ្ញា និងមានស្មារតីជាតិក្នុងការអភិរក្សវប្បធម៌ និងធនធានធម្មជាតិរបស់កម្ពុជា។ ឆ្នាំព្រៃ នឹងនាំអ្នកទស្សនាផ្សារភ្ជាប់ខ្លួនទៅនឹងជីវចម្រុះនៃព្រៃឈើ។ ព្រៃឈើដែលងាយរងគ្រោះនេះត្រូវបានអនុញ្ញាតិជាផ្លូវការពីរាជរដ្ឋាភិបាលកម្ពុជា ឲ្យរក្សាទៅជាព្រៃអភិរក្ស ដែលត្រូវបានដាក់ឈ្មោះជាផ្លូវការថា «ព្រៃសហគមន៍សង្ឃរុក្ខវ័ន្ត»។

ព្រះតេជគុណ ប៊ុន សាលួត គឺជាប្រធានសហគមន៍បានមានសង្ឃដីកាថា ព្រៃសហគមន៍សង្ឃរុក្ខវ័ន្តមានទំហំសរុប ៣០,២៥៦ ហិចតា លាតសន្ធឹងក្នុងស្រុកចំនួនបី រួមមាន ស្រុកសំរោង ស្រុកចុងកាល់ និងស្រុកអន្លង់វែង។ ព្រៃនេះត្រូវបានចាត់ចូលជាព្រៃដែលទទួលបានការពារតាមរយៈអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា។

ព្រះតេជគុណ ប៊ុន សាលួត ដែលជាមេគុណខេត្តឧត្តរមានជ័យដែរនោះ មានសង្ឃដីកាបន្ថែមទៀតថា តំបន់ព្រៃសហគមន៍សង្ឃរុក្ខវ័ន្ត គឺជាព្រៃសេសសល់ចុងក្រោយនៃខេត្តឧត្តរមានជ័យ។ កាលពីមុនតំបន់ព្រៃសង្ឃរុក្ខវ័ន្ត ត្រូវបានទន្ទ្រាន និងកាប់ឈើលក់ទៅឲ្យឈ្មួញ ធ្វើឲ្យព្រៃឈើនៅតំបន់នេះចាប់ផ្តើមរេចរឹលបន្តិចម្តងៗ ហើយជម្រកសត្វព្រៃក៏បានបាត់បង់ជាបណ្តើរៗដែរ។ ដូច្នេះព្រះអង្គក៏ស្ម័គ្រចិត្តចូលបម្រើការងារថែរក្សាព្រៃនេះ និងបានបំពេញឯកសារទៅស្ថាប័នពាក់ព័ន្ធ ក្រសួង និងរដ្ឋាភិបាល ដើម្បីសុំសិទ្ធិការពារថែរក្សា និងអភិរក្សតំបន់ព្រៃសហគមន៍នេះ ចាប់តាំងពីឆ្នាំ ២០០១មក។ ព្រះអង្គបង្កើតកម្មវិធីផ្សេងៗតាមបែបសាសនា រួមមាន ការរៀបចំពិធីបុណ្យទាន ការបំបួសដើមឈើដើម្បីអប់រំនិងណែនាំប្រជាជនក្នុងសហគមន៍អំពីសារសំខាន់នៃព្រៃឈើ។ សព្វថ្ងៃ ព្រះអង្គសង់ទីស្នាក់ការចំនួន៧កន្លែងសម្រាប់ឃ្លាំមើលព្រៃឈើ ដោយទីស្នាក់ការនីមួយៗមានកម្លាំងយាមល្បាតចំនួន៣-៤នាក់ រួមមាន ទាំងព្រះសង្ឃដែរ។

ទោះបីជាជួបបញ្ហាប្រឈមទាក់ទងនឹងការបំពេញការងារកន្លងមក ក៏ព្រះអង្គមិនដែលមានចិត្តរុញរា ឬចង់បញ្ឈប់សកម្មភាពរបស់ព្រះអង្គដែរ ព្រោះព្រះអង្គស្រឡាញ់ធម្មជាតិ និងចង់អភិរក្សតំបន់សហគមន៍ព្រៃសង្ឃរុក្ខវ័ន្តឲ្យក្លាយទៅជាតំបន់ទេសចរណ៍ចម្រុះដែលអាចទាក់ទាញភ្ញៀវទេសចរណ៍ មកពីគ្រប់ទីកន្លែងឲ្យចូលមកដើរកម្សាន្តនៅក្នុងព្រៃនេះ។ ជិត២០ឆ្នាំកន្លងមកនេះ ព្រះអង្គបានខិតខំអភិរក្សតំបន់សហគមន៍ព្រៃសង្ឃរុក្ខវ័ន្តនេះ ហើយជាលទ្ធផល សហគមន៍ព្រៃសង្ឃរុក្ខវ័ន្តក៏បានផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋដែលរស់នៅ និងអាស្រ័យផលពីអនុផលព្រៃឈើក្នុងតំបន់នេះចំនួន៩ភូមិ ស្មើនឹងជិតមួយរយគ្រួសារ។ ជាពិសេស តំបន់សហគមន៍ព្រៃសង្ឃរុក្ខវ័ន្តនេះ ក៏បានផ្តល់ជាទីជម្រកដល់សត្វព្រៃជាច្រើនសន្ធឹកសន្ធាប់ដែរ។ ព្រះអង្គសង្ឃឹមថា ប្រជាជនកម្ពុជានឹងមានការយល់ដឹងច្រើនអំពីសារសំខាន់នៃព្រៃឈើ ព្រោះព្រៃឈើនិងមនុស្សត្រូវតែមានទំនាក់ទំនងនិងអាស្រ័យផលគ្នាទៅវិញទៅមក។ ព្រៃសហគមន៍សង្ឃរុក្ខវ័ន្ត នឹងត្រូវបានការពារ និងថែរក្សាដោយយកចិត្តទុកដាក់ដើម្បីរក្សាទុកជាសម្បត្តិធម្មជាតិសម្រាប់កូនចៅជំនាន់ក្រោយ។

កាលពីមុន ព្រៃសហគមន៍សង្ឃរុក្ខវ័ន្ត ក៏ធ្លាប់ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមខ្មែរក្រហមដែរ។ យោធា កម្មាភិបាលខ្មែរក្រហម និងប្រជាជនដែលរត់គេចខ្លួនពីការវាយប្រហារពីសំណាក់កងទ័ពវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា នៅឆ្នាំ១៩៧៩ បានរត់មកប្រមូលផ្តុំគ្នានិងរស់នៅក្នុងព្រៃនេះ។ ខ្មែរក្រហមបានកេណ្ឌប្រជាជនរាប់ម៉ឺននាក់ចូលមករស់នៅក្នុងព្រៃនេះ និងនៅលើជួរភ្នំដងរែក (លាតសន្ធឹងពីខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ) ឲ្យចូលជាយោធាដើម្បីវាយប្រយុទ្ធតទល់នឹងរដ្ឋាភិបាល។ តំបន់នេះមានទីតាំងភូមិសាស្ត្រល្អសម្រាប់ក្រុមខ្មែរក្រហមលាក់ខ្លួន ព្រោះសម្បូរណ៍ទៅដោយព្រៃឈើក្រាស់ៗ និងជួរភ្នំវែងអន្លាយ។ នៅអំឡុងពេលនោះ ខ្មែរក្រហមក៏បានកាប់ឈើពីក្នុងព្រៃនេះដើម្បីយកមកសាងសង់ផ្ទះសម្រាប់យោធា សង់មូលដ្ឋានទ័ព ស្ពាន និងហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀត។ ក្រោយមក យោធាខ្មែរក្រហមបានចាប់ផ្តើមកាប់ព្រៃឈើ

កាន់តែច្រើនក្នុងគោលបំណងដោះដូរស្បៀងគ្រឿងឧបភោគ និងសម្ភារប្រើប្រាស់ ជាមួយឈ្មួញថៃ ដែលបណ្តាលឲ្យព្រៃឈើជាច្រើននៅតាមព្រំដែនកម្ពុជា-ថៃរួមមានស្រុកអន្លង់វែង ស្រុកសំរោង និងស្រុកចុងកាល់ បាត់បង់ជាបន្តបន្ទាប់។

ក្រោយមក ដោយសារតម្រូវការឈើ និងការជួញដូរឈើកាន់តែច្រើនឡើងធ្វើឲ្យព្រៃនៅក្នុងតំបន់ព្រៃសហគមន៍នេះទទួលរងគ្រោះកាន់តែខ្លាំង តាមរយៈការកាប់រំលំ ទោះបីមានវិធានការការពារជាបន្តបន្ទាប់ពីអាជ្ញាធរ និងរដ្ឋាភិបាលក៏ដោយ។ ទោះបីរបបខ្មែរក្រហមបានដួលរលំអស់រយៈកាល ៤០ឆ្នាំហើយក្តី ក៏ប៉ុន្តែការកាប់ទន្ទ្រានព្រៃឈើនៅតែបន្តកើតមាននៅក្នុងប្រទេសកម្ពុជាយើងរហូតមកដល់សព្វថ្ងៃនេះ។ ព្រៃឈើនៅតាមតំបន់ផ្សេងៗនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកាប់រំលំពីសំណាក់អ្នកមានអំណាចមួយចំនួន ឈ្មួញអ្នកមានលុយ និងតាមរយៈការលួចកាប់បំផ្លាញរបស់ប្រជាជនមូលដ្ឋានផ្ទាល់។ ទោះបីជារាជរដ្ឋាភិបាលកម្ពុជាបានចេញសារាចរណែនាំទៅដល់អភិបាលរាជធានីខេត្តក្រុងស្រុកខណ្ឌឲ្យអនុវត្តឲ្យបានត្រឹមត្រូវនូវតួនាទីភារកិច្ចរបស់ខ្លួន និងចាត់វិធានការឲ្យបានម៉ឺងម៉ាត់ និងម៉ត់ចត់ចំពោះបទល្មើសធនធានធម្មជាតិគ្រប់ប្រភេទ ជាពិសេសទៅលើវិស័យព្រៃឈើ និងជលផលដោយចាត់វិធានការតាមផ្លូវច្បាប់។

ព្រៃឈើ បានផ្តល់ផលប្រយោជន៍ជាច្រើនដល់មនុស្ស និងជម្រកសត្វព្រៃ។ ព្រៃឈើមានតួនាទីយ៉ាងសំខាន់ក្នុងការជួយថែរក្សាដំណើរការប្រព័ន្ធអេកូឡូស៊ី និងជួយកាត់បន្ថយឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ដូចជា ទឹកជំនន់ ខ្យល់ព្យុះ និងស្រូបយកឧស្ម័នកាបូនិចពីបរិយាកាស។ ព្រៃឈើ គឺជាសម្បត្តិធម្មជាតិដ៏មានតម្លៃ ដែលទំនាក់ទំនង



អង្គទូត ពុទ្ធបរិស័ទ និងភ្ញៀវទស្សនាការបញ្ចាំងកុនឯកសារឆ្នាំព្រៃ នៅវត្តលង្កា ក្រុងភ្នំពេញ
(រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាមួយនឹងការរស់នៅប្រចាំថ្ងៃរបស់មនុស្ស និងសត្វ ដូច្នេះ ទាមទារឲ្យមានការចូលរួម ការគ្រប់គ្រង និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយវិចារណញ្ញាណ ដើម្បីធានានូវតុល្យភាពបរិស្ថាន ព្រមទាំងផ្តល់ឱកាសដល់កូនចៅជំនាន់ក្រោយទទួលបានផលប្រយោជន៍ពីធនធានទាំងអស់នេះ។

ព្រៃសហគមន៍សង្ឃរុក្ខវ័ន្ត មិនត្រឹមតែរក្សាលំនឹងបរិស្ថានធម្មជាតិដែលមានសម្រស់ស្រស់បំព្រងពណ៌បៃតង និងរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រកបដោយចីរភាព ព្រមទាំងបម្រើដល់វិស័យទេសចរណ៍ប៉ុណ្ណោះទេ ប៉ុន្តែបានផ្សារភ្ជាប់ទៅនឹងអំពើហិង្សា និងប្រវត្តិនៃការកាប់សម្លាប់ដ៏ឃោរឃៅរបស់ក្រុមខ្មែរក្រហម។ របបខ្មែរក្រហមមិនត្រឹមធ្វើឲ្យប៉ះពាល់ទៅដល់មនុស្ស ធម្មជាតិ និង សង្គមប៉ុណ្ណោះទេ ប៉ុន្តែបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរទៅដល់វប្បធម៌ និងសាសនាផងដែរ ហើយដែលបន្តរហូតមកដល់សព្វថ្ងៃ។ ដូចគ្នានឹងយន្តការនៃការការពារ ការអភិរក្សព្រៃឈើ និងការបង្ហាញពីសារសំខាន់នៃព្រៃសហគមន៍សង្ឃរុក្ខវ័ន្ត ប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមក៏យើងគួរត្រូវលើកយកពិភាក្សា និងរៀនសូត្រដែរ។

**ហូ ចុនា**



ព្រះសង្ឃ ពុទ្ធបរិស័ទ និងភ្ញៀវទស្សនាការបញ្ចាំងកុនឯកសារឆ្នាំព្រៃ នៅវត្តលង្កា ក្រុងភ្នំពេញ
(រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍វិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្ដីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្ដុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរគឺ ជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្ដៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្ដៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ ដល់ម៉ោង៥។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង សុង ថាណៃ តាមរយៈទូរសព្ទលេខ៖ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល៖ truththanay.s@dccam.org។



























# អង្គជំនុំជម្រះសាលាដំបូង
# សេចក្តីសង្ខេបសាលក្រមសំណុំរឿង០០២/០២
## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

(តពីលេខមុន)

២៤. មន្ទីរសន្តិសុខភ្នំក្រោលស្ថិតនៅតំបន់ ១០៥ (បច្ចុប្បន្នខេត្តមណ្ឌលគិរី) មានមន្ទីរ ក-១៧ និង ក-១១ គុកភ្នំក្រោល និងកន្លែងកប់សាកសពត្រពាំងព្រីងៗ អង្គជំនុំជម្រះយល់ឃើញថាពុំមានការការពារតាមប្រព័ន្ធតុលាការ ឬតាមនិតិវិធីច្បាប់ទេ នៅពេលចាប់ខ្លួនអ្នកដែលត្រូវបានគេសន្មតថាជាអ្នកទោស និងពេលឃុំខ្លួនពួកគេនាពេលក្រោយមក នៅមន្ទីរសន្តិសុខភ្នំក្រោល ហើយនៅក្នុងអំឡុងពេលនោះ ពួកគេត្រូវបានបង្ខំឲ្យធ្វើការៗ អង្គជំនុំជម្រះយល់ឃើញទៀតថាអ្នកជាប់ឃុំម្នាក់បានស្លាប់ដោយសារតែលក្ខខណ្ឌនៃការឃុំខ្លួន ហើយអ្នកជាប់ឃុំម្នាក់ត្រូវគេសម្លាប់ដោយចេតនាៗ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះមិនអាចរកភ័ស្តុតាងបង្ហាញឲ្យឃើញថា តើកន្លែងកប់សាកសពត្រពាំងព្រីងត្រូវបានគេប្រើសម្រាប់កប់សាកសពអ្នកជាប់ឃុំទាំងនោះ ឬយ៉ាងណានោះទេៗ លើសពីនេះទៀត ទោះបីជាអង្គជំនុំជម្រះជឿថា ត្រពាំងព្រីងពិតជាកន្លែងកប់សាកសពនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថាត្រពាំងព្រីងត្រូវគេប្រើជាទីតាំងសម្លាប់មនុស្សបានឡើយៗ

២៥. អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចតទៅនេះត្រូវបានប្រព្រឹត្តពាក់ព័ន្ធនឹងការ



សាធារណៈជន តម្រង់ជួរចូលស្តាប់សវនាការ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ (រូបថត៖បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បង្កើត និងដំណើរការរបស់មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស។ ឧក្រិដ្ឋកម្មទាំងនោះរួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ។ អង្គជំនុំជម្រះនឹងលើកឡើងអំពីការសន្និដ្ឋានរបស់ខ្លួនទាក់ទងនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខ ស-២១ ដោយបង្ហាញអំពីការប្រព្រឹត្តលើជនជាតិវៀតណាម។

## ១.៣.៤.ការកំណត់គោលដៅលើក្រុមមនុស្សជាក់លាក់

២៦. អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានគោលនយោបាយកំណត់គោលដៅលើក្រុមមនុស្សដូចតទៅនេះ ដើម្បីបង្កើតសង្គមមួយដែលមិនជឿលើសាសនា និងមានលក្ខណៈតែមួយដោយគ្មានការបែងចែកវណ្ណៈ តាមរយៈការលុបបំបាត់នូវភាពខុសគ្នាខាងជាតិពន្ធុ ជាតិ សាសនា ពូជសាសន៍ វណ្ណៈ និងវប្បធម៌។ ក្រុមទាំងនោះរួមមានជនជាតិចាមជនជាតិវៀតណាមពុទ្ធសាសនិក ព្រមទាំងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (រួមទាំងអ្នករដ្ឋការស៊ីវិល និងទាហាន) និងក្រុមគ្រួសាររបស់ពួកគេ។

### ១.៣.៤.១. ជនជាតិចាម

២៧. ទាក់ទងនឹងជនជាតិចាម អង្គជំនុំជម្រះយល់ឃើញថា ក្រោយការបះបោរនៅកោះផល ក្នុងខែកញ្ញា ឆ្នាំ១៩៧៥ និងនៅស្វាយឃ្លាំង ក្នុងខែតុលា ឆ្នាំ១៩៧៥ ប្រជាជនចាមនៅភូមិភាគបូព៌ាភាគច្រើនជាអ្នករស់នៅតាមដងទន្លេមេគង្គត្រូវបានគេបញ្ជូនឲ្យទៅរស់នៅបែកខ្ញែកគ្នា នៅភូមិភាគកណ្តាល (ឧត្តរចាស់)។ ជនជាតិចាម ត្រូវបានកងទ័ពបក្សកុម្មុយនីស្តកម្ពុជាបញ្ជូនចេញ ដោយគ្មានការយល់ព្រម និងក្រោមការគំរាមកំហែងថានឹងចាត់ទុកជាខ្មាំង បើពួកគមិនស្តាប់បញ្ជា។ ទោះបីជាការបំបែកនេះ គឺជាផ្នែកមួយនៃការជម្លៀសប្រជាជនក្នុងទ្រង់ទ្រាយធំពីភូមិភាគបូព៌ាទៅភូមិភាគកណ្តាល (ឧត្តរចាស់) ក្នុងគោលដៅដាក់ពង្រាយប្រជាជននៅទូទាំងប្រទេសកម្ពុជាក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា ជនជាតិចាមនៅភូមិភាគបូព៌ាត្រូវបានកំណត់ជាគោលដៅជាក់លាក់ដោយសារតែការបះបោរប្រឆាំងនឹងការរឹតត្បិតពីមុនលើ សាសនា ប្រពៃណី និងវប្បធម៌ចាម។ អង្គជំនុំជម្រះយល់ឃើញទៀតថា គេមិនត្រឹមតែជម្លៀសជនជាតិចាមពីកន្លែងដើមទៅកន្លែងថ្មី ដើម្បីបំពេញសេចក្តីត្រូវការខាងកម្លាំងពលកម្មក្នុងស្រុកប៉ុណ្ណោះទេ គឺថែមទាំង បំបែកជនជាតិចាមឲ្យរស់នៅរាយប៉ាយនៅតាមភូមិខ្មែរ ដើម្បី


សាលាក្តីខ្មែរក្រហម ថ្ងៃទី១៦ ខែវិច្ឆិកាឆ្នាំ២០១៨ (រូបថតៈបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រំលាយសហគមន៍ជនជាតិចាម និងច្របាច់បញ្ចូលពួកគេជាមួយប្រជាជនកម្ពុជា។ ហេតុដូច្នេះ ជនជាតិចាមត្រូវបានកំណត់ជាគោលដៅ មិនមែនជាបុគ្គលទេ ប៉ុន្តែផ្អែកលើសមាជិកក្រុមរបស់ពួកគេ។

២៨. លើសពីនេះទៅទៀត អង្គជំនុំជម្រះយល់ឃើញថា ប្រជាជនចាមបានទទួលរងការរើសអើងខុសច្បាប់ទាហរណ៍ នៅការដ្ឋានការផ្សារទំនប់ ១ មករា ពួកគេត្រូវបានបង្ខំឲ្យហូបសាច់ជ្រូក ហើយត្រូវបានរារាំងមិនឲ្យគោរពបូជាសាសនា និងនិយាយភាសាចាមឡើយ។ អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា បក្សកុម្មុយនីស្តកម្ពុជាបានដាក់កំហិតលើការប្រណិប័តន៍សាសនា និងវប្បធម៌ចាម នៅស្រុកក្រូចឆ្មារ តាមទីតាំងជាច្រើនក្នុងភូមិភាគកណ្តាល (ខេត្តរចាស់) និងតាមទីតាំងនានាផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។ ការដាក់កំហិតបែបនេះរួមមានការហាមសំយ៉ាំងជារៀងរាល់ថ្ងៃ ការបង្ខំជនជាតិចាមឲ្យហូបសាច់ជ្រូក ព្រមទាំងស្លៀកសម្លៀកបំពាក់ និងកាត់សក់ដូចប្រជាជនខ្មែរ ការបង្ខំឲ្យនិយាយតែភាសាខ្មែរ ក៏ដូចជា ការដុតគម្ពីរអាល់គូរ៉ាន និងការរុះរើព្រះវិហារ ឬការប្រើប្រាស់ព្រះវិហារសម្រាប់គោលបំណងខុសពីការបួងសួង។ អ្នករឹងទទឹងត្រូវគេចាប់ខ្លួន និង/ឬសម្លាប់ចោល។

២៩. លើសពីនេះទៅទៀត អង្គជំនុំជម្រះយល់ឃើញថា មនុស្សជាច្រើន រួមទាំងជនជាតិចាមភាគច្រើនមកពីស្រុកកងមាស (បច្ចុប្បន្នខេត្តកំពង់ចាម) តំបន់ ៤១ ភូមិភាគកណ្តាល (ខេត្តរចាស់) ត្រូវគេចាប់យកទៅសម្លាប់នៅវត្តអូរត្រកួន ក្នុងឆ្នាំ១៩៧៧។ អង្គជំនុំជម្រះយល់ឃើញទៀតថា នៅឆ្នាំ១៩៧៨ ប្រជាជនចាមជាច្រើនមកពីស្រុកក្រូចឆ្មារ (បច្ចុប្បន្នខេត្តត្បូងឃ្មុំ) ត្រូវគេចាប់យកទៅមន្ទីរសន្តិសុខភូមិទ្រា ក្នុងស្រុកក្រូចឆ្មារដដែល ហើយនៅទីនោះ សមាជិកក្រុមចាមត្រូវបានគេពិនិត្យផ្ទៀងផ្ទាត់។ អ្នកដែលត្រូវបានគេចាត់ទុកថាជាចាម ត្រូវគេសម្លាប់ ចំណែកឯអ្នកដែលមិនមែនជាចាម ត្រូវគេទុកឲ្យរួចជីវិត។ អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា បញ្ជាឲ្យកំណត់គោលដៅលើជនជាតិចាមនៅភូមិភាគកណ្តាល (ខេត្តរចាស់) និងជាពិសេស នៅតំបន់៤១ចេញមកពីថ្នាក់លើ។ អង្គជំនុំជម្រះក៏យល់ឃើញដែរថា បញ្ជាឲ្យកំណត់គោលដៅលើជនជាតិចាមនៅភូមិភាគបូព៌ា និងជាពិសេសនៅស្រុកក្រូចឆ្មារ ចេញមកពីថ្នាក់លើ។ ថ្វីត្បិតតែអង្គជំនុំជម្រះមិនអាចកំណត់ចំនួនជនរងគ្រោះបានជាក់លាក់ក៏ដោយ ក៏អង្គជំនុំជម្រះជឿជាក់ថា ជនស៊ីវិលចាមជាច្រើន ត្រូវគេនាំយកទៅមន្ទីរសន្តិសុខវត្តអូរត្រកួន និងមន្ទីរសន្តិសុខភូមិទ្រារួចត្រូវបានគេសម្លាប់ចោលក្នុងទ្រង់ទ្រាយធំ។ អង្គជំនុំជម្រះជឿជាក់ថា ចារីនៅមន្ទីរសន្តិសុខវត្តអូរត្រកួននិងមន្ទីរសន្តិសុខភូមិទ្រា បានបង្ហាញអំពីស្ថានភាពផ្លូវចិត្តក្នុងការប្រល័យពូជសាសន៍ជនជាតិចាម ដែលត្រូវបានរកឃើញថា ត្រូវបានគេសម្លាប់នៅទីតាំងទាំងនោះ។ អង្គជំនុំជម្រះយល់ឃើញទៀតថា នៅឆ្នាំ១៩៧៨ ជនជាតិចាមមកពីស្រុកក្រូចឆ្មារត្រូវគេចាប់យកទៅមន្ទីរសន្តិសុខភូមិទ្រា ឃុំខ្លួនតាមទំនើងចិត្ត និងដកហូតសិទ្ធិទទួលបានដំណើរការក្តីតាមផ្លូវច្បាប់ ហើយនៅទីនោះ អ្នកខ្លះត្រូវបានគេសួរចម្លើយ និងវាយដំ។

៣០. ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានប្រព្រឹត្តលើជនជាតិចាម ក្រោមទម្រង់ជាការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការជម្លៀសដោយបង្ខំ។

### ១.៣.៤.២. ជនជាតិវៀតណាម

៣១. ចំពោះជនជាតិវៀតណាម អង្គជំនុំជម្រះយល់ឃើញថា ចាប់ពីឆ្នាំ១៩៧៥ ដល់ចុងឆ្នាំ១៩៧៦ មានគោលនយោបាយថ្នាក់ជាតិសំដៅបណ្តេញជនជាតិវៀតណាមដែលរស់នៅប្រទេសកម្ពុជា។ គោលនយោបាយនេះត្រូវបានអនុវត្តក្រោយពីមានការព្រមព្រៀងគ្នាជាមួយអាជ្ញាធរវៀតណាម។

កម្មាភិបាលខ្មែរក្រហមបានរៀបចំនិងឃ្លាំមើលការដឹកជញ្ជូនប្រជាជនវៀតណាមទៅព្រំដែនវៀតណាម តាមកាណូត និងរថយន្តៗ ប្តីឬប្រពន្ធជាជនជាតិខ្មែរដែលមានគ្រួសារចម្រុះជាតិសាសន៍ត្រូវនៅកម្ពុជាៗ អង្គជំនុំជម្រះក៏យល់ឃើញដែរថា ថ្នាក់លើរបស់បក្សកុម្មុយនីស្តកម្ពុជាបានបញ្ជាឲ្យកំណត់អត្តសញ្ញាណជនជាតិវៀតណាម ហើយក្រោយមក ចាប់ពីខែមេសា ឆ្នាំ១៩៧៥ថ្នាក់ក្រោមបានរៀបចំបញ្ជីឈ្មោះ និងប្រវត្តិរូបរួចបញ្ជូនទៅថ្នាក់លើ ដើម្បីចាត់វិធានការបន្តទៀតៗ ចាប់ពីឆ្នាំ១៩៧៥ មកបក្សកុម្មុយនីស្តកម្ពុជាបានចាត់ទុកថាប្រសិនបើគ្រួសារណាមានម្តាយជាជនជាតិវៀតណាម ហើយឪពុកជាខ្មែរនោះ ត្រូវបញ្ជូនម្តាយនិងកូនៗទៅប្រទេសវៀតណាម ដោយទុកឪពុកៗស្រដៀងគ្នានេះដែរប្រសិនបើគ្រួសារណាមានឪពុកជាជនជាតិវៀតណាម ហើយម្តាយជាខ្មែរ ត្រូវបញ្ជូនឪពុកទៅប្រទេសវៀតណាមវិញ ដោយទុកម្តាយនិងកូនៗនៅប្រទេសកម្ពុជាៗ អង្គជំនុំជម្រះយល់ឃើញថា ជនជាតិវៀតណាមដែលចេញពីខេត្តព្រៃវែង ខេត្តស្វាយរៀង និងស្រុកត្រាំកក់ ក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ ត្រូវគេបង្ខំឲ្យធ្វើបែបនេះក្នុងបរិយាកាសបង្ខិតបង្ខំៗ

៣២. អង្គជំនុំជម្រះក៏យល់ឃើញដែរថា មានភ័ស្តុតាងបង្ហាញពីករណីជាក់លាក់មួយចំនួននៃការសម្លាប់ជនស៊ីវិលវៀតណាម ឧទាហរណ៍ នៅខេត្តស្វាយរៀង ក្នុងឆ្នាំ១៩៧៨ ក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ ក្រោយខែមេសា ឬខែឧសភា ឆ្នាំ១៩៧៧ និងនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨, នៅខេត្តកំពង់ឆ្នាំង ក្នុងឆ្នាំ១៩៧៧, នៅវត្តខ្សាច់ (ខេត្តសៀមរាប) នៅចុងឆ្នាំ១៩៧៨ និងនៅក្រចេះ ក្នុងខែកញ្ញា ឆ្នាំ១៩៧៨ៗ ការសម្លាប់ដោយចេតនាទ្រង់ទ្រាយធំទាំងនេះ ត្រូវបានរៀបចំឡើងជាប្រព័ន្ធនិងកំណត់គោលដៅទៅលើជនជាតិវៀតណាមៗ ក្នុងករណីនីមួយៗ ជនជាតិវៀតណាមត្រូវបានគេកំណត់គោលដៅមិនមែនជាបុគ្គលទេ គឺដោយសារតែសមាជិកក្រុមរបស់ពួកគេ និងដោយសារតែពួកគេត្រូវបានសន្មតថា ជាជនជាតិវៀតណាមៗ ករណីទាំងនេះបានកើតឡើងក្រោមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការកំណត់គោលដៅជាក់លាក់ទៅលើក្រុមជនជាតិវៀតណាម រួមទាំងជនស៊ីវិលផងៗ រហូតដល់ចុងឆ្នាំ១៩៧៦ ជនជាតិវៀតណាមត្រូវគេកំណត់គោលដៅ ដើម្បីបណ្តេញចេញ និងដើម្បីកម្ទេច ចាប់ពីខែមេសា ឆ្នាំ១៩៧៧ មកៗ

៣៣. ទាក់ទងនឹងការប្រព្រឹត្តលើជនជាតិវៀតណាមដែលត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខ ស-២១ អង្គជំនុំជម្រះយល់ឃើញថា ជនស៊ីវិល និងទាហានវៀតណាមរាប់រយនាក់ត្រូវបានគេសម្លាប់ក្រោយពីសួរចម្លើយ ដោយប្រើវិធីបង្ខិតបង្ខំ និងទទួលរងនូវលក្ខខណ្ឌលំបាកវេទនា នៅមន្ទីរសន្តិសុខ ស-២១ៗ អ្នកដែលត្រូវបានគេសម្លាប់ជាជនស៊ីវិល ឬឈ្លើយសឹកវៀតណាម ដែលជាជនត្រូវទទួលបានការការពារតាមអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ៗ ចម្លើយសារភាពដែលយកពីអ្នកជាប់ឃុំជាជនជាតិវៀតណាម ត្រូវគេចុះផ្សាយក្នុងឯកសារនានារបស់កម្ពុជាប្រជាធិបតេយ្យ ក្នុងគោលដៅបង្ហាញអំពី «ការឈ្លានពាន» របស់វៀតណាមមកលើកម្ពុជាប្រជាធិបតេយ្យៗ អង្គជំនុំជម្រះយល់ឃើញទៀតថា អ្នកជាប់ឃុំជាជនជាតិវៀតណាមដែលចូលមកមន្ទីរសន្តិសុខ ស-២១ មិនទទួលបានការការពារតាមនិតិវិធី ឬសិទ្ធិដែលអាចឲ្យពួកគេការពារខ្លួនបាននៅក្រោយពេលចាប់ខ្លួនត្រូវបានគេដកហូតដំណើរការមួយដែលស្រដៀងនឹងការកាត់ក្តីដោយយុត្តិធម៌ ហើយត្រូវគេបង្ខំឲ្យឆ្លើយសារភាពថាជាគិញ មុនពេលត្រូវបានគេសម្លាប់ៗ ទាហាន និងជនស៊ីវិលវៀតណាមទាំងអស់ ដែលចូលមកមន្ទីរសន្តិសុខ ស-២១ ត្រូវគេចោទថាជាគិញ និងចាត់ទុកថាជាខ្មាំងៗ ជោគវាសនារបស់អ្នកជាប់ឃុំទាំងនេះត្រូវបានសន្និដ្ឋានទុកជាមុន ដោយសារជាចុងក្រោយ ពួកគេទាំងអស់ត្រូវបានសម្លាប់ចោលៗ

(នៅមានត)

***អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា***

# ការយល់ឃើញរបស់អ្នកទស្សនាទៅលើគ្រូពេទ្យនៅក្នុងរបបខ្មែរក្រហម ក្នុងឈុតល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់»

ក្រោយរបបខ្មែរក្រហមដួលរលំ ប្រជាជនកម្ពុជានៅរស់រានមានជីវិតប្រមាណជា៥លាននាក់ប៉ុណ្ណោះ។ មានរឿងរ៉ាវជាច្រើនបានដក់ជាប់នៅក្នុងចិត្តរបស់ប្រជាជនកម្ពុជាដែលបានឆ្លងកាត់របបខ្មែរក្រហម ហើយរឿងរ៉ាវទាំងនេះត្រូវបានចងចាំរហូតមកដល់សព្វៗ ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» គឺជាការសម្តែង ដែលបានដកស្រង់ចេញពីសាច់រឿងពិតរបស់ប្រជាជនកម្ពុជាដែលបានឆ្លងកាត់ភាពសោកស្រេងពីអតីតកាល។

ខាងក្រោមនេះ គឺជាខ្លឹមសាររឿងនៅក្នុងឈុតមួយនៃល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ៖

«ខ្ញុំឈ្មោះ ស៊ីណា នៅក្នុងឆ្នាំ១៩៧៦ មានអាយុ១០ឆ្នាំ គេយកឪពុករបស់ខ្ញុំទៅមន្ទីរពេទ្យ គាត់មានជំងឺហើមដោយសារតែអត់មានអាហារហូប។ ឪពុករបស់ខ្ញុំស្រែករកឲ្យគេជួយ «ខ្ញុំចុកពោះខ្លាំងណាស់» ពេទ្យបានយកថ្នាំមួយក្តាប់ពណ៌ខ្មៅចេញមក។ ម៉ែក៏យកថ្នាំនោះមកឲ្យពុក ប៉ុន្តែថ្នាំនោះមិនបានធ្វើឲ្យពុកបាត់ឈឺនោះទេ។ ពុកថ្ងូរ ឈឺ។ ពេទ្យក៏ចេញមក ហើយស្រែកសម្លុតឲ្យពុក។ ម៉េចក៏ស្រែកខ្លាំងៗម្ល៉េសអ្នាស! ចង់ងាប់អ្នាស! ពេទ្យក៏ដើរចេញទៅយកសឺរ៉ាំងមកចាក់ចូលក្នុងសាច់ពុក ពុកបាត់មាត់ឈឹង»។

ក្រោយរបបខ្មែរក្រហមដួលរលំ ក្មេងស្រីដែលបានបាត់បង់ឪពុកលែងចង់និយាយស្តី ហើយប្រសិនបើនាងបានជួបគ្រូពេទ្យដែលធ្វើឲ្យឪពុករបស់នាងបាត់បង់អាយុជីវិតម្តងទៀតនាងប្រាកដជាមិនលើកលែងទោសឲ្យនោះទេ។

គ្រូពេទ្យនោះឈ្មោះ សុវណ្ណា គឺជាអតីតគ្រូពេទ្យនៅ



ហុង ចន្ទ្រា អង្គុយលើអង្រឹង ក្បែរផ្ទះ
(រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្នុងរបបខ្មែរក្រហម។ សុវណ្ណា តែងតែមានភាពខ្មាស់អៀនចំពោះរឿងរ៉ាវដែលខ្លួនបានធ្វើ។ «កាលពីឆ្នាំ១៩៧៦ ខ្ញុំមានអាយុ ១៥ឆ្នាំ។ ខ្ញុំបានចូលបម្រើដល់បដិវត្តន៍។ ខ្ញុំមើលថែអ្នកជំងឺ។ ខ្ញុំមានមោទកភាពខ្លាំងណាស់។ បន្តិចក្រោយមកខ្ញុំបានដឹងថា ខ្ញុំមិនអាចធ្វើអ្វីបានទាំងអស់ ព្រោះមន្ទីរពេទ្យនោះមិនបានធ្វើអ្វីដែលមន្ទីរពេទ្យគួរធ្វើនោះទេ។ យើងធ្វើការនៅទីនេះគ្រាន់តែបើកភ្នែកចាំមើលមនុស្សស្លាប់តែប៉ុណ្ណោះ។ យើងគ្មានអ្វីផ្តល់ឲ្យអ្នកជំងឺនោះទេសូម្បីតែថ្នាំសង្កូវ»។ ក្រោយខ្មែរក្រហមដួលរលំ ខ្ញុំបានជួបក្មេងស្រីដែលខ្ញុំបានព្យាបាលធ្វើឲ្យឪពុកនាងស្លាប់។ ខ្ញុំបានសុំនាងលើកលែងទោស ប៉ុន្តែនាងមិនបានលើកលែងទោសឲ្យខ្ញុំឡើយ។

គំនុំមិនត្រូវបានលើកលែងទោស។ ប៉ុន្តែប្រសិនភាគីទាំងពីរបានបើកបេះដូង និងគិតអំពីស្ថានភាពរបស់ភាគីម្ខាងទៀត នោះការលើកលែងទោសអាចនឹងត្រូវបានយកមកពិចារណា។ មានមតិរបស់អ្នកទស្សនាល្ខោននិយាយទម្លាយភាព «ស្ងៀមស្ងាត់» បានលើកឡើងប្រសិនបើពួកគេ គឺជាស៊ីណា ៖

ជុំ ស្រីម៉ុច ភេទស្រី អាយុ១៩ឆ្នាំ គឺជាគរុសិស្សឯកទេសអង់គ្លេស-ខ្មែរ មានទីកន្លែងកំណើតនៅឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ស្រីម៉ុច គិតថា ប្រសិនបើខ្ញុំ គឺជាស៊ីណា ខ្ញុំអាចមានឱកាសបានជួបអ្នកគ្រូពេទ្យម្តងទៀត ខ្ញុំនឹងសួរហេតុផល តើបានចាក់ថ្នាំអ្វីជូនពុកខ្ញុំ។ ប្រសិនបើគាត់និយាយមកមានហេតុផល ឬមិនមានហេតុផលត្រឹមត្រូវ ខ្ញុំអាចលើកលែងទោសឲ្យគាត់។ ខ្ញុំអាចលើកលែងទោសឲ្យគាត់ព្រោះក្នុងរបបខ្មែរក្រហមមិនមានសម្ភារ និងថ្នាំសង្កូវគ្រប់គ្រាន់។ របបអាហារនិងថ្នាំពេទ្យតិចតួច ធ្វើឲ្យគ្រូពេទ្យពិបាកក្នុងការព្យាបាល និងប្រើប្រាស់ថ្នាំគ្មានប្រសិទ្ធភាព។ គ្រូពេទ្យដែលទទួលបានការអប់រំតិចតួច ធ្វើឲ្យសីលធម៌វិជ្ជា



គរុសិស្សរង់ចាំទស្សនាការសម្តែងល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់
(រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជីវៈរបស់គ្រូពេទ្យមានកម្រិតទាប ដែលនាំឲ្យមិនមានភាពអត់ធ្មត់ចំពោះអ្នកជំងឺ។ ម្យ៉ាងវិញទៀត ស្ថានភាពប្រទេសនៅពេលនោះ គ្រូពេទ្យគ្មានសិទ្ធិអ្វីទាំងអស់ គឺស្ថិតនៅក្រោមបញ្ជារបស់ថ្នាក់លើ។ ខ្មែរក្រហមបានឆ្លងកាត់របបដ៏ជូរចត់នេះដូចគ្នា ហើយគាត់ត្រូវត្រឡប់មករស់នៅក្នុងពេលបច្ចុប្បន្ន ដូច្នេះយើងជាជនជាតិខ្មែរគួរតែស្រឡាញ់គ្នា។ ជីវិតរបស់មនុស្សមិនមានអាចស្ថិតស្ថេរបានទេ។ ខ្ញុំគឺជាគ្រូបង្រៀន ដូច្នេះទោះបីជាខ្ញុំខឹងយ៉ាងណាក៏ដោយ ក្តីស្រឡាញ់របស់ខ្ញុំចំពោះសិស្សនៅតែមាន និងមិនដែលមានចិត្តគុំកួនចំពោះសិស្សឡើយ។ ខ្ញុំពិតជាសប្បាយចិត្តខ្លាំងណាស់ដែលមានមើលល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ព្រោះកូនខ្មែរគួរតែយល់ដឹង និងចងចាំសោកនាដកម្មដ៏អាក្រក់ និងការពារកុំឲ្យរបបនេះកើតឡើងម្តងទៀត។ ខ្ញុំបានយល់ដឹងពីតថភាពនៅពេលនោះ ប្រជាជនគ្មានសិទ្ធិសេរីភាពអ្វីទាំងអស់។ ខ្ញុំមើលឃើញពីភាពខុសប្លែកគ្នាកាលពីរបបពីមុន និងរបបបច្ចុប្បន្ន។ ល្ខោននេះបានអប់រំឲ្យមនុស្សត្រូវចេះសាមគ្គី ចេះស្រឡាញ់គ្នា និងមានឆន្ទៈក្នុងការដោះស្រាយបញ្ហា និងត្រូវហ៊ានប្រឈមជាមួយបញ្ហា។

រស់បញ្ញា ភេទប្រុស អាយុ១៩ឆ្នាំ គឺជាគរុសិស្សឯកទេសប្រវត្តិវិទ្យា-ភូមិវិទ្យា មានស្រុកកំណើត នៅឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ប្រសិនបើខ្ញុំគឺជា ស៊ីណា ខ្ញុំនឹងលើកលែងទោសឲ្យគ្រូពេទ្យនោះ ព្រោះអ្នកគ្រូពេទ្យទទួលបាននូវការអប់រំតិចតួច ហើយវិស័យសុខាភិបាលក៏មានភាពខ្វត់ខ្វែងដែរ ដែលមានតែថ្នាំអាចជ័ទន្សាយសម្រាប់ព្យាបាលជំងឺគ្រប់មុខ។ ស៊ីណា គ្រាន់តែធ្វើតាមបញ្ជារបស់ថ្នាក់លើតែប៉ុណ្ណោះ។ គ្រូពេទ្យនៅសម័យនោះបានប្រើពាក្យសម្តីមិនគួរសមចំពោះអ្នកជំងឺដែលខុសពីវិជ្ជាជីវៈជាគ្រូពេទ្យ ហើយតាមរយៈរឿងនេះ ក៏អាចធ្វើការប្រៀបធៀបចំពោះគ្រូពេទ្យបច្ចុប្បន្នមួយចំនួនដែលទទួលបានការអប់រំប្រសើរជាងគ្រូពេទ្យនៅសម័យខ្មែរក្រហមដែរ។ «ទម្លាយភាពស្ងៀមស្ងាត់» បានធ្វើឲ្យខ្ញុំដឹងអំពីមូលហេតុដែលនាំឲ្យមានការបែកបាក់គ្នានៅក្នុងសង្គម។

ថៃ គឹមហុង ភេទប្រុស អាយុ១៨ឆ្នាំ គឺជាគរុសិស្សប្រវត្តិវិទ្យា-ភូមិវិទ្យា មានទីកន្លែងកំណើតនៅឃុំសូរ្យសែន ស្រុកព្រៃឈរ ខេត្តកំពង់ចាម។ គឹមហុង បានរៀបរាប់ថា ខ្ញុំមិនដែលបានទស្សនាល្ខោននិយាយ ដែលមានចំណងជើងថា «ទម្លាយភាពស្ងៀមស្ងាត់» ពីមុននោះទេ។ នៅក្នុងឈុតទី២ នៃរឿងនេះបានបង្ហាញឲ្យខ្ញុំបានដឹងអំពីភាពខ្វះខាតនៃវិស័យសុខាភិបាលក្នុងរបបខ្មែរក្រហម។ គ្រូពេទ្យព្យាបាលអ្នក


ស្រី ម៉ុច គរុសិស្សភាសាខ្មែរ និងភាសាអង់គ្លេសនៅគរុកោសល្យភូមិភាគកំពង់ចាម (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជំងឺដោយខ្វះវិជ្ជាជីវៈ និងគ្មានសីលធម៌ចំពោះអ្នកជំងឺ។ ប្រសិនបើខ្ញុំ គឺជាតួអង្គដែលឪពុកត្រូវបានគ្រូពេទ្យព្យាបាលឲ្យស្លាប់ ខ្ញុំនឹងលើកលែងទោសឲ្យគ្រូពេទ្យនោះ ព្រោះរឿងទាំងអស់នេះជារឿងរ៉ាវអតីតកាល។ ប្រសិនបើខ្ញុំទោសម្លាប់គ្រូពេទ្យនោះ ឪពុករបស់ខ្ញុំក៏មិនអាចត្រឡប់មកវិញដែរ»។ គ្រូពេទ្យនោះគឺ ស្ថិតនៅក្រោមការគាប់សង្កត់របស់អង្គការ។

ហុង ចន្ទ្រា អាយុ ៥៤ឆ្នាំ មានស្រុកកំណើតនៅឃុំវត្តគរ ស្រុកសង្កែ ខេត្តបាត់ដំបង។ ចន្ទ្រា បានលើកឡើងថា ខ្ញុំបានមើលល្ខោន «ទម្លាយភាពស្ងៀមស្ងាត់» ខ្ញុំបាននឹកដល់ឪពុកខ្ញុំដែលធ្វើជាទាហាន។ ឪពុករបស់ខ្ញុំបានលាក់ប្រវត្តិរូបមិនឲ្យខ្មែរក្រហមដឹងឡើយ។ ឪពុករបស់ខ្ញុំត្រូវបានបញ្ជូនទៅសមរភូមិនៅភូមិក្បាលដំរី។ ក្រោយមកនៅពេលដែលគាត់ឈឺ ឪពុរបស់ខ្ញុំក៏ត្រូវបានខ្មែរក្រហមបញ្ជូនមកវិញ។ ឪពុករបស់ខ្ញុំសម្រាកព្យាបាលនៅមន្ទីរពេទ្យ។ ឪពុករបស់ខ្ញុំមានជំងឺហើម ហើយខ្ញុំបានទៅមើលគាត់នៅមន្ទីរពេទ្យ។ ខ្ញុំចង់មើលថែទាំឪពុករបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនអាចធ្វើបាននោះទេព្រោះអង្គការមិនអនុញ្ញាត។ ឪពុករបស់ខ្ញុំហើម ហើយសាច់របស់គាត់ពណ៌ឡើងខៀវ។ ឪពុករបស់ខ្ញុំប្រហែលមិនមានអាហារហូប។ ឪពុករបស់ខ្ញុំឃ្លានពោតស្ងោរ។ ខ្ញុំក៏បានទៅលួចពោតនៅក្នុងចម្ការដើម្បីស្ងោរឲ្យពុកហូប។ ខ្ញុំបានទៅដល់ចម្ការពោតខ្ញុំ មិនឃើញមនុស្សសូម្បីតែម្នាក់។ បន្ទាប់ពីខ្ញុំបានកាច់ពោតបានចំនួនពីរទៅបីផ្លែស្រាប់តែឈ្លបមកភ្ជង់ខ្ញុំ។ ឈ្លបនោះបាននាំខ្ញុំទៅជួបប្រធានរបស់គេ ហើយបានសួរនាំខ្ញុំ។ ខ្ញុំបានឆ្លើយប្រាប់ត្រង់ថា ឪពុករបស់ខ្ញុំឈឺ ហើយគាត់ឃ្លានពោត។ សំណាងល្អប្រធានកងឈ្លបបានដោះលែងខ្ញុំ។ ដោយសារឪពុករបស់ខ្ញុំនៅសល់មាសខ្លះ ដូច្នេះគាត់ក៏លួចយកមាសទៅដូរយកថ្នាំជាមួយគ្រូពេទ្យ។ ឪពុករបស់ខ្ញុំបានជាសះស្បើយពីជំងឺ។ ប្រសិនបើឪពុករបស់ខ្ញុំស្ថិតនៅក្នុងស្ថានភាពដូចជាតួអង្គឪពុករបស់ ស៊ីណា ខ្ញុំមិនខឹងនឹងគ្រូពេទ្យនោះទេ ព្រោះគ្រូពេទ្យនោះទទួលបញ្ជាពីថ្នាក់លើ។ ប្រសិនបើគ្រូពេទ្យនោះមិនធ្វើតាមបញ្ជារបស់ថ្នាក់លើទេ គ្រូពេទ្យនោះប្រាកដជាត្រូវបានយកទៅសម្លាប់ជាមិនខាន។

បន្ទាប់ពីការសម្តែង «រឿងទម្លាយភាពស្ងៀមស្ងាត់» សាធារណជនក៏បានបង្ហាញអំពីគំនិត តម្លៃអប់រំរបស់ល្ខោននេះជាមួយសាច់រឿងផ្ទាល់ខ្លួន ដែលបានជំរុញឲ្យមនុស្សទាំងអស់រស់នៅក្នុងសង្គមដោយសុខសន្តិភាព រំសាយនូវកំហឹងឈប់មានគំនុំគ្នាចំពោះរឿងរ៉ាវអតីតកាល និងត្រូវចេះរួបរួមគ្នាដើម្បីអភិវឌ្ឍន៍ប្រទេសជាតិ។ **ដារ៉ារដ្ឋ មេត្តា**



ការសម្តែងនិយាយទម្លាយភាពស្ងៀមស្ងាត់នៅខេត្តកំពង់ចាម
(រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ដំណឹងជ្រើសរើសអ្នកស្រាវជ្រាវ

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសអ្នកស្រាវជ្រាវដែលគ្រូបង្រៀន ឬអតីតគ្រូបង្រៀនឯកទេសប្រវត្តិវិទ្យាចំនួន២០នាក់ ឲ្យចូលរួមក្នុងការសរសេរសំណេរ«ប្រវត្តិសាស្ត្រចេញពីភូមិ»ទាក់ទងនឹងព្រឹត្តិការណ៍នៅក្នុងរបបខ្មែរក្រហម ចេញពីភូមិឃុំដែលខ្លួនកំពុង ឬធ្លាប់បំពេញការកិច្ចជាគ្រូបង្រៀន។ កិច្ចការនេះ ជាកិច្ចការស្ម័គ្រចិត្តនៅក្នុងគម្រោងស្ដីអំពី «ប្រវត្តិសាស្ត្រភូមិ» ហើយក៏ជាដំណាក់កាលទី២នៃការអនុវត្តកិច្ចការនេះដែរ។ សំណេររបស់អ្នកស្រាវជ្រាវ នឹងត្រូវបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា រួចប្រគល់ជូនវិញដើម្បីប្រើប្រាស់ជាសម្ភារឧបទ្ទេសក្នុងការបង្រៀន ឬប្រើប្រាស់ផ្ទាល់ខ្លួន។ មជ្ឈមណ្ឌលឯកសារកម្ពុជា ឧបត្ថម្ភជាថវិកាសម្រាប់ការស្រាវជ្រាវនេះ។






*លក្ខខណ្ឌជ្រើសរើស*

១) អ្នកស្រាវជ្រាវ ត្រូវតែជាអតីត ឬគ្រូបង្រៀនឯកទេសប្រវត្តិវិទ្យានៅក្នុងខេត្តព្រៃវែង, ស្វាយរៀង, ត្បូងឃ្មុំ, កណ្ដាល (ស្រុកមុខកំពូល, ល្វាឯម និងខ្សាច់កណ្ដាល) និងក្រចេះ (ស្រុកឆ្លូង) ដែលមិនជាប់តួនាទីជានាយកឬនាយករងនៃវិទ្យាល័យ ឬការងារដ៏ទៃទៀតដែលខ្លួនកំពុងធ្វើការ។

២) មានចំណេះដឹងអំពីវិធីសាស្ត្រក្នុងការធ្វើកិច្ចការស្រាវជ្រាវដូចជាការធ្វើបទសម្ភាសន៍ទំនាក់ទំនងជាមួយអ្នកដែលត្រូវសម្ភាសន៍ វិភាគលើទិន្នន័យដើម និងសរសេរ។

៣) មានចំណេះដឹងសមរម្យក្នុងការប្រើប្រាស់កុំព្យូទ័រលើកម្មវិធី Microsoft Word & Excel និងមានកុំព្យូទ័រផ្ទាល់ខ្លួនដើម្បីធ្វើកិច្ចការនេះ។

៤) មានការប្ដេជ្ញាចិត្តខ្ពស់ក្នុងការសម្រេចឲ្យបាននូវសំណេរតាមការកំណត់។

៥) មានភាពច្នៃប្រឌិតចំពោះការប្រើប្រាស់ឧបករណ៍ (ថតសំឡេង និងម៉ាស៊ីនថត) សម្រាប់កិច្ចការស្រាវជ្រាវ។

៦) មានសមត្ថភាពទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន។

*លក្ខខណ្ឌការងារ*

១) ធ្វើកិច្ចការស្រាវជ្រាវដោយមិនឲ្យប៉ះពាល់ដល់ម៉ោងបង្រៀនសិស្សនៅតាមវិទ្យាល័យដែលខ្លួនកំពុងបង្រៀន។

២) ប្រើប្រាស់ពេលវិស្សមកាល ឬពេលទំនេរពីការបង្រៀន ដើម្បីធ្វើកិច្ចការនេះ។

៣) បែងចែកពេលវេលាច្បាស់លាស់ពីដំណើរការប្រព្រឹត្តទៅនៃកិច្ចការស្រាវជ្រាវ រួចផ្ញើមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីការសហការ។ ឧទាហរណ៍៖ បង្ហាញគម្រោងផែនការជាដំណាក់កាលៗដូចជា៖ ប្រមូលធនធានសម្រាប់ ឯកសារយោង, កំណត់គោលដៅសម្រាប់សម្ភាសន៍, ការសម្ភាសន៍, វិភាគទិន្នន័យសម្ភាសន៍ និងសំណេរ។

៤) សរសេរកិច្ចការស្រាវជ្រាវឲ្យបានយ៉ាងហោចណាស់២០ទំព័រ។

៥) ផ្ញើសំណេរ និងកិច្ចសម្ភាសន៍ជាសំឡេងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីរក្សាទុក និងងាយស្រួលក្នុងការពិនិត្យផ្ទៀងផ្ទាត់ និងបោះពុម្ព។

ប្រសិនបើលោកគ្រូអ្នកគ្រូ និងប្រិយមិត្តដ៏ទៃទៀតមានការចាប់អារម្មណ៍លើកិច្ចការនេះ សូមដាក់ពាក្យស្នើសុំមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយភ្ជាប់មកជាមួយនូវ ៖ ១) ពាក្យស្នើសុំធ្វើកិច្ចការស្រាវជ្រាវប្រវត្តិភូមិ។ ២) ប្រវត្តិរូបសង្ខេប១ច្បាប់ និង ៣) សេចក្ដីអធិប្បាយត្រួសៗពីប្រធានបទដែលចង់សរសេរ តាមអាសយដ្ឋាន ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឬផ្ញើមកកាន់អ៊ីមែល៖ truthrasy.p@dccam.org។ ការទទួលពាក្យផុតកំណត់ត្រឹម ថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០១៩។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីស្រាវជ្រាវ និងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា តាមទូរសព្ទ៖ ០១២ ៦៩៦៩៦១ ឬអ៊ីមែល៖ truthrasy.p@dccam.org ។

# បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមចារទុកក្នុងសៀវភៅរំឭកវិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

(តពីលេខមុន)

ង្វូន សាមិត្ត ហៅ វៀង យ៉ាំងថាំ ហៅ នី មានអាយុ២៧ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅព្រៃវែងខេត្តព្រៃវែង ឪពុកម្តាយ ង្វូន កានង្វៀងយាំកង និង ង្វៀងធីវិញ មានប្រពន្ធឈ្មោះ ឡេ ធីធី មានកូនប្រុស ១នាក់ និងស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៥ នៅសណ្ឋាគារឡឺភ្នំ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែង ក្នុងផ្ទះ ក០៧ បន្ទប់ធំ ១០។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការចូលក្នុងគុកទួលស្លែង និងការសម្លាប់នៅឡើយ។

ង្វៀវ ប៊ុនខេង មានអាយុ២០ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកងមាស ខេត្តកំពង់ចាម ជាកូនរបស់ពូ ង្វៀវ ម៉េញ និងមីង ឈៀង ហ៊ុន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៧។ ខ្មែរក្រហមបញ្ចូល ង្វៀវ ប៊ុនខេង ក្នុងគុកទួលស្លែងនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៧៧ និងសម្លាប់ចោលនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៧។

ង្វូន អកដ្ឋា មានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅភ្នំពេញ ជាកូនរបស់ពូ ង្វូន ផៃ និងមីង គីម ហួយ មានប្រពន្ធឈ្មោះ ទ្រូ ចន្ទលី ហៅ គង់ មានកូនប្រុស២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៧ នៅស្រុកភ្នំស្រុក តំបន់៥ (ខេត្តបាត់ដំបង) ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះក០៥ បន្ទប់ធំ១៤។ ខ្មែរក្រហមសម្លាប់ ង្វូន អកដ្ឋា ឬ ង្វូន អថា នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៦។

ង្វូន សាមិត្ត ហៅ វៀង យ៉ាំងថាំ ហៅ នី មានអាយុ២៧ឆ្នាំ ក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅព្រៃវែង ខេត្តព្រៃវែង ឪពុកម្តាយ ង្វូន កានង្វៀងយាំកង និង ង្វៀងធីវិញ មានប្រពន្ធឈ្មោះ ឡេ ធីធី មានកូនប្រុស១នាក់ និងស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៥ នៅសណ្ឋាគារឡឺភ្នំ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែង ក្នុងផ្ទះក០៧ បន្ទប់ធំ១០។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការចូលក្នុងគុកទួលស្លែង និងការសម្លាប់នៅឡើយ។

ង្វៀវ ប៊ុនខេង មានអាយុ២០ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកងមាស ខេត្តកំពង់ចាម ជាកូនរបស់ពូ ង្វៀវ ម៉េញ និងមីង ឈៀង ហ៊ុន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៧។ ខ្មែរក្រហមបញ្ចូល ង្វៀវ ប៊ុនខេង ទៅគុកទួលស្លែងនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៧៧ និងសម្លាប់ចោលនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៧។

ង្វៀង ដិនអ៊ី ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ នៅកំពង់សោម។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា ង្វៀន ដិនអ៊ី ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៥, បញ្ចូលទៅក្នុងគុកទួលស្លែងនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៦។

ង្វៀង ធីថាន់ មានអាយុ៤១ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅភ្នំពេញ ឪពុកម្តាយ ង្វៀង ថាន់ផាង និង ង្វៀង ធីហឿង មានប្តីឈ្មោះ ប្រាក់ អ៊ុល ធ្វើការក្នុងក្រុមភូមិសាស្ត្រកងពល៣១០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៦ ខែកុម្ភៈ

ឆ្នាំ១៩៧៧ នៅកងពល៣១០។ ខ្មែរក្រហមសម្លាប់ ង៉ៀង ធីថាន់ នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៧។ ចំណែកឯ ប្តីឈ្មោះ ប្រាក់ អ៊ុល ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃជាមួយគ្នានឹងប្រពន្ធ ហើយសម្លាប់មុនប្រពន្ធគឺនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៧៧។

ង៉ៀង ធី ធឿង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៧ ខែឧសភាឆ្នាំ១៩៧៦ នៅកំពង់សោម។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារកឃើញថា ង៉ៀង ធី ធឿង ត្រូវបានខ្មែរក្រហមចាប់ខ្លួនតាំងពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៧៥ មកម៉្លេះ។ ខ្មែរក្រហមបញ្ជូល ង៉ៀង ធី ធឿង ទៅក្នុងគុកទួលស្លែងនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៦។

ង៉ៀង ធី ឡាំ មានអាយុ១៥ឆ្នាំក្នុងឆ្នាំ១៩៧៧ ប្អូនស្រីរបស់ ង៉ៀង ធីថាន់ ស្រុកកំណើតនៅភ្នំពេញ ឪពុកម្តាយ ង៉ៀង ថាន់ជ្រៀវ និង ង៉ៀង ធីហឿង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅកងពល៣១០។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ង៉ៀង យ៉ាងលី ជាប់គុកទួលស្លែងក្នុងផ្ទះលេខ០៨ បន្ទប់លេខ១១។ ខ្មែរក្រហមចាប់បញ្ជូលក្នុងគុកទួលស្លែងនៅថ្ងៃទី៦ ឬ ១០ ខែមីនា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ង៉ៀង យ៉ាងហុង អាយុ១៣ឆ្នាំក្នុងឆ្នាំ១៩៧៦ ស្រុកកំណើតនៅអាំងភូ ខេត្តចុងដុក ឪពុកម្តាយ ង៉ៀង យ៉ាងទី និង ង៉ៀង ធីយិន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៧៦ នៅស្រុកកោះធំ តំបន់២៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះក០២ បន្ទប់លេខ១១។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ង៉ៀង ហូឡាង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ នៅកំពង់សោម ហើយសម្លាប់ចោលនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៦។

ចក អុន មានអាយុ៣៧ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅបារាយណ៍ ខេត្តកំពង់ធំ ជាកូនរបស់អ៊ំ អៀង អ៊ឹម និងអ៊ំស្រី អ៊ុំ មានប្រពន្ធឈ្មោះ សូ ស៊ិនថន ហៅ ថន មានកូនប្រុស៣នាក់ និងស្រី២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៦ នៅភ្នំពេញ។ ខ្មែរក្រហមសម្លាប់ ចក អុន នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៧៦ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ៨៦ ថ្ងៃ។

ចក់ យន់ មានអាយុ៤១ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅខេត្តព្រៃវែង ជាកូនរបស់អ៊ំ ចក់ កេញ និង អ៊ំស្រី ឃ្លោក កែវ មានប្រពន្ធឈ្មោះ ហៀង យ៉ុន មានកូនប្រុស២នាក់ និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ១ បន្ទប់ធំ៥។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង និងការសម្លាប់នៅឡើយ។

ចក់ សុង ជាប្រជាជន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅតំបន់២៥ ក្នុងឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង និងការសម្លាប់នៅឡើយ។

ចក់ សំអុន មានអាយុ២១ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅទឹកជ្រៅ ខេត្តកំពង់ចាម ជាកូនរបស់ពូ ចក់ អ៊ឹម និងមីង គី អេន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៦ នៅស្រុកកៀនស្វាយ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះក០៥ បន្ទប់ធំ៥។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង និងការសម្លាប់នៅឡើយ។

ចក់ ហុន ប្រធានកងហ កងពល១៧០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៧៦ នៅកងពល១៧០។ ខ្មែរក្រហមសម្លាប់ ចក់ ហុន នៅថ្ងៃទី១៦ ខែកញ្ញា

ឆ្នាំ១៩៧៦ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ១៤ថ្ងៃ។

ចក់ ហួត មានអាយុ១៩ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រៃកប្បាស ខេត្តតាកែវ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្រុក ២០ ថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងបន្ទប់ធំ០៧ បន្ទប់តូច៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ចក់ អែត ហៅ សៀន អាយុ៤១ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅទ្រាំង ខេត្តតាកែវ ជាកូនរបស់អ៊ំ ចក់ អ៊ិត និងអ៊ំស្រី យិន អេម មានប្រពន្ធឈ្មោះ ឈឿន ហៅ ស៊ាន មានកូនប្រុស១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧ (៦) ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែង បន្ទប់ធំ ៥ បន្ទប់តូច១។ ខ្មែរក្រហមសម្លាប់ ចក់ អែត នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៧៦ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ១៨ ថ្ងៃ។

ចក់ហៀប ជាកម្មករចាស់ត្រូវបានខ្មែរក្រហមចាប់ឃាត់ខ្លួននៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦ នៅរទេះភ្លើង។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង និងការសម្លាប់នៅឡើយ។

ចន អឿន មានអាយុ២៥ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅជើងព្រៃ ខេត្តកំពង់ចាមយុទ្ធជនកងពល៣១០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅកងពល៣១០។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ចាង ដិន អឹង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ នៅកំពង់សោម។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ចាង យ៉ាងហៅ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ នៅកំពង់សោម ហើយសម្លាប់ចោលនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៧៦។

ចាង យ៉ាងឡាក អាយុ៤៤ឆ្នាំ ជនជាតិយួន (វៀតណាម) ត្រូវបានខ្មែរក្រហមចាប់ខ្លួនមកដល់គុកទួលស្លែងនៅថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៧៦ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ចាង យឹនជឹង មានអាយុ២៥ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅខេត្តឡុងចូវទៀវ ឪពុកម្តាយ ត្រឹង យឹងទៀង និង យ៉ាធីងអាង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ០២ បន្ទប់តូច៤។ ខ្មែរក្រហមបញ្ជូន ចាង យឹនជឹង ទៅដល់គុកទួលស្លែងនៅថ្ងៃទី៦ ឬ ១០ ខែមីនា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ចាង សេងណុង អតីតគ្រូបង្រៀន ត្រូវបានខ្មែរក្រហមចាប់ឃាត់ខ្លួនក្នុងឆ្នាំ១៩៧៦។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា ខ្មែរក្រហមបញ្ជូល ចាង សេងណុង ដល់គុកទួលស្លែងនៅថ្ងៃខុសគ្នាគឺថ្ងៃទី១២ និង២៧ ខែតុលា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៦។

ចាន់ កាត មានអាយុ៤៦ឆ្នាំ មានស្រុកកំណើតនៅស្រុក ១៨ (ស្រុកកោះធំ) ខេត្តកណ្តាល ជាកូនរបស់អ៊ំ ញាន ចាន់ និងអ៊ំស្រី កុង យួន មានប្រពន្ធឈ្មោះ ប៉ុង កុង មានកូនប្រុស ៤នាក់ និងស្រី២នាក់ ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅភ្នំពេញ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៦ បន្ទប់តូច ២។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង និងការសម្លាប់នៅឡើយ។

**(នៅមានត)**

*វ៉ាន់ថាន់ ពៅដារ៉ា និង ឡុង ដានី*

មជ្ឈមណ្ឌលឯកសារកម្ពុជា

# អដ្ឋិធាតុ៖ គ្មានអ្វីជាអមតៈ

## បញ្ជីអដ្ឋិធាតុដែលរកឃើញនៅក្រោមបល្ល័ង្កព្រះពុទ្ធរូបក្នុងវត្តលង្កា, ទីក្រុងភ្នំពេញ

រៀបរៀងដោយ៖ ចាន ប្រាថ្នា, សា ហ្វាទីលី, សុភ័ក្ត្រ ភាណា និង អ៊ុន សុដាវី
វិទ្យាស្ថានស្លឹករឹត, ខែកុម្ភៈ ឆ្នាំ២០១៥

(តពីលេខមុន)

| ល.រ | លេខកូដ | ឈ្មោះជាភាសាអង់គ្លេស | ឈ្មោះ | ភេទ | អាយុ | ថ្ងៃមរណភាព | ទំព័រក្នុងសៀវភៅ |
|---|---|---|---|---|---|---|---|
| ៤១៤ | ៨៩២៣ | Thlork Paulida | ធ្លក ប៉ូលីដា | ? | ? | ? | ២២៧ |
| ៤១៥ | ៨៩៤១ | Keo Un | កែវ អ៊ុន | ? | ? | ៣០/១០/១៩៨៤ | ២៣០ |
| ៤១៦ | ៨៩៤៧ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៣០ |
| ៤១៧ | ៨៩៥៣ | Svay Sao | ស្វាយ សៅ | ? | ? | ១៦/០៨/១៩៨៨ | ២៣០ |
| ៤១៨ | ៨៩៥៨ | Kang Vanny | កង វ៉ាន់នី | ស្រី | ? | ០៦/០៩/១៩៨៣ | ២៣៣ |
| | | Nhik Neang | ញឹក នាង | ? | ? | ? | |
| ៤១៩ | ៨៩៦១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៣៣ |
| ៤២០ | ៨៩៦៥ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៣៣ |
| ៤២១ | ៨៩៦៨ | Pen Sinat | ប៉ែន ស៊ីណាត | ? | ? | ? | ២៣៣ |
| ៤២២ | ៨៩៧១ | Ly Choung | លី ដួង | ? | ? | ? | ២៣៤ |
| ៤២៣ | ៨៩៨៤ | Ngauv Huoy | ង៉ូវ ហ៊ួយ | ស្រី | ? | ? | ២៣៤ |
| ៤២៤ | ៨៩៨៩ | Kim Rithyvuth | គីម ឫទ្ធីវុធ | ប្រុស | ៣ ឆ្នាំ | ១០/០៥/១៩៨៩ | ២៣៦ |
| ៤២៥ | ៨៩៩៧ | Chann Dimang | ចាន់ ឌីម៉ង់ | ស្រី | ៦ ឆ្នាំ | ១០/១០/១៩៨៨ | ២៣៦ |
| ៤២៦ | ៩០០១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៣៧ |
| ៤២៧ | ៩០១៦ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៣៩ |
| ៤២៨ | ៩០២០ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៣៩ |
| ៤២៩ | ៩០២២ | Yim Sarem | យឹម សារ៉េម | ? | ? | ? | ២៣៩ |
| ៤៣០ | ៩០២៦ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៤០ |
| ៤៣២ | ៩០២៧ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៤០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤៣២ | ៩០២៩ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៤០ |
| ៤៣៣ | ៩០៤១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៤៤ |
| ៤៣៤ | ៩០៤៤ | In Phally alias Am | ឥន ផល្លី ហៅ អាំ | ស្រី | ៣៧ ឆ្នាំ | ២៨/០៥/១៩៩៣ | ២៤៤ |
| ៤៣៥ | ៩០៥០ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៤៤ |
| ៤៣៦ | ៩០៥១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៤៩ |
| ៤៣៧ | ៩០៥៥ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៤៩ |
| ៤៣៨ | ៩០៤៦ | Pen Mut | ប៉ែន មុត | ? | ? | ? | ២៤៤ |
| ៤៣៩ | ៩០៦០ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៥០ |
| ៤៤០ | ៩០៥៧ | Om May | អុំម៉័យ | ? | ? | ? | ២៤៩ |
| ៤៤១ | ៩០៦៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៥៣ |
| ៤៤២ | ៩០៦៩ | Vannada | វណ្ណាដា | ? | ? | ០៦/០២/១៩៨១ | ២៤៩ |
| ៤៤៣ | ៩០៧៣ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៥០ |
| ៤៤៤ | ៩០៧៦ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៥០ |
| ៤៤៥ | ៩០៧៨ | Om Nguon *alias* Khliang | អុម ង៉ួន ហៅ ឃ្លាំង | ? | ? | ? | ២៥១ |
| ៤៤៦ | ៩០៨២ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៥៣ |
| ៤៤៧ | ៩០៨៥ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៥៣ |
| ៤៤៨ | ៩០៨៨ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៥៤ |
| ៤៤៩ | ៩០៩០ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៥៤ |
| ៤៥០ | ៩០៩៣ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៥៤ |
| ៤៥១ | ៩០៩៦ | Kim Ngon | គីម ង៉ុន | ប្រុស | ? | ? | ២៥៤ |
| ៤៥២ | ៩០៩៩ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | |
| ៤៥៣ | ៩១០៣ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៥៤ |
| ៤៥៤ | ៩១០៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៥៧ |

(នៅមានត)

# ដំណឹងស្វែងរកកូនប្រុស ផាន់ សុធា បាត់ខ្លួននៅសម័យខ្មែរក្រហម


ផាន់ សុខុម

ខ្ញុំបាទឈ្មោះ ផាន់ សុខុម មានទីកន្លែងកំណើតនៅខាងជើងវត្តទួលទំពូង ក្នុងក្រុងភ្នំពេញ។ ពីមុនសម័យខ្មែរក្រហម ខ្ញុំមានតួនាទីជាទាហានជើងទឹក នៅជ្រោយចង្វារ។ នៅពេលដែលខ្មែរក្រហមចូលមកទីក្រុងភ្នំពេញ ឆ្នាំ១៩៧៥ ខ្មែរក្រហម បានជម្លៀសក្រុមគ្រួសាររបស់ខ្ញុំ ទៅព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ខ្ញុំបានរស់នៅខេត្តតាកែវបានមួយរយៈ ទើបខ្មែរក្រហមបានបញ្ជូនគ្រួសារខ្ញុំឲ្យទៅរស់នៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ជាមួយប្រពន្ធរបស់ខ្ញុំឈ្មោះ សុផាវី ពីមុនជាគ្រូបង្រៀននៅជ្រោយចង្វារ និងម្ដាយឈ្មោះ ញ៉ឹម យ៉ា ព្រមទាំងកូនប្រុសរបស់ខ្ញុំម្នាក់ឈ្មោះ ផាន់ សុធា អាយុ៣ឆ្នាំ។ កូនខ្ញុំ ផាន់ សុធា កើតថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៣។

ក្រោយមក ប្រពន្ធរបស់ខ្ញុំបានកើតពិស និងបានស្លាប់នៅពេលខ្មែរក្រហមចាត់តាំងគាត់ ឲ្យទៅធ្វើការនៅស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ខណៈដែលខ្ញុំត្រូវបានខ្មែរក្រហមបំបែក ចេញពីគ្រួសារឲ្យទៅនេសាទត្រី នៅខាងស្ទឹងសង្កែ ខេត្តបាត់ដំបង។ ចំណែកកូនប្រុសរបស់ខ្ញុំ ដោយសារនៅក្មេងពេកមិនដឹងថាម្ដាយស្លាប់ទេ គឺនៅយំខឹបសាកសពម្ដាយ។

នៅពេលវៀតណាមវាយចូលប្រទេសកម្ពុជាឆ្នាំ១៩៧៩ ខ្ញុំបានទទួលដំណឹងថា មានតាចាស់ម្នាក់បានយកកូនរបស់ខ្ញុំទៅចិញ្ចឹម។ នៅឆ្នាំ១៩៨០ ខ្ញុំបានភៀសខ្លួនទៅនៅជំរំខាវអ៊ីដាង ក្នុងទឹកដីថៃ។ ក្រោយមក ខ្ញុំបានចេញទៅរស់នៅសហរដ្ឋអាមេរិក ប៉ុន្តែមិនដែលបានទទួលដំណឹងពីកូនប្រុសរបស់ខ្ញុំឡើយ។

ដូច្នេះ ប្រសិនបើបងប្អូនណាបានដឹងដំណឹង ឬស្គាល់កូនប្រុសរបស់ខ្ញុំ ផាន់ សុធា សូមទាក់ទងមកខ្ញុំបាទឈ្មោះ ផាន់ សុខុម តាមរយៈអាសយដ្ឋាន៖ #1419 Red Field Rodd, Bel Air, MD (Marry Land) 2115, USA អ៊ីម៉ែល Sxphann@yahoo.com ទូរសព្ទនៅប្រទេសកម្ពុជាលេខ ០១៥ ៩៧១ ១៨៤ ទូរសព្ទនៅកន្លែងធ្វើការផ្ទារលេខ ៤១ ៤៣៦ ២៥៩២ និងទូរសព្ទដៃ ៤៤ ៣៤ ១៨៤ ៣១៤ ឬ មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ក្រុងភ្នំពេញ ទូរសព្ទលេខ ០២៣ ២១១ ៨៧៥។

សូមអរគុណ!



ក្រុមនិស្សិតកំពុងទស្សនចិច្ចសិក្សាមជ្ឈមណ្ឌលឯកសារភូមិភាគបូព៌ា


**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 233, May 2019 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M BRK, 30 Ocotber 2018.